ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- កែ ពក ការពារខ្លួនមុនពេលស្លាប់
- [illegible]

[illegible]

លេខ២៧ ខែមីនា ឆ្នាំ២០០២

# ស្វែងរកការពិត

លេខ២៧ ខែមីនា ឆ្នាំ ២០០២

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា


## មាតិកា


- សំបុត្រ៖ ប្រសិនបើយើងខកខាន.......................................... ១

**ផ្នែកឯកសារ**

- កែ ពក ការពារខ្លួនមុនពេលស្លាប់.......................................... ២
- ចម្លើយសារភាពនិងទូរលេខ................................................ ៨
- តើជាចេតនានៃការសម្លាប់ផ្តាច់ពូជ........................................១៣
- ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍..............................១៥
- លោកទស្សនៈបដិវត្តនិងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារ ......១៧
- ការបោះឆ្នោតនៅកម្ពុជាក្នុងឆ្នាំ១៩៧៦..................................២៣
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ ...... ២៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- កំណាប់ព្រលឹងប្រវត្តិសាស្ត្រ............................................... ២៦
- ការងារដែលជាថ្នូរនឹងការរស់រានមានជីវិត............................ ៣១
- សម្លេងពីមន្ទីរ ស-២១ .....................................................៣៥
- រូបថតឯកសារ............................................................... ៤០

**ផ្នែកច្បាប់**

- តុលាការនៅទីម័រខាងកើត..................................................៤២

**វេទិកាពិភាក្សាសាធារណៈ**

- ការវិភាគទៅលើសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ ...៤៩
- ចរិតអង្គការសហប្រជាជាតិ.................................................៥១
- ការជំនុំជម្រះក្តីមីឡូស៊ីវិក ..................................................៥៣
- សេចក្តីថ្លែងការរបស់រាជរដ្ឋាភិបាលកម្ពុជា ..............................៥៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- ស្លាប់ព្រោះស្រឡាញ់ស្រុកកំណើត...................................... ៥៨

**សិល្បៈខ្មែរក្រហម**

- ប្រលោមលោកបដិវត្តៈ ពលិកម្មម៉ែៗយើង.............................. ៦០
- ចម្រៀងៈ កុមារក្រុមសាមគ្គីរៀនផងធ្វើការផង........... ក្របក្រោយ




ជនរងគ្រោះ


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


***វាគ្មិនលេខនេះ៖*** *ដេវីត ឆេនដល័រ, ស៊ូហ្សាណា លីនតុន, វ៉េមិន ចូហាន់សាន់, ភីតធ័រ ម៉ាឃ្យៀរ, សុខ វណ្ណៈ, ហ៊ុយ វណ្ណៈ, ឡុង ដានី, យិន នាន, ឃួយ វិសាលមុនី* ***អ្នកនិពន្ធនិងស្រាវជ្រាវ៖*** *លី សុផល, ជួង សុភារិទ្ធ* ***ជំនួយការនិពន្ធនាយក៖*** *សាន កល្យាណ* ***និពន្ធនាយករងទី១៖*** *ស្ទួ ប៊ុនស៊ូ* ***និពន្ធនាយករងទី២៖*** *ស៊ឹម សុរិយ៉ា* ***អ្នកបកប្រែ៖*** *អេង កុកថាយ* ***និពន្ធនាយកទូទៅ៖*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រ៖*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយ៖*** *សុខ វណ្ណៈ*

*សំបុត្រៈ*

# ប្រសិនបើយើងខកខាន...

យើងទាំងអស់គ្នាដែលជាប្រជាជនកម្ពុជានិងសហគមន៍អន្តរជាតិ នឹងបន្តចង្អុលដាក់គ្នាជារៀងរហូតអស់មួយជីវិត និងបន្តចង្អុលដាក់គ្នារាប់ជំនាន់តទៅមុខទៀត ប្រសិនបើយើងខកខានមិនបានបង្កើតឡើងនូវតុលាការឯករាជ្យមួយសម្រាប់វិនិច្ឆ័យឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហម ។ មិនតែប៉ុណ្ណោះទៀតសោត ប្រជាជនកម្ពុជាជាច្រើននឹងបន្តជឿថា បរទេសគឺជាអ្នកដែលបានបញ្ឆោខ្មែរឲ្យសម្លាប់ខ្មែរគ្នាឯង ។

ប្រវត្តិសាស្ត្រពិភពលោកបានបង្ហាញថា ដរាបណាប្រវត្តិសាស្ត្រដែលមានភាពគួរឲ្យតក់ស្លុតនៃប្រទេសជាតិមួយមិនត្រូវបានដោះស្រាយ ភាពគួរឲ្យតក់ស្លុតទាំងនោះនឹងបន្តអន្ទោលតាមប្រាណប្រជាជននៃប្រទេសនោះមិនចេះចប់មិនចេះហើយ បន្តការឈឺចាប់ និងទាំងដល់កំហឹងដែលមិនអាចទប់បាននិងការមិនទុកចិត្តគ្នា ។ ប្រទេសដែលជួបស្ថានការណ៍បែបនេះមិនអាចអភិវឌ្ឍន៍ទៅមុខបានទេ ។

តើអ្នកណាមានកាតព្វកិច្ចកំណត់វាសនាប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់កូនខ្មែរជំនាន់ក្រោយៗ និងសម្រាប់មនុស្សជាតិទាំងមូល?

**ឆាំង យុ**






















ស្លាប់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២




ស្លាប់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧




ស្លាប់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧




ស្លាប់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨

# កែ ពក ការពារខ្លួនមុនពេលស្លាប់

## ប្រវត្តិរបស់ កែ ពក ឆ្នាំ១៩៤៩-១៩៨៥


រូបថតឯកសារៈ ហេង ស៊ីនិត


សមមិត្ត កែ ពក

ខ្ញុំបានចូលរួមតស៊ូតាំងពីឆ្នាំ១៩៤៩ ជិនាន់ឥស្សរៈ ។ ដល់មានកិច្ចព្រមព្រៀងហ្សឺណែវ ខ្ញុំឈប់តស៊ូ ទៅនៅផ្ទះ ។ រហូតដល់ឆ្នាំ១៩៥៧ ឈ្មោះ ស៊ីវ ហេង ជាលេខាបក្ស បានមកទាក់ទងភ្ជាប់គ្នាវិញ ។

នៅឆ្នាំ១៩៥៧នេះ ខ្ញុំចូលតស៊ូវិញ ហើយបានចូលបក្ស នៅឃុំស្វាយទាប ស្រុកចំការលើ ។ ឈ្មោះ ទៀប ជាលេខស្រុក ជាអ្នកបញ្ចូលខ្ញុំ ។ តែបក្សកាលនោះក៏នៅជាប់នឹងយួនដែរទេ ។

នៅឆ្នាំ១៩៥៨ ក្រោយពីខ្ញុំចូលបក្សហើយ គេឲ្យខ្ញុំធ្វើសកម្មភាពនៅស្រុកចំការលើជាស្រុកកំណើតរបស់ខ្ញុំវិញ ។

នៅចុងឆ្នាំ១៩៥៨ ស៊ីវ ហេង + ប៉ែន យុត ក្បត់ ។ ដល់ ស៊ីវ ហេង ជាលេខាបក្ស ក្បត់ ក៏ដាច់ការទាក់ទងជនបទ+ក្រុង (ភ្នំពេញ) ។

ដល់ឆ្នាំ១៩៥៩ មូលហេតុឡើងតស៊ូជាលេខាបក្ស ។ ទូ សាមុត កាលនោះគាត់បង្កប់ខ្លួនធ្វើជាកម្មករ ។ តែពេលនោះ ស៊ីវ ហេង ក្បត់ វាទៅប្រាប់គិញឲ្យមកចាប់ ទូ សាមុត សម្លាប់ចោល ។ ការទាក់ទងជនបទ+ភ្នំពេញនៅតែដាច់ដដែល ។

ដល់ឆ្នាំ១៩៦០ មានប្រជុំមហាសន្និបាតបក្សលើកទី១ ធ្វើនៅរ៉ាវទេះភ្លើងភ្នំពេញ ។ មហាសន្និបាតនេះរៀបចំនៅឆ្នាំ១៩៦៤ មានឈ្មោះ យ៉ុង មកពីបូព៌ា ជាមនុស្សរបស់ សោ

ភឹម ។ ឈ្មោះ យ៉ុង មកធ្វើការខាងខ្ញុំ ហើយមកគ្រប់គ្រងលើក,បទាំងអស់ដែលរៀបរាប់ពីខាងលើ ។

ដល់ចុងឆ្នាំ១៩៦៤ បាន កុយ ធួន ចុះមក ហើយ កុយ ធួន គេថារៀបចំធ្វើសន្និបាតមួយរបស់តំបន់ ។ ធ្វើនៅសង្កាត់គគីធំ ។ សន្និបាតរៀបចំ កុយ ធួន ជាលេខា ឯបុគ្គលបន្ទាប់មាន យ៉ុង-សាត... ។ ឯខ្ញុំនៅក្រោមគេទេ ។

១រយៈក្រោយមកមានទំនាស់គ្នា ក៏គេមានវិធានការកម្ទេច យ៉ុង ចោល ហើយ កុយ ធួន ទទួលខុសត្រូវ គឺនៅឆ្នាំ១៩៦៧ ។ ដល់ យ៉ុង ស្លាប់ សោ ភឹម ចុះមកពិនិត្យសកម្មភាពនៅសង្កាត់ចំការអណ្ដូង នៅភូមិប្រើសមាស ។ ពេលនោះខ្ញុំមានឥទ្ធិពល ហើយដល់ទាក់ទងក,បស្ដាំមេកុងវិញទាំងអស់ ។

ពេលនោះមូលដ្ឋានន,បរបស់ខ្ញុំមានៈ

- ស្រុកបារាយណ៍ៈ គឺឃុំឈូកខ្សាច់-ឃុំទ្រាល-ស្រឡៅ-ប្រទាង-គគីធំ-ក្រវ៉ា
- តាំងគោកៈ គឺឃុំស្រយោង-ស្វាយភ្លើង-ប្រទាង
- ជើងព្រៃៈ ឃុំសំពងដៃ-ស្ដើងដៃ-ស្រម៉-ជើងឆ្នុក-តាព្រង-ប្រើសមាស
- ស្រុកចំការលើៈ ឃុំចំការអណ្ដូង-ស្វាយទាប-ស្ដី-ជីយោ-ល្វាលើ-នាងលើង- តាប្រ៊ុក
- ស្ទឹងត្រង់ៈ ឃុំទួលព្រះឃ្លាំង-ព្រែកក់-មេសរជ្រៃ-ដងក្ដារ-អូរម្លូ-ណោមកោះស្នា ទួលសំបួរ-កម្មករបឹងកេត
- កំពង់សៀមៈ ឃុំរមាស-ស្រក-រំចេក
- ព្រៃឈរៈ ឃុំជ្រៃវៀន-សំរោង
- ស្ទោងៈ ក្រសាំង-ពពក
- សន្ទុកលើៈ សណ្ដាន់-មានរិត-ខ្វែង
- ព្រែកប្រសព្វៈ ឃុំមេមត់-ឫស្សីកែវ-តាម៉ៅ-សោប

ដល់ពាក់កណ្ដាលឆ្នាំ១៩៦៧ ចាត់តាំងគណៈភូមិភាគ មាន កុយ ធួន ជាលេខា ខ្ញុំជាអនុលេខា-ដឿនសមាជិក-ស្រេង-ប្រា-ថោង សំអាត ក៏ជាសមាជិក ។ ពេលនោះ បងធួនទៅច,តនៅកណ្ដាលក្រុងព្រៃឈរ ។

ឆ្នាំ១៩៦៨ ចាប់ផ្ដើមចូលព្រៃ ។ ពេលនោះ កុយ ធួន-ដឿន នៅក្រុង ស្រេង នៅជាប់ផ្លូវលេខ៧ ឯក្រៅពីនេះមកនៅព្រៃជាមួយខ្ញុំ ។ ក្នុងឆ្នាំ៦៨នេះ ឈ្មោះ ប្រា ត្រូវខ្មាំងបាញ់សម្លាប់នៅតំបន់១៣០ ។ ថោង សំអាត ខ្មាំងចាប់ទៅចំការអណ្ដូង ។

ឆ្នាំ៦៨ជាឆ្នាំបំផុសធ្វើកុប្បកម្ម ។ ខាងខ្ញុំបំផុសខាងក្រវ៉ា បាក់ស្នា ល្វាលើ ប៉ុស្ដិ៍តាប្រ៊ុក ។ ក្រវ៉ា យ ចូលអត់ចុះទេ ។ ឯតាប្រ៊ុក យ បានកាំភ្លើង៣ដើម ។ ក្រោយធ្វើកុប្បកម្ម មានបាតុករទាំងអស់២៥០នាក់ចូលព្រៃខាងគគីធំ ។ ពេលនោះអត់បាយអត់ទឹក ។

ខែ៨,៦៨ បាយក៏ដាច់ ខ្មាំងក៏វៃ យ បែកបាក់គ្នា ខ្មាំងចាប់បានខ្លះ ស្លាប់ខ្លះ ។ ភាគច្រើនខ្មាំងចាប់បានដាក់គុក ហើយសារភាពទៅ ។ ហើយនៅសល់តែខ្ញុំ គ្នា១០-២០នាក់ បន្តដ,នចលនាក្នុងព្រៃតទៅទៀត ដ,នគ្រប់ស្រុកដូចរៀបរាប់ខាងលើ ។

ខែ៦-៧,៦៨ ខ្មាំងធ្វើសកម្មភាពខ្លាំង គ្រួសារខ្ញុំដកចេញពីផ្ទះទៅកំពង់ចាម ទៅក្រចេះ ។ ដល់ក្រចេះស្លាប់កូន១ ។ គ្រួសារខ្ញុំអ្នករកអង្ករចិញ្ចឹមក,ច ។

ដល់ឆ្នាំ១៩៧០ លន់ ណុល ផែនក,លខ្មែរក្រហម១ចំនួនចេញពីគុក ។ ខ្ញុំត្រូវស្រវ៉ាក,លនេះយកមកកសាង មាន ចន-តុល-ខាន់-ភី ជាដើម ។ ប្រមូលយកបូកនិងក,លនៅព្រៃផងបានគ្នា៣០-៤០នាក់ ពេលរដ្ឋប្រហារឆ្នាំ១៩៧០ ខ្ញុំឈរនៅស្រុកចំការលើ រៀបចំក,ទនៅកន្លែងនេះឲ្យទៅស្ទោង១ក្រុម-ទៅសណ្ដោ...១ក្រុម-កំពង់ស្វាយ១ក្រុម-សន្ទុក១ក្រុម-បារាយណ៍១ក្រុម-តាំងគោក១ក្រុម-ចំការលើច្រើនក្រុម-ស្ទឹងត្រង់ច្រើនក្រុម-កំពង់សៀម១ក្រុម-ព្រៃឈរ១ក្រុម -ជើងព្រៃ១ក្រុម ហៅថាប្រដាប់អាវុធឃោសនាផង+រៀបចំរដ្ឋអំណាចឃុំ-ភូមិផង

ខ្ញុំរៀបចំក,លខាងលើបានចប់សព្វគ្រប់ដល់ខែ៧,៧... ខាងលើឲ្យខ្ញុំទៅឈរនៅសៀមរាប ។ មុនខ្ញុំទៅ ខ្ញុំរៀបចំក,ល៦០នាក់ឲ្យទៅមុន ឲ្យទៅរៀបចំរដ្ឋអំណាចឃុំភូមិនៅសៀមរាប ។ ខ្ញុំទៅរួមជាមួយឈ្មោះ សុត ។ សុត ជាអនុរបស់ខ្ញុំ ។

ដើមឆ្នាំ១៩៧២ ខាងភាគ+ខាងមជ្ឈិមឲ្យខ្ញុំមកកំពង់ចាមវិញ ទទួលជាអនុភាគ+ជាប្រធានសេនាធំភូមិភាគ ។ ពេលនោះ

ខ្ញុំចាប់ផ្តើមរៀបចំក,ទ៣ប្រភេទ

១) ក,ទស្រុក ១ស្រុក១អ,ធ (១អធ១២០នាក់)

២) ក,ទតំបន់ ១តំបន់មាន១ទៅ២វ,ត (១វ,ត៣៦០ទៅ ៥០០នាក់)

៣) ក,ទចល័តរបស់ភូមិភាគ រៀបចំបាន១៣វ,ត (១វ,ត ៣៦០ទៅ៥០០នាក់)

**សំគាល់:** ខែ៧,៧០នាក់ អ្នកដ,នទូទាំងប្រទេសមកនៅតំបន់បឹងល្វា។ ខ្ញុំជាអ្នករៀបចំកន្លែងរបស់មជ្ឈិមនេះ ក្រោយបន្តិចមក មកពីតំបន់១៣០ តំបន់ស្ទឹងត្រង់លើ។

ខែ២,៧២ មជ្ឈិមឲ្យខ្ញុំសហការជាមួយកងមជ្ឈិមឈ្មោះកង៣៩ ដ,នដោយបងខៀវ វ៉ៃបោសខ្មាំងជុំវិញកំពង់ធំ។ រៀបចំទ័ពបណ្តើរវ៉ៃបណ្តើរ។ វ៉ៃរំដោះជុំវិញក្រុងជិតអស់ក៏ទៅអត់រួចក៏ហ៊ុំព័ទ្ធចោលទៅ។

ចុង៧២ដើម៧៣ មានប្រត្តិការណ៍អង្គរជ័យចេញពីសៀមរាប ខ្ញុំទៅបញ្ជាវ៉ៃបំបាក់ប្រតិបត្តិការនេះ វ៉ៃហើយខ្ញុំដកមកកំពង់ធំវិញ ខែ៤,៧៣ សម្តេចស,នឲ្យទៅរៀបចំទទួលនៅអង្គរ ទទួលស,នហើយ មកវ៉ៃកំពង់ធំវិញ។

ខែ៧,៧៣ ខ្ញុំរៀបចំក,ទឲ្យចូលផ្លូវលេខ៦ ចូលចន្លោះៗដូចជាចន្លោះបារាយណ៍ ដើងព្រៃ ចន្លោះពីស្គុនទៅព្រែកក្តាម។ ពេលនោះមជ្ឈិមធ្វើសន្និបាតមានផែនការវ៉ៃបោសផ្លូវលេខ៦ ពីព្រែកក្តាមរហូតដល់ស្គុន តាំងគោក-កងមាស-ព្រៃឈរ។ យ វ៉ៃបោសអស់ស្អាត។ ហើយឲ្យខ្ញុំរៀបចំក,ទភូមិភាគ វ៉ៃយកកំពង់ចាមជា២មុខព្រួញ។ កុយ ធួន ១មុខព្រួញ ខ្ញុំ១មុខព្រួញ។ មុខសញ្ញាខ្ញុំវ៉ៃដល់ក្រុង-រោងចក្រតម្បាញដល់បន្ទាយស៊ុប។ តែមុខព្រួញ កុយ ធួន វាអត់វ៉ៃ ហើយវាបើកឲ្យខ្មាំងកេលបុកពីក្រោយ ពីទន្លេបិទទៅវិញ។ យ រំដោះកំពង់ចាមមិនបានក៏ហ៊ុមព័ទ្ធចោលទៅ។

ខែ៩,៧៣ មជ្ឈិមធ្វើសន្និបាតសំរេចវ៉ៃសំរុកទូទាំងប្រទេស។ បែកជាមុខសញ្ញា÷

- ខាងបូព៌ា វ៉ៃផ្លូវលេខ១-មេគុងលើ-មេគុងក្រោម
- ខាងនិរតី វ៉ៃផ្លូវលេខ២ ផ្លូវលេខ៣ ផ្លូវលេខ៤
- ខាងបស្ចិម វ៉ៃពីពាយ័ព្យចន្លោះផ្លូវលេខ៤ ផ្លូវលេខ៥ ទិសភ្នំបាសិត អន្លង់កាន។
- ឧត្តរ ត្រូវយកពាកងពលតូច វ៉ៃរំដោះផ្លូវលេខ... ចូលស,ភូកំណត់ខែ១១។ ពេលវ៉ៃផ្លូវលេខ៥ ខ្ញុំរៀបចំ៣មុខសញ្ញា ពីកើតទន្លេ៤មុខសញ្ញាពីលិចទន្លេ។ វ៉ៃលើកទី១អត់បានសំរេច។ រៀបចំម្តងទៀតទៅវ៉ៃបានសំរេច បោស+កាន់កាប់ផ្លូវលេខ៥ បានកំណាត់ពីផ្សារឧត្តុង្គដល់ទល់មុខភ្នំពេញ ប្រវែង៣០គ.ម។

មុខសញ្ញារបស់ខ្ញុំនេះចូលចុះ តែមុខសញ្ញាផ្សេងចូលអត់ចុះទេ។ យ កាន់កាប់ផ្លូវលេខ៥កំណាត់នេះបានកន្លះខែ ខាងលើសំរេចរៀបចំយកឧត្តុង្គទៀត។ តែខ្ញុំរៀបចំវ៉ៃឧត្តុង្គអត់បានក៏ពិភាក្សាជាមួយបងខៀវទៅវ៉ៃផ្លូវលេខ៤ដោយសហការជាមួយខាងនិរតីផង។ វ៉ៃជិតរំដោះផ្លូវលេខ៤ហើយ ពួកភូមិភាគពិសេសសារភាពខ្មាំង វានាំខ្មាំងមកវ៉ៃយកវិញ។ ពេលនោះ យ ងាកមកវ៉ៃយកឧត្តុង្គបាន។ កាន់កាប់បាន១រយៈ អាកងពល៨០មកពីភ,ពមកវ៉ៃដណ្តើមយកឧត្តុង្គវិញ។ យ វ៉ៃវិញខ្ទេច យកបានរថក្រោះ+កាំភ្លើងធំ គ្រាប់រំសេវរាប់ពាន់តោន។

ពេល យ វ៉ៃបាក់អាកងពល៨០ហើយ បាន កុយ ធួន បើកឲ្យខ្មាំងយកផ្លូវលេខ៦ពីសៀមរាបដល់ដីក្រែង ដល់អញ្ចឹង មជ្ឈិមធ្វើសន្និបាតខែ៧,៧៤សំរេចដកខ្ញុំមកសៀមរាបវិញ មកវ៉ៃការពារអង្គរ។ ខ្ញុំក៏លាឈប់ពីតំណែងសេនាធិការភូមិភាគ ក្នុងទិសដៅការពារអង្គរឲ្យបាន ហើយឲ្យ កុយ ធួន ទៅកាន់ទ័ពដែលខ្ញុំក្តាប់វ៉ៃសំរុកចូលភ្នំពេញ។

ខ្ញុំមកវ៉ៃនៅសៀមរាប ដំបូងវ៉ៃពីខាងលិចកាន់កាប់ចន្លោះពួក+សៀមរាបបាន២៥ថ្ងៃ។ ខ្មាំងវាស្រែកអត់បាយ ដល់វាយបុកវិញថមថយ។

បន្ទាប់មកខ្មាំងវាបើកប្រតិបត្តិការណ៍ ៨០២ បុក យ ប្រតិបត្តិការណ៍នេះបញ្ជាដោយ កុយ ធួន។ តែខ្ញុំវ៉ៃដោយក,ទភាគខ្លះ ក,ទតំបន់ខ្លះ វាបាក់ទៅវិញ។ ហើយនៅសៀមរាបនេះខ្ញុំក៏រៀបចំក,លវ៉ៃផ្តាច់ដែរ នៅពេលដែល យ រៀបចំវ៉ៃផ្តាច់ភ,ព។ ពេលនោះភ,ពក៏ដាច់ សៀមរាបក៏ដាច់។

ពេលរំដោះទូទាំងប្រទេសហើយ ខាងមជ្ឈិមសំរេចដក កុយ ធួន ទៅធ្វើរដ្ឋមន្ត្រីក្រសួងសេ,កិពាណិជ្ជកម្ម។ ក,ទភូមិភាគ

ក៏មជ្ឈិមដកយកទៅទាំងអស់នៅសល់តែ១កងពល គឺកងពល ៣១២ ។ ពេលក៏សំរេចឲ្យខ្ញុំមកនៅកំពង់ចាមវិញ មកទទួលខុសត្រូវ ន,ប យ,ធ សេ,កិ គឺខ្ញុំត្រូវក្តាប់ចំការកៅស៊ូផង ។ ដល់ដកខ្ញុំមកកំពង់ចាម បានបំបែកសៀមរាប+ឧត្តរមានជ័យជាតំបន់៣៥ មជ្ឈិមដ,នផ្ទាល់ ។ ឯភូមិភាគកណ្តាលមានតែកំពង់ចាមខាងលិច កំពង់ធំ ក្រចេះខាងលិច មុខកំពូលខាងត្រើយម្ខាង ។ ចាប់ពីពេលនោះហើយដែលមជ្ឈិមច,តជាភូមិភាគកណ្តាល ។ គណៈភូមិភាគកណ្តាលនេះមានខ្ញុំជាលេខា ស្រេងអនុលេខា-តុលសមាជិក ចនសមាជិក ។ ឯ កុយធួន+ជឿន ទៅភ្នំពេញហើយ ។

ក្នុងខែ...,៧៥ នៅភ,ព មជ្ឈិមមានប្រជុំរៀបចំផ្លាស់ប្តូរមាគ៌ា ។ មាគ៌ាបដិវត្តប្រជាជាតិប្រជាធិបតេយ្យចប់ហើយ ត្រូវរៀបចំមាគ៌ាតទៅទៀត ដោយសំរេចយកមាគ៌ាបដិវត្តសង្គមនិយម ។ រៀបចំមាគ៌ាហើយ សំរេចឲ្យយកមកផ្សាយ ។ ត្រឡប់មកវិញ ខ្ញុំរៀបចំក,បទាំងអស់ជាង៥០០នាក់ មកធ្វើសន្និបាតកណ្តាលក្រុងកំពង់ចាម ផ្សព្វផ្សាយពីការបញ្ចប់មាគ៌ាចាស់ ប,វ ប្រ,ជា ប្រ,ត ហើយចវន្តមាគ៌ាថ្មីគឺមាគ៌ាប,វសង្គមនិយម ។

**សំគាល់:** ពេលមជ្ឈិមប្រជុំរៀបចំមាគ៌ាថ្មីនេះហើយមានការជជែកគ្នា ។ ក្នុងនេះមានការជជែកគ្នាពីការដកប្រ,ជចេញពីក្រុង (គ្រាន់តែជជែក តែប្រ,ជដកចេញពីភ,ពអស់ទៅហើយ) ។ ពេលនោះខ្ញុំលើកមតិថា: យ ដកតែពួកក្អាក់ង៉ាររដ្ឋការអីៗចេញបានហើយ ឯប្រ,ជ យ ទុក ហើយ យ ចាត់ច,តរដ្ឋអំណាចគ្រប់គ្រងទៅ ។ តែក៏មានមតិថា បើធ្វើប៉ុណ្ណឹងគ្រាន់តែជាការប្តូរសេះប៉ុណ្ណោះ ។

បន្ទាប់ពីបានផ្សព្វផ្សាយមាគ៌ាថ្មី គឺមានមាគ៌ាប,វសង្គមនិយមនៅទូទាំងប្រទេស ហើយឆ្នាំ១៩៧៦មជ្ឈិមក៏មានការប្រជុំមួយទៀតនៅវិហារព្រះកែវ ។ ប្រជុំលើកផែនការ៤ឆ្នាំ ។ ខ្លឹមសារផែនការ៤ឆ្នាំនេះអង្គប្រជុំបានឯកភាពគ្នាទាំងស្រុង ។ ខ្លឹមសារផែនការមាន២សំខាន់÷

១) ការពារប្រទេសឲ្យបាន កុំឲ្យយួនយកបាន

២) កសាងប្រទេសឲ្យលឿនតាមល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ

ដើម្បីសំរេចផ,កទាំង២ខាងលើបាន ត្រូវរៀបចំសហករណ៍ដោយយកពិសោធន៍តាមសង្គ្រាម៥ឆ្នាំ ។ អង្គប្រជុំឯកភាពគ្នាទាំងស្រុងអំពីការរៀបចំសហករណ៍នេះ ។ កំណត់រៀបចំសហ-ករណ៍១ ១០០គ្រួសារ បាយរួម ។ ថាធ្វើយ៉ាងនេះទើបមានក,លទ័ពទៅការពារប្រទេស ហើយមានក,លកសាងប្រទេសធ្វើទំនប់ប្រឡាយអីៗបាន ។

ក្នុងពេលជាមួយគ្នានោះក៏មានរៀបចំដ,កបោះពុម្ពលុយដែរ ។ លុយបោះពុម្ពហើយៗ តែដល់ យ ដកដូរអីៗអស់ហើយ ក៏សំរេចថាអត់ចាយលុយវិញ ។

ចាប់ពីពេលនោះមក ខាងការពារប្រទេសក៏រៀបចំក,លកងទ័ពទៅព្រំដែន ខាងក,លប្រទេសក៏រៀបចំសហករណ៍ ។

ដើមឆ្នាំ១៩៧៧វាកើតមានព្រឹត្តិការណ៍បណ្តើរៗ ពេលនោះស្រាប់តែមានដំណឹងចេញពីភ,ពមកវិញ គឺខ្ញុំឃើញមានឯកសារមួយកម្រាស់កូនដៃ ក្នុងនេះគេមានលប់ខ្មៅ១កន្លែងកុំឲ្យខ្ញុំដឹង ។ ដល់ខ្ញុំយកមកអាន ខ្ញុំបញ្ចាំងមើលកន្លែងលុបខ្មៅ មានឈ្មោះ កុយ ធួន ។ ឃើញយ៉ាងនេះ ខ្ញុំក៏ ហៅគណៈភាគមានស្រេង តុល សី មកប្រាប់ ហើយខ្ញុំថា កុំនិយាយរឿយប្រយ័ត្នងាប់ ។

បន្តិចក្រោយមក ក៏មានបញ្ជាពីភ,ពឲ្យមកចាប់ឈ្មោះហោះ ចោទថាសក្តិ៤+ចាប់អាចារ្យវ៉ែន ជាអតីតលោកសង្ឃនៅភ,ពដែល វន វេត កសាង ។ កាលនោះអាចារ្យ វ៉ែនជាលេខាស្រុកព្រែកប្រសប់ ក្រោយមកជាលេខាតំបន់ ។

ចាប់អាចារ្យវ៉ែន+ហោះហើយ គេបានចម្លើយពីហោះ+វ៉ែន ក៏មានឯកសារពី កុយ ធួន ខាងទ័ពផ្ញើមកខ្ញុំទៀត ។ ពេលនោះខ្ញុំកំពុងធ្វើសន្និបាតតំបន់៤១+តំបន់៤២ ។

**បញ្ជាក់:** ភូមិភាគកណ្តាលចែកជា៣តំបន់ តំបន់៤១មានស្រុកព្រៃឈរ-ជើងព្រៃ-កងមាស-កំពង់សៀម ។ តំបន់៤២មានស្រុកតាំងគោក-បារាយណ៍-ស្ទឹងត្រង់-ចំការលើ-ព្រែកប្រសប់ ។ តំបន់៤៣ ស្រុកសន្ទុក-កំពង់ស្វាយ-ស្ទោង ។

ពេលខ្ញុំកំពុងធ្វើសន្និបាតតំបន់៤១ ក៏មាននិរសាពីភ,ពឲ្យខ្ញុំរៀបចំភ្ញៀវទៅទស្សនកិច្ចឯណាៗ ។ ដល់ទៅភ,ពខ្ញុំទៅជួបប៉ុល ពត បងនួនជា ។ ប៉ុល ពត បងនួនជា ក៏បង្ហាញឯកសារ

របស់តំបន់គ្រប់តំបន់ គ្រប់ក្រសួង ហើយចម្លើយវាដាក់ច្បាស់ រកកែមិនរួច ពេលនោះ បងខៀវ ជាប្រធានសន្តិសុខផង ហើយ មានឈ្មោះ ឌុច ផង ។

ឃើញអញ្ចឹងខ្ញុំត្រូវដោះស្រាយក្រសួង ព្រោះក្រសួងវានៅជាប់នឹងខ្ញុំ ។ ខ្ញុំថា "ពិបាកនិយាយណាស់ ព្រោះមិត្តទាំងអស់សុទ្ធតែស្គាប់រស់ជាមួយគ្នា ។ ប៉ុន្តែបើអង្គការដ,នសំរេចហើយ ខ្ញុំមិនដឹងធ្វើម៉េចដែរ" ។ មានអ្នកខ្លះគ្នានៅបំរើឯងតាំងពីឆ្នាំ ១៩៦៨ តែថាសេ.អ៊ី.អាដែរ ។ ខ្ញុំមិនដឹងឆ្លើយយ៉ាងម៉េចក៏ថា "ខ្ញុំបេះតែបញ្ជូនទៅលើហើយ" ។

ដល់ខែ២,៧៧ ឡានសន្តិសុខពីភ,ពមកចាប់ប្រធានក្រសួង មានប្រធានក្រសួងកសិកម្ម-ឧស្សាហកម្ម-ពាណិជ្ជកម្ម សាធារណៈការ ។ ដោយឡែកប្រធានចំការកៅស៊ូ ខ្ញុំអត់ឲ្យដោះស្រាយ ទេព្រោះខ្ញុំទុកជាម៉ែជាឪខ្ញុំហើយ ។ ខ្ញុំឲ្យខាងលើហៅទៅភ,ពផ្ទាល់ទៅ ។ តែប្រធានចំការកៅស៊ូនេះ គាត់ឈ្មោះ តាសាត អត់ទៅ ក៏រត់ចូលព្រៃទៅ ។

ក្នុងឆ្នាំ៧៧ដែរ ឡានសន្តិសុខពីភ,ពមកចាប់គណៈតំបន់៤១ ៥-៦នាក់ ចាប់គណៈតំបន់៤២ ៥-៦នាក់ ចាប់គណៈតំបន់៤៣ ៥-៦នាក់ ។ ចាប់គណៈតំបន់អស់ហើយ ក៏ចាប់មេៗក្រសួងរបស់តំបន់ទៀត ព្រោះតំបន់១ៗសុទ្ធតែមានក្រសួងរបស់ខ្លួន ។

បន្ទាប់មកទៀត ឡានសន្តិសុខភ,ពមកចាប់គណៈបញ្ជាការយ,ធរបស់ភូមិភាគទៀត ។

សរុបក,បតំបន់+ក្រសួងដែលត្រូវចាប់មានចំនួន៥០-៦០នាក់ ។

**បញ្ជាក់:** គណៈតំបន់៣៥ សៀមរាប-ឧត្តរមានជ័យ ក៏ខាងភ,ពមកចាប់ដូចភូមិភាគកណ្តាលដែរ ។

បន្តិចក្រោយមក គឺក្នុងឆ្នាំ៧៧ដែរ រវាងខែ៥ ឡានសន្តិសុខពីភ,ពមកចាប់គណៈស្រុកទៀត ចាប់គ្រប់ស្រុកទាំងអស់ ១ស្រុក ២-៣នាក់ៗ ។ រួចហើយចាប់ប្រធានឃុំខ្លះ (មិនគ្រប់ឃុំទាំងអស់ទេ) ។

ដល់ខែ៦,៧៧ ចប់ការចាប់១វគ្គដំបូងហើយ ។ ពេលនោះនៅសល់តែខ្ញុំ ពេលនោះធ្វើការពិនិត្យនៅភូមិភាគកណ្តាលអស់ ក,ប ។ ខាងលើក៏សំរេចយកក,បពីនិរតីមកដាក់ ។ ខាងលើហៅក,បពីនិរតីមក២០០នាក់ជាង មានកងចាបជាបុគ្គលទី១ ធ្វើការនៅពហុកីឡាដ្ឋាន ។ ពេលនោះខាងលើច,តសរុប+តំបន់៣៥ ភូមិភាគកណ្តាលទៅជាភូមិភាគឧត្តរថ្មី មានខ្ញុំជាលេខា-កងចាប អនុលេខា-តាអានជាសមាជិក ។

ដល់ដំណើរការភូមិភាគឧត្តរថ្មី១រយៈទៅ ក៏មានចម្លើយពីខាងកំពតមកថា ត្រូវចាប់ក,បរបស់កងចាប១ខ្សែទៀត គឺយកក,បរបស់កងចាប១ខ្សែនេះទៅភ,ពវិញទៅ ។ ឯយកបន្តទៅណាទៀតខ្ញុំអត់ដឹងទេ ។

ចាប់ពីពេលនោះមកក៏រៀបចំបំបែកភូមិភាគឧត្តរថ្មីជា២វិញ គឺកងចាបទទួលតំបន់សៀមរាប-ឧត្តរមានជ័យ ឡើងត្រង់ទៅមង្ឃិម ។ ឯខ្ញុំនៅភូមិភាគកណ្តាលវិញដដែល ។

ឯក,បដែលមកពីខាងនិរតីមកភូមិភាគកណ្តាល អ្នកដែលគ្មានជំពាក់ជំពិននឹងចម្លើយក៏នៅ ។ ឯអ្នកដែលជំពាក់ជំពិននឹងចម្លើយគឺដកយកទៅភ,ពវិញ តែអ្នកទាំងនេះក្រោយយួនចូលឃើញនៅរស់ ។

សុំបញ្ជាក់ថា ក,បពីនិរតីដែលល្អគេនៅទើសតឡូវ ឯកសារដែលក៏ល្អគេមកថែមអំបិល ។ អ្នកនេះហើយដែលប៉ះពាល់មហាជនច្រើន ។ ដូចជាមានក,បម្នាក់ឈ្មោះ ទី មកពីកំពតមកធ្វើជាលេខាស្រុកបារាយណ៍ វាបញ្ជាឲ្យចាប់បងប្អូនពីខាងបាក់ស្នាអស់៧០នាក់ជាង ។ ថាចោរព្រៃ ។ ដល់ទៅមើលខ្ញុំស្គាល់មានខ្លះជាអ្នកនាំផ្លូវខ្ញុំពីតស៊ូន,បផង ។ ខ្ញុំសួរបងប្អូនទៅថាគេបេះតែចាប់មិនដឹងអីទេ ។ ខ្ញុំក៏ឲ្យមិត្ត ទី លែងបងប្អូនទាំងអស់នោះវិញ ខ្ញុំចាត់ចែងដាំបាយឲ្យហូប ហើយខ្ញុំធ្វើមិទិញនៅបាក់ស្នា១ថ្ងៃដើម្បីលបលាង ។

ឧទាហរណ៍មួយទៀត លេខាស្រុកសណ្តាន់មកពីខាងនិរតីដែរ មកធ្វើបាបប្រ,ជខ្លាំងណាស់ សុទ្ធតែដុតប្រ,ជក្នុងឡ ។

និយាយរួម ក,បមកពីនិរតីដែលមិនល្អបានធ្វើឲ្យប៉ះពាល់មូលដ្ឋានខាងខ្ញុំខ្លាំងណាស់ ។

ពេលនោះហើយដែលខ្ញុំនិយាយជាមួយនឹងបងខៀវពី៧៩ថា ខ្ញុំអស់តម្រិះសូត្រហើយ ព្រោះគេធ្វើឲ្យប៉ះពាល់មូលដ្ឋានន,បអស់ហើយ ។ ឯកាលពីឆ្នាំ៧៨ខ្ញុំក៏បាននិយាយក្រៅជាមួយ អៀង សារី ដែរថា (តែខ្ញុំអត់ហ៊ាននិយាយជាមួយ

ប៉ុលពតទេ) យើងធ្វើយ៉ាងនេះមិនល្អទេ មានបញ្ហាអីយើងដោះស្រាយយ៉ាងម៉េចៗ អៀង សារី ក៏និយាយរបៀបគេចៗថា មិនដឹងធ្វើម៉េចទេ ហើយកាលមហាបដិវត្តវប្បធម៌ចិនក៏មានបញ្ហាអញ្ចឹងដែរ ។

សរុបឡើងវិញទៅ ខ្ញុំយល់ឃើញថា ប៉ុល ពត ធ្វើខុសគឺតាំងពីឆ្នាំ១៩៧៥មក ។ ពីឆ្នាំ១៩៧៥ ពេលប្តូរមាក៏ថ្មីមក ប្រ,ជអត់បាយ ជំនួយបរទេសអត់ទទួល ធ្វើការសហករណ៍ប៉ះក,ល ។

មានថ្ងៃមួយគេប្រុងធ្វើបាបខ្ញុំ ពេលនោះតាអានមកហើយ ។ គឺនៅទំនប់មួយមកវា ។ ពេលនោះអាប៉ង់វាមកទំនប់មួយមកវាដែរ ។ ដល់ត្រឡប់វិញអាប៉ង់វាឲ្យខ្ញុំជិះឡានវា ហើយវាយកក្រមាបាំងកញ្ចក់ ខ្ញុំសួរវាថាម៉េចអញ្ចឹង? អាប៉ង់វាថា កុំឲ្យគេស្គាល់ ។ ខ្ញុំឃើញមិនស្រួលក៏ត្រៀមកាំភ្លើងខ្លីខ្ញុំដែរ ។ ដល់ស្ពាន់ចុះនោម ស្រាប់តែមានអ្នកយាមមកព័ទ្ធស្វែងក្របី ។ ខ្ញុំក៏សួរទៅអាប៉ង់ទៀតថា ម៉េចបានធ្វើអញ្ចឹង ធ្វើអញ្ចឹងអត់ល្អទេ ។ បានវាសួរខ្ញុំថា ពីស្ពាន់ទៅព្រែកក្តាមមានក,លយាមទេ? ខ្ញុំថាមានរហូត ។ ដល់ឡើងពីស្ពាន់ទៅទៀតក៏ឃើញមានក,លទ័ពយាមរហូតហូរតែតាមផ្លូវ ដល់អញ្ចឹងវាអត់ហ៊ានធ្វើអី ។...។ ពេលទៅដល់ភ្នំពេញ វាថាខ្ញុំដើរកាត់របងលួសបន្លាច្រើនដាន់ ។ ខ្ញុំគិតថា ស្លាប់ហើយពេលនេះ ។ តែវានាំខ្ញុំបានទៅដល់ ប៉ុល ពត ។ ជួប ប៉ុល ពត ខ្ញុំលើកបញ្ហានេះជាមួយ ប៉ុល ពត ប៉ុល ពត អត់មាត់ ។

ពេលបើកមហាសន្និបាតលើកទី៥ នៅពេលសាលសភា ខែ...,៧៨ មុនយួនចូល ពេលកំពុងប្រជុំស្រាប់តែផ្ទើលឈុល ពេលនោះ ចេង អន ថាមានកូនទូកមួយបណ្តែត ដល់ទៅមើលឃើញតែទំកន្ទក់ ។ មហាសន្និបាតក៏បិទ ។ បិទហើយ ប៉ុល ពត ប្រាប់ខ្ញុំកុំអាលទៅ ចាំមើលកុនសិន ។ ខ្ញុំគិតថា យ៉ាងម៉េចអញ្ចេះ ហើយក៏ទៅដេកនៅកន្លែងមជ្ឈិម ។ ស្រាប់តែម៉ោង១រសៀល គេចាប់តាគី+វនវេត ។ រួចហើយ ប៉ុល ពត សួរថា មានឃើញកុនទេ ។ ខ្ញុំស្មានតែកុនមែនទែន ការពិតគឺកុនចាប់តាគី+វនវេតនេះឯង ។ គេចោទ វន វេត ថាត្រូវ+ចិនផង ត្រូវនឹងយួនផង ហើយត្រៀមធ្វើនាយករដ្ឋមន្ត្រី ។

ដល់ពេលយួនចូលហើយមកនៅព្រំដែនហើយ ខ្ញុំដើមដំបូងអត់អីទេ ប៉ុល ពត នៅតែដ,នប្រយុទ្ធ តែទស្សនៈប្រែប្រួលអស់ ប៉ុល ពត ដែលខ្លាំងគឺពី៨៤-៨៥ រហូតមក ។ បើចំពោះខ្ញុំ គាត់ហៅខ្ញុំទៅរបៀបឲ្យឈប់តែម្តង ។

មុនដំបូងច,តគណៈដងរែកមានតា បងខៀវ ខ្ញុំ ។ ខែ១០,៨០ ទៅធ្វើការសំរេចឲ្យខ្ញុំចុះទៅធ្វើការក្នុងវិញ ។ ខែ៦,៨២ ហៅខ្ញុំពីក្នុងមកធ្វើការ ពេលនោះឃើញទឹកចិត្ត ប៉ុល ពត+ខ្ញុំ អត់ប្រែប្រួលទេ ។

ដល់ខែ៩,៨៤ ពេលទៅធ្វើការនៅផ្ទះមូលអូរស្វរស្តីភ្នំក្រវ៉ាញ ខ្ញុំឃើញ ប៉ុល ពត ដូចជាប្រែប្រួលជាមួយខ្ញុំ ។ រាល់ដងពេលទៅធ្វើការអញ្ចឹងតែងហៅខ្ញុំជួបផ្ទាល់ ។ តែលើកនេះហៅតែបងខៀវជួប ។ ពេលធ្វើការចប់ត្រឡប់ទៅវិញ ខ្ញុំចុះទៅក្នុងវិញ ។

ដល់ឆ្នាំ៨៥ ខ្ញុំឡើងមកធ្វើការទៀត ពេលនោះ ប៉ុល ពត រៀបចំឲ្យខ្ញុំដាច់ពីកងទ័ព ។ ពេលនោះនិយាយអីអត់ច្បាស់ ។ ដល់ខ្ញុំសួរទៅថាឲ្យខ្ញុំធ្វើគណៈសមរភូមិរួចហើយខ្ញុំចុះទៅស,ភូចុះទៅដល់ទន្លេពៅហើយស្រាប់តែហៅខ្ញុំឲ្យឡើងមកវិញ ហើយថា ៨៧ឲ្យខ្ញុំទៅខាងកោះកុង ពេលនោះយកខ្ញុំទៅនៅខាងកោះកុង ១ខែ ។ មានថ្ងៃមួយ និរសា ប៉ុល ពត មកហៅខ្ញុំទៅជួប ប៉ុល ពត ។ ប៉ុល ពត ក៏សួរមកខ្ញុំថាមានបញ្ហាអីទេ? ខ្ញុំថាអត់មានបញ្ហាអីទេ គ្រាន់តែឮលាន់ៗយ៉ាងនេះថាខុត្តរនៅតែខ្ញុំ១ៗ ។ តែដល់យួនចូលមក ការឮយ៉ាងនេះស្ងប់ហើយ ។ រួចហើយ និយាយជាមួយខ្ញុំថា បើចង់បោះឆ្នោតធ្វើសភា ថ្ងៃក្រោយឲ្យទិញម៉ាស៊ីនកិនស្រូវកិនយកឈ្នួលថោកៗ ប្រ,ជបោះឆ្នោតឲ្យហើយ ។

ដល់ចុងក្រោយ ប៉ុល ពត មានហៅខ្ញុំមកចូលរួមប្រជុំ អ.ប.តនឹងគេ ។ ពេលនោះខ្ញុំសួរមិត្តយ៉ាន់ថាចង់ជួប ប៉ុល ពត ។ ទៅជួប ប៉ុល ពត ឲ្យ១ម៉ឺនបាត ។ [រ៉ែ ពក]

***(ឯកសារមិនទាន់ចប់សេចក្តី ប៉ុន្តែមិនដឹងថានៅមានសល់ប៉ុន្មានទំព័របន្តទៀត)***

***ដកស្រង់តាំងស្រុងពីឯកសារដើម ដោយៈ***
***សាន់ កល្យាណ***

# ចម្លើយសារភាពនិងទូរលេខមួយចំនួន ដែលទាក់ទងនឹង កែ ពក

◆◆◆ ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧៦ កែ ពក បានផ្ញើទូរលេខ លេខ៩៨ ជូនបងប៉ុល (ចម្លងជូនបងនួន បងខៀវ មន្ទីរឯកសារ) អំពីសភាពការណ៍ខ្មាំង សភាពការណ៍មហាជន និងសភាពការណ៍បង្កបង្កើនផលនៅភូមិភាគឧត្តរ ។ ខ្លឹមសារទូរលេខបានសរសេរថា "...សកម្មភាពខាងលើនេះ ភូមិភាគបានមានវិធានការណែនាំទៅខាងតំបន់ឲ្យយកចិត្តទុកដាក់តាមដានសកម្មភាពនេះ ក្នុងការតាមដានសកម្មភាពនេះទៀត ជាក់ស្តែងយើងចាប់បានពួកសមាសភាពជាអតីតប្រធានក្រុមសហករណ៍ចាស់..." ។

◆◆◆ ចម្លើយសារភាពរបស់ អែម មីន ហៅ សែន កម្មាភិបាលជំនួយស្រុកបារាយណ៍ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧ មានចំណារផ្ញើជូនសមមិត្ត ពក ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៧៧ ។

◆◆◆ ចម្លើយសារភាពលើកទី១របស់ អ៊ុំ អេន ហៅ ហំ ប្រធាននយោបាយវរសេនាធំទី២ កងពល១១៧ កាលបរិច្ឆេទថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៧ មានចំណារជូនសមមិត្តពកមួយច្បាប់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៧ ។ ចម្លើយសារភាពរបស់ អ៊ុំ អេន ហៅ ហំ មានពាក់ព័ន្ធនឹងការស្វែងរកចាប់ខ្មែរក្បត់នៅភូមិភាគឧត្តរ កងពល១១៧ កងពល១៧០ ប្រធានកងពល១៧០ឈ្មោះ ចក្រី អង្គការចាប់ខ្លួនហើយ ប្រធានកងពល៣១០ឈ្មោះ អឿន ក្តាប់មិនបាន ប្រធានកងពល៤៥០ឈ្មោះ សួង ក្តាប់មិនបាន និងតំបន់៤១មួយចំនួនទៀត ។

◆◆◆ ចម្លើយសារភាពរបស់ លី ហាក់ ប្រធានសាលាបច្ចេកទេសឫស្សីកែវ ត្រូវអង្គការចាប់ខ្លួនថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧ មានចំណារជូនសមមិត្តពកមួយច្បាប់ ។ ក្នុងចម្លើយសារភាពរបស់ លី ហាក់ មាននិយាយពីការទាក់ទងដល់ជនក្បត់ចំនួន៤០នាក់នៅភូមិភាគឧត្តរ ។

◆◆◆ ចម្លើយសារភាពរបស់ យង់ ពៅ ប្រធានសន្តិសុខតំបន់១០៦ អំពីផែនការលាក់ទាយទាហានរបស់ ស្រេង នៅភូមិភាគឧត្តរ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៧ ។ បានជូនសមមិត្តពក មួយច្បាប់ ។

◆◆◆ ចម្លើយសារភាពរបស់ ចាន់ ម៉ុន ហៅ តុល តំបន់៤២ ចម្លងតាមខ្សែអាត់ថតសម្លេង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៧ បានឆ្លើយសារភាពថា ពក បាននាំខ្លួន តុល រត់ចូលព្រៃធ្វើបដិវត្តន៍នៅក្នុងឆ្នាំ១៩៦៤-៦៧: "ចាន់ ម៉ុន ហៅ តុល ត្រូវបានបងពកចាត់តាំងឲ្យចូលក្នុងអង្គការបក្សជនខែមិថុនា ឆ្នាំ១៩៦៥ ។ ក្រោយថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧ ដោយនៅក្នុងភូមិភាគឧត្តរមានពួកក្បត់ដូចជា ស្រេង, តុល, ងិន និង តាំង ត្រូវបានចាប់ខ្លួន បងពក បានធ្វើសតិអារម្មណ៍ដល់កម្មាភិបាលនៅក្នុងភូមិភាគ ហើយបងពកបញ្ជាឲ្យ ម៉ុន ខំតាមចាប់ពួកក្បត់ដែលនៅសេសសល់ជាបក្ខពួកក្បត់របស់ឃួន ។...ឈ្មោះ ចន ត្រូវបានបងពកចាត់តាំងឲ្យទៅចាប់ឈ្មោះ អ៊ុន ដែលលួចរត់ពីចម្ការលើទៅព្រែកប្រសប់ ។...ដើមឆ្នាំ១៩៧៧ ដោយអ្នកនៅខាងភូមិភាគបស្ចិមរត់មកនៅភូមិភាគឧត្តរជាបន្តបន្ទាប់ បងពកបានធ្វើការប្រជុំមួយនៅទំនប់១មករា ដើម្បីក្តាប់សភាពការណ៍ បងពកបានចាត់តាំងឲ្យឈ្មោះ ចន ទៅទាក់ទងជាមួយឈ្មោះ សារុន ពីរឿងមនុស្សនៅភូមិភាគបស្ចិមរត់មកនៅភូមិភាគឧត្តរ ។ ដល់ខែឧសភា ឆ្នាំ១៩៧៧ ពក បានចាត់តាំងឲ្យឈ្មោះ ចន ដើរចាប់ពួកក្បត់បន្តទៀត ។ បន្ទាប់មក បងពក បានចុះទៅសៀមរាប ដើម្បីតាមចាប់ពួកក្បត់ និងរៀបចំការចាត់តាំងថ្មីឡើងវិញនៅតាមស្រុកនីមួយៗនៅក្នុងភូមិភាគឧត្តរ ។ នៅខែ

មិថុនា ឆ្នាំ១៩៧៧ បងលេខ១ បានចុះទៅបើកវគ្គរៀនសូត្រ ក៏ចាត់តាំងគណៈភូមិភាគឧត្តរ ដោយចាត់តាំង បងពក ជាលេខា បងសែជាអនុលេខា និង ចនសមាជិក។ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧ បងពកបានផ្ញើសំបុត្រទៅឲ្យ ចន មកធ្វើការនៅកំពង់ចាម។ ពេល ចន មកដល់កំពង់ចាមនៅម៉ោង៤រសៀល ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧ ត្រូវអង្គការចាប់ខ្លួនតែម្តង"។

◆◆◆ ក្នុងចម្លើយសារភាពរបស់ ម៉ៅ ជឿន ហៅ លី ប្រធានភ័ស្តុភារក្នុងកងពល១៧៤ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧ មូលហេតុដែលអង្គការចាប់ខ្លួនដោយសារ ម៉ៅ ជឿន ហៅ លី បានបញ្ជាឲ្យយុទ្ធជន៥នាក់ដាក់មីន និងគ្រាប់បែកប្រហែល១០០គ្រាប់ ដើម្បីកម្ទេចឃ្លាំងគ្រាប់។ ប្រមាណជាម៉ោង៥ល្ងាច ឃ្លាំងគ្រាប់២ត្រូវផ្ទុះឆេះអស់។ ក្រោយមក បងពក បានចុះមកសួរនាំអំពីមូលហេតុឆេះឃ្លាំងគ្រាប់ ហើយនៅវេលាម៉ោង២យប់ អង្គការចាប់ឈ្មោះ ម៉ៅ ជឿន ហៅ លី នេះតែម្តង។

◆◆◆ នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៧ បងពក បានចាត់តាំង ផេង ស៊ន់ ហៅ ជ័យ និងសមមិត្តយើងមួយចំនួនទៀតទៅចូលរួមជប់លៀងអបអរសាទរខួបកំណើតឆ្នាំទី២៨នៃកំណើតប្រទេសចិន តាមការអញ្ជើញពីគ្រៀវចិនផ្នែកបច្ចេកទេសរោងចក្រតម្បាញកំពង់ចាម។ ក្រោយពិធីជប់លៀង បក្សមានវិធានការឃាត់ខ្លួនខ្មែរ សេ.អ៊ី.អា។ ផេង ស៊ន់ ហៅ ជ័យ ត្រូវអង្គការចាប់ខ្លួនថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧។

◆◆◆ ចម្លើយសារភាពរបស់ឈ្មោះ សៀង ផុន ហៅ ផា ជាជំនួយការវរសេនាតូចលេខ ៧០១ កងពល៧១៤ ភូមិភាគកណ្តាល ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៧ "មូលហេតុគឺដោយសារនៅចុងខែធ្នូ ឆ្នាំ១៩៧៦ ផាត្រូវបាន ស៊ី ចាត់តាំងឲ្យទៅការពារ បងពក ក្នុងគោលបំណងដើម្បីបាញ់បងពក"។ មានចំណារមួយចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ជូនភូមិភាគកណ្តាល១ច្បាប់ និងជូនបងនួន១ច្បាប់សំខាន់។

◆◆◆ ចម្លើយសារភាពរបស់ តាំ ចាន់ ហៅ ចន ជាលេខាតំបន់៤៣ ភូមិភាគកណ្តាល ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៧៧ បានសរសេរថាៈ "កាលពីខែកក្កដា ឆ្នាំ១៩៧៥ បងលេខ១ បានចុះទៅធ្វើការចាត់តាំងគណៈភូមិភាគឧត្តរ ដោយចាត់តាំងបងពកជាលេខាភូមិភាគ ស្រេងជាអនុលេខាភូមិភាគ គុលជាសមាជិកអចិន្ត្រៃយ៍ ហើយឈ្មោះ ងិន, ស៊ី និង ចន ជាសមាជិកភូមិភាគឧត្តរ។

◆◆◆ សេចក្តីរាយការណ៍ពីសភាពការណ៍ខ្មាំងនៅស្រុកមុខកំពូល តំបន់២២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ សភាពការណ៍ខ្មាំងនៅស្រុកមុខកំពូលៈ "សូមជួយផ្តល់ដំណឹងទៅខាងភូមិភាគបស្ចិមនិងភូមិភាគកណ្តាលជ្រាបផង ព្រោះខាងយើងខ្ញុំ (តំបន់២២) ចាត់វិធានការហើយ។ អាខ្មាំងនេះពីដើមវានៅព្រៃឈើបួន បច្ចុប្បន្នវាដកទៅនៅកន្ទែងម្ទំពាម ម្ខាងនៅឃុំសំបួរមាស ម្ខាងនៅឃុំព្រៃកតាសេក។ ពួកវាមានគ្នាចំនួន៣០នាក់ មានអាវុធធុនអាកាចំនួន៣ដើម អាអ៊ែ-១៥ចំនួន៤ដើម មួយកន្លែងទៀតមានអាខ្មាំងរត់ពីកើតទៅ មានគ្នាវាចំនួន១២នាក់ មានអាវុធអាកា២ដើម អ៊ឹម-៧៩មួយដើម អាអ៊ែ-១៥ចំនួន២ដើម។ នៅយប់ថ្ងៃទី១៨ខែមីនា ឆ្នាំ១៩៧៨ វាចាប់នារីម្នាក់កុមារម្នាក់នៅលើកោះដាច់។ បានចម្លងជូនបងពកមួយច្បាប់"។

◆◆◆ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ខាង ម.៨៧០ បានជម្រាបថា ខាងភូមិភាគបូព៌ាបានផ្ញើសេចក្តីរាយការណ៍ពីសកម្មភាពខ្មាំងនៅស្រុកមុខកំពូល មួយច្បាប់មកជូនមន្ទីរ ដោយសុំឲ្យមន្ទីរផ្ញើជូនទៅខាងបង៦។ បានផ្ញើជូនបងពកមួយច្បាប់។

◆◆◆ ទូរលេខ លេខ៣២ ខ្ទង់២៩៥ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ សមមិត្ត ពក បានជម្រាបមកគណៈ៨៧០ និងចម្លងជូនអ៊ំនួន មន្ទីរឯកសារៈ "សូមរាយការណ៍ជូនអង្គការៈ ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ វេលាម៉ោង៤រសៀល យោធាតំបន់៤១ បានឃាត់ខ្លួនយុទ្ធជន២នាក់ឈ្មោះ ឆន និងឈ្មោះ រី នៅអង្គភាព៥១២ ខាងជើងអាកាស ស្លៀកពាក់ខោអាវពណ៌គគីប្រដេះ មានម៉ូតូមួយគ្រឿង។ ដោយមូលហេតុគ្មានលិខិតធ្វើដំណើរ និងគ្មានលិខិតសំគាល់ខ្លួន។ តាមការសាកសួរថាធ្វើដំណើរទៅធ្វើយន្តហោះនៅព្រលានវ៉ឺនសៃខេត្តក្រចេះ។ បញ្ហាខាងលើនេះស្នើអង្គការសាកសួរសមមិត្ត ម៉េត ផង។ តើមានឈ្មោះដូចរាយការណ៍ខាងលើទេ? បើមានសុំឲ្យដំណឹងមកទាក់ទងសមមិត្ត

*អាន តំបន់៤១ ទទួលជននេះផង» ។*

*◆◆◆ ទូរលេខ លេខ០៣ ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ សមមិត្ត ពក ជម្រាបមក គណៈ ម.៨៧០ មានចម្លងជូន អ៊ំនួន អ៊ំវ៉ាន់ អ៊ំវ៉ន មន្ទីរឯកសារៈ «អំពីបញ្ហាថ្ងៃមុន ខ្ញុំ (ពក) បានយកបញ្ជី បងវ៉ន និងសំបុត្របងផ្ទាល់ទៅទាក់ទងសមមិត្ត ជឿន យកគ្រាប់កាំភ្លើងតាមបញ្ជីនោះមកសមរភូមិ ហើយគ្រាប់ត្រូវការគឺគ្រាប់កាំភ្លើងអាគេននិងមីនថ្មើរជើង ។ ស្នើអង្គការឲ្យជួយដោះស្រាយគ្រាប់និងមីនថ្មើរជើងឲ្យបានមួយចំនួនថែមទៀត ។ ម្យ៉ាងទៀត សំណូមពរគ្រប់មុខព្រួញពេលបុណ្យខួបត្រូវត្រៀមគ្រាប់ដើម្បីម្ចាស់ការលើសមរភូមិ ។ សូមអង្គការជ្រាបជាព័ត៌មាន ។ បន្ថែមៈ បញ្ហាប្រេងដែលស្តារចេញពីសាទែនរើរៀបចំនោះ តាមមតិអង្គការថាយកទៅផ្ញើនៅក្រចេះនិងបូព៌ា ។ តែបងប្អូនពិនិត្យឃើញថា បើយកទៅផ្ញើនៅក្រចេះនិងបូព៌ា បងប្អូននៅខាងភូមិភាគកណ្តាលពិបាកទៅយក ។ ឥឡូវបងប្អូនកំណត់ដាក់លើកប៉ាល់បណ្តែតទឹកនៅកំពង់ចាមតែម្តង ។ តើអង្គការមានមតិយ៉ាងណា?» ។*

*◆◆◆ ទូរលេខ លេខ០២ ខ្ទង់៦៨០ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ សមមិត្ត ពក បានជម្រាបគណៈ៨៧០ ចម្លងជូនអ៊ំ អ៊ំនួន អ៊ំវ៉ាន់ អ៊ំវ៉ន មន្ទីរឯកសារៈ «រាយការណ៍ពីសមរភូមិផ្លូវជាតិលេខ៧ បន្ថែមនៅសមរភូមិតាមមុខព្រួញនីមួយៗមកប្រជុំធ្វើការនៅសមរភូមិប៉ែកខាងលិចពីព្រែកជ័ររហូតដល់កំពង់រកា ។ នៅសមរភូមិប៉ែកខាងលិចពីព្រែកជ័រមកផ្លូវលេខ២២ រហូតមកដល់ខាងលិចផ្លូវលេខ២២ ត្រង់ចំណុចនេះខ្មាំងក៏វាយកាំភ្លើងធំមកលើយើងដែរ និងមានសភាពអ៊ូរអរ ។ សមរភូមិខាងលិចផ្លូវលេខ២២ចាប់តាំងពីកើតវាលវែងត្រង់ស្ពឹងបំបែកអូរផ្គាវទៅរហូតកំពង់រកា មុខព្រួញនេះខ្មាំងក៏មានការប្រែប្រួល ។ ...នៅថ្ងៃទី១០, ១១, ១២ ខែមេសា ឆ្នាំ១៩៧៨ ខ្មាំងវាយមកលើយើងនៅកំពង់រកា មានថ្មើរជើង រថក្រោះ និងកាំភ្លើងធំ ។ ឯមុខព្រួញកាទុំដែលខ្មាំងរុលក្បាលចូលក្តី យើងនៅតែវាយខ្មាំងបាន ។ យើងវាយរំដោះបានភូមិពីរទាំងស្រុង ហើយកំពុងតាមកម្ទេចខ្មាំងដែលចូលមកភូមិឆ្ងាយទៀត» ។*


សមមិត្ត កែ ពក

*◆◆◆ ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ មានទូរលេខ០៥ របស់សមមិត្ត ពក ជម្រាបមកគណៈ៨៧០ ចម្លងជូន អ៊ំ អ៊ំនួន អ៊ំវ៉ាន់ អ៊ំវ៉ន មន្ទីរឯកសារ ។ ទូរលេខនិយាយអំពី«សភាពការណ៍ខ្មាំងនៅសមរភូមិផ្លូវជាតិលេខ៧ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ នៅសមរភូមិប៉ែកខាងលិច ជារួមខ្មាំងវានៅមុខព្រួញនេះ មិនទាន់ធ្វើសកម្មភាពអ្វីខ្លាំងក្លាមកលើយើងទេ ។ តែមានហេតុភេទប្លែកនៅមុខសញ្ញាផ្លូវលេខ២២ ព្រំប្រទល់ជាប់តំបន់ត្រពាំងផ្លុង ខ្មាំងមានដោតទង់ជាសញ្ញាតែមិនដឹងជាសញ្ញាអ្វីរបស់វាទេ ។ ឯយើងវិញនៅមុខព្រួញខាងលិចនេះ យើងវាយសម្រុកខ្មាំងជាប់តាំងពីព្រលឹមម៉ោង៥ទល់គ្នានឹងម៉ោង៥ល្ងាច តាំងពីកំពង់រកា ស្ពានបន្ទា អូរផ្គាវ តាមជួរខាងកើតអូរស្នោច់ រហូតមកផ្លូវលេខ២២ បន្ទាយ២៧ ចុងពើក ស្វាយញ៉ីរ រហូតខាងកើតព្រែកជ័រ យើងវាយទាំងថ្មើរជើង ទាំងកាំភ្លើងធំ ធ្វើឲ្យខ្មាំងយួនវាភ័យស្លន់ស្លោ ហើយយើងបានកម្ទេចលេណដ្ឋាន និងកម្ទេចកម្លាំងរបស់វាបានមួយចំនួនធំថែមទៀត ។ ឯមុខព្រួញប៉ែកខាងកើតមេមត់ កាទុំ ខ្មាំងវានៅតែបាក់ទ័ពដដែល» ។*

*◆◆◆ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨ មានទូរលេខ០៩ ខ្ទង់៥៨៦ របស់សមមិត្ត ពក ជម្រាបជូនគណៈ៨៧០ ចម្លង*

ជូន អ៊ំ អ៊ំនួន អ៊ំវ៉ាន់ អ៊ំវន មន្ទីរឯកសារ ស្តីអំពីលទ្ធផលថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨ ទាំងសមរភូមិខាងលិចនិងខាងកើត ។ “សមរភូមិប៉ែកខាងលិចយើងវាយរំដោះបានត្រពាំងស្រឡៅទាំងស្រុង ហើយត្រពាំងស្រឡៅនេះនៅប៉ែកខាងលិចផ្លូវលេខ២២ចម្ងាយ៤ឬ៥គីឡូម៉ែត្រ លើខ្សែស្របទី០៣ ខ្សែទទឹង៨៥ ។ យើងកម្ទេចខ្មាំងស្លាប់និងរបួសជាង៥០ក្បាល ខ្មាំងវាបោលខ្មោចនៅនឹងកន្លែង២៧ក្បាល រឹបយកអាវុធនិងសម្ភារមួយចំនួន ។ មុខព្រួញខាងកាទុំ មេមត់ យើងបានវាយរំដោះបានភូមិដាំអំពិល ភូមិលាចលើ ភូមិលាចក្រោម (ឃុំដាំស្រុកមេមត់) ។ ដោយឡែកមុខព្រួញដែលខ្មាំងចេញពីលិចកាទុំវាយមកលើយើងពីខាងត្បូងវាលចង្រ្កាន និងពីវាលចង្រ្កានចេញមកព្រំប្រទល់ដែននៅភូមិព្រៃសាលាលើក្រោម ភូមិប្រកក្រាញ់ ភូមិសូទៃ ភូមិបីខាងលើនេះនៅក្នុងដីវា ឯភូមិសូទៃ (ឃុំរូងស្រុកមេមត់) នៅក្នុងដីយើង ។ យើងបានវាយផ្តក់ទៅលើអាខ្មាំងពីរក្បាល ពីកើតផងនិងពីខាងលិចផង ធ្វើឲ្យវាប្រាសក្បាលចូលទៅក្នុងដីវាវិញ” ។

◆◆◆ ថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៨ មានទូរលេខ១០ ខ្ទង់៣៩៣ របស់សមមិត្ត ពក ជម្រាបជូនមកគណៈ៨៧០ៈ “១) បានមកដល់សមរភូមិល្វាចថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៨ វេលាម៉ោង៦ៈ៣០ និងបានទទួលសំបុត្ររបស់អង្គការហើយ ។ ២) សភាពការណ៍សមរភូមិប៉ែកខាងកាទុំ មេមត់ ខ្មាំងនៅបឹងម្រោងលើនិងបឹងម្រោងក្រោម ជាប់ព្រំប្រទល់យើងគឺបានគាបសង្កត់ជាប់ ។ ៣) នៅសមរភូមិខាងលិចកំពង់រការហូតដល់បន្ទាយ២៧ អូររូង ស្វាយញ័រ ខ្មាំងវាយបកមកលើយើងយ៉ាងខ្លាំងដែរនៅខាងកើតផ្លូវលេខ២២ម្តុំស្វាយញ័រ តែវាយយើងមិនធ្លាយទេ ។ ៤) មុខព្រួញដា ព្រែកជរ អាខ្មាំងវាមានកម្លាំងប្រហែល២វរៈសេនាធំ ហើយកម្លាំងវាថែមមកបន្តបន្ទាប់ ។ ៥) កម្លាំងយើងខ្ញុំបានចេញពីកំពង់ចាមមកដល់ខាងកើតស្នួងហើយនឹងមកជាបន្តបន្ទាប់ ។ បញ្ហាសភាពការណ៍ខាងលើនេះខ្ញុំមានសំណូមពរអង្គការចាត់ចែងបញ្ជូនជំនួយសមមិត្តវិននិងសមមិត្ត យ៉ា បំពាក់អាវុធស្រេច ឲ្យមកជាប្រញាប់ជួបខ្ញុំនៅស្នួងទាំងពីរកង ដើម្បីរួមជាមួយគ្នាព័ទ្ធវាយកម្ទេចខ្មាំង ។ ៦) សុំបញ្ជាក់អង្គការថាៈ បងភឹមគាត់បានលើកវិធានការដោយដកកម្លាំងតំបន់២០មួយកងវរៈសេនាតូច និងកងសមមិត្ត គិមមួយចំនួនទៅវាយខ្មាំងនៅស្អំ” ។

◆◆◆ ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៨ មានទូរលេខ១១ ខ្ទង់៤៧៧ របស់សមមិត្ត ពក “ជម្រាបបងថាៈ ខ្ញុំបានទទួលទូរលេខបងមួយហើយ សុំរាយការណ៍ពីសភាពការណ៍ខ្មាំងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៨ ជូនបងដូចតទៅៈ

សភាពការណ៍ខ្មាំងនៅតាមសមរភូមិផ្លូវជាតិលេខ៧ ទាំងខាងលិចនិងខាងកើត និងសមរភូមិកាទុំ មេមត់ យើងបានវាយខ្មាំងរំដោះបានទឹកដីយើងទាំងស្រុង ហើយខ្មាំងត្រូវស្លាប់និងរបួសមួយចំនួនធំ បាញ់ឆេះរថក្រោះមួយគ្រឿងទៀត ។ ឯយើងវិញ ខ្ញុំ (សមមិត្ត ពក) បានរៀបចំកងភូមិភាគបូព៌ា កងពលទី៤ និងតំបន់២១ សហការគ្នាវាយខ្មាំងនៅបន្ទាយ៧៣៣ បន្តទៀត ។

សមរភូមិខាងលិចពីកំពង់រការមកបន្ទាយ២៧ខ្មាំងវាធ្វើសកម្មភាពមកលើយើងដែរ តែត្រូវបានយើងវាយសម្រុកវាជាប់ធ្វើឲ្យវារុលក្បាលមិនរួចទេ ។

ដោយឡែកខ្មាំងដែលមកតាមផ្លូវលេខ៧ វាមកដល់ភូមិស្អំនៅរសៀលថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៨ កម្លាំងវាមិនធំទេច្រើនបំផុតជាងមួយវរសេនាធំតែប៉ុណ្ណោះ មានរថក្រោះពី៣ទៅ៥គ្រឿង រថក្រោះនេះនៅក្នុងដីវាតាមផ្លូវជាតិលេខ២៧ តែវាមិនហ៊ានមកតាមផ្លូវជាតិលេខ៧ទេ ។ ខ្មាំងមកបានមកពីយើងមិនវាយវា ម្យ៉ាងទៀតអាចមានសមាសភាពក្បត់នាំផ្លូវ ។ ខ្ញុំ (សមមិត្តពក) បានដាក់ទិសវាយពីខាងកើតដោយកង៦០៣ វាយពីលិច ដោយកងភូមិភាគកណ្តាលចាស់លាយថ្មី ចាប់ផ្តើមវាយពីថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៨ នេះបណ្តើរៗ កំណត់វាយធំនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៨” ។

◆◆◆ ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៨ ទូរលេខ លេខ១៣ ខ្ទង់៣៣០ របស់សមមិត្ត ពក ជម្រាបមកគណៈ៨៧០ ចម្លងជូន អ៊ំ អ៊ំនួន អ៊ំវ៉ាន់ អ៊ំវន មន្ទីរឯកសារៈ “ខ្ញុំ (សមមិត្តពក) សុំរាយការណ៍បន្ថែមពីលទ្ធផលកម្ទេចខ្មាំងថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៨ នៅមុខព្រួញសមមិត្តតាតនិងសមមិត្ត វ៉ាន់ ។ មុខព្រួញសមមិត្ត


រូបថតឯកសារៈ ចូសេហ្វ កុហ្វម៉ាន់

គាត មុខព្រួញស្ពានពន្ធា នៅខាងអាគ្នេយ៍ស្ពានពន្ធា យើងវាយអាខ្មាំងធ្វើឲ្យវាស្លាប់និងរបួសមួយចំនួន នៅខាងកើតកំពង់រកា យើងវាយអាខ្មាំងជាប់ កម្លាំងយើងចូលដល់ខាងជើងវាលដីរីស៊ីត្រង់ចំណុច៧៥៣ពីលើ០២៦ បាញ់សម្លាប់អាខ្មាំងចំនួន៥ក្បាល មានផ្កាយពីរចំនួនពីរក្បាល អត់ផ្កាយ៣ក្បាល យកបានអាវុធ AK៥ដើម ឡានហ្ស៊ីបខ្មាំងមួយគ្រឿង។ មុខព្រួញសមមិត្ត វ៉ាន់ យើងវាយកម្ទេចអាខ្មាំងនៅអូរផ្គាវហៅថាស្ពានដែក ស្ពានដែកនេះ យើងរំដោះបានទាំងស្រុងហើយ យើងដេញអាខ្មាំង វាបាក់ទ័ពរត់ខ្ចាត់ខ្ចាយ ហើយយើងកំពុងរៀបចំកម្លាំងវាយដេញវាម្តងទៀត។ ក្នុងការប្រយុទ្ធនេះ យើងរឹបអូសយកបានអាវុធមួយចំនួន ខ្មាំងត្រូវស្លាប់និងរបួសប្រហែល៥០ក្បាល»។

◆◆◆ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៨ ក្នុងចម្លើយសារភាពរបស់ យាង ស៊ីមហន ហៅ ប៊ុត។ ប៊ុត បាននិយាយថា «បងវន បានខ្ទេសនាមឲ្យដឹងថា បងពក (លេខាភូមិភាគកណ្តាល) ជាអនុលេខាបក្សពលករម្នាក់។ ពេល វី ឈើមុនឡើងយន្តហោះ វី បានណែនាំថា «ខ្ញុំទៅនេះមិនដឹងជាយូរប៉ុណ្ណាប់នោះទេ ព្រោះឈឺធ្ងន់មិនទៅកន្លែង មានអីខាងផ្នែក សេ.អ៊ី.អាយើងត្រូវទាក់ទងរាយការណ៍ជូន បងពក មិនបាច់ទាក់ទងជាមួយ បងវន ទេ ព្រោះ បងពក គាត់ទទួលទាំងក្បៀសាននិងទាំងខុត្តរ»។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៨ ពេលទឹកជំនន់ឡើងខ្លាំង ខ្ញុំ (ប៊ុត) បានជូនសំបុត្រមួយទាក់ទងជាមួយ បងពក រាយការណ៍ពីសភាពការណ៍ទឹកជំនន់នេះ និងសួរមតិគាត់តើត្រូវចាក់បណ្តោយ ឬត្រូវមានវិធានការទប់ទល់។ តែខ្ញុំ (ប៊ុត) ឥតបានទទួលចម្លើយពី បងពក ទេ។ បងវន សួររឿងទាក់ទង បងពក ខ្ញុំជម្រាបថា «បានតែសរសេរសំបុត្ររាយការណ៍និងសុំមតិគាត់ម្តងពេលទឹកជំនន់ តែឥតឃើញគាត់ឆ្លើយ»។

**ឡុង ដានី និង ឃួយ វិសាលមុនី**

# តើជាចេតនានៃការសម្លាប់ផ្តាច់ពូជ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?


តឹក សេងអេង

ក្នុងចំណោមអ្នកទោសប្រមាណជាង២មុឺននាក់ដែលត្រូវឃុំឃាំងនិងសម្លាប់នៅមន្ទីរស-២១ មានមួយចំនួនជាកុមារ ។ កុមារទាំងអស់នោះក្លាយជាអ្នកទោសនៅមន្ទីរ ស-២១តាមឪពុកម្តាយដែលត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។ កុមារទាំងអស់ត្រូវបានយកទៅសម្លាប់ចោលជាមួយនឹងឪពុកម្តាយរបស់ខ្លួនដែរ ។ មានពត៌មានមិនទាន់ពិតទាំងស្រុងមួយថា មានកុមារ៧រូបបានរួចផុតពីការសម្លាប់ នៅពេលដែលកងទ័ពវៀតណាមចូលមកកម្ពុជាក្នុងថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ។

គ្រួសារទាំងមូលត្រូវចាប់ខ្លួនព្រមៗគ្នានិងត្រូវសម្លាប់ព្រមៗគ្នាដែរ ។ គ្រួសារខ្លះទៀត សមាជិកនៃគ្រួសារត្រូវចាប់ខ្លួនម្តងម្នាក់ៗជាបន្តបន្ទាប់គ្នា និងយកមកឃុំដោយឡែកៗពីគ្នា ហើយនៅទីបំផុតក៏ត្រូវសម្លាប់ចោលទាំងអស់គ្នា ។ នៅពេលដែលសមាជិកណាម្នាក់នៅក្នុងគ្រួសារមួយបានប្រព្រឹត្តកំហុស សមាជិកផ្សេងទៀតនៃគ្រួសារនោះក៏ត្រូវមានទោសដូចគ្នា ។

ខ្ញុំសូមបង្ហាញជូននូវករណីមួយចំនួនដែលខ្ញុំបានរកឃើញថាសមាជិកក្នុងគ្រួសារទាំងមូលត្រូវបានកម្ទេចទាំងអស់÷

◆◆◆ តឹក សេងអេង ជាកម្មករបច្ចេកទេសផ្លូវដែក និងប្រពន្ធឈ្មោះ ម៉ក់ ណយស៊ីម ព្រមទាំងកូន៦នាក់និងចៅ២នាក់ ត្រូវចាប់មកឃុំឃាំងនៅមន្ទីរ ស-២១ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦ ។ ប្រពន្ធនិងកូនរបស់ តឹក សេងអេង ត្រូវសម្លាប់ជាបន្តបន្ទាប់នៅថ្ងៃទី ២១, ២៥ និង ២៨ ខែឆ្នាំដដែល ។ តឹក សេងអេង ត្រូវកម្មាភិបាលនៅមន្ទីរ ស-២១ សួរចម្លើយអស់រយៈពេល៧ខែ ទើបសម្លាប់ចោលនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ១៩៧៧ ។

◆◆◆ នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៧៧ ធូ ហៃ និងប្រពន្ធឈ្មោះ ហម គ្រាវ ព្រមទាំងកូន៧នាក់ ត្រូវចាប់ខ្លួនបញ្ជូនមកឃុំឃាំងនិងសម្លាប់នៅមន្ទីរ ស-២១ ទាំងអស់គ្នា ។ ធូ ហៃ


អេង រស្មី


តឹក គាំសុី


អេង វុត្ថា


ឡុង ប៊ុតដារ៉ា


ឡុង សុជាតិ


ឡុង ធីនារី

ជាកម្មករអារឈើនៅរោងចក្រ អ-៥ ។ ទោសកំហុសរបស់ ធូ ហៃ គឺ «បំផ្លាញបដិវត្តន៍» ដែលត្រូវបានចាត់ចូលក្នុងប្រភេទជនក្បត់ ។ ប្រពន្ធនិងកូនរបស់ ធូ ហៃ ក៏ត្រូវបានចាត់ចូលក្នុងប្រភេទ «ខ្មាំង» ដូចជា ធូ ហៃ ដែរ ហើយនិងត្រូវទទួលទោសដល់ស្លាប់ដូចគ្នា ។ ឯកសារចម្លើយសារភាពរបស់ ធូ ហៃ ត្រូវបានគណៈមន្ទីរ ស-២១ «ទុកជូនសមមិត្ត ម៉ុក ទំនាក់ទំនងតំបន់២៥និង៣៣ និរតី» ។

◆◆◆ នៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ដែលត្រូវកម្ទេចនៅឆ្នាំ១៩៧៦ មានឈ្មោះមនុស្សចំនួន១២នាក់ ដែលជាឪពុកម្តាយកូននឹងគ្នា ។ ក្រុមគ្រួសារនោះមានឈ្មោះ ÷ ១) ឡុងធិន ជាមេគ្រួសារ ២) ញ៉ែមម៉្វះ ភរិយា ៣) ឡុង សុជាតិ (កូន) ៤) ឡុង ធីនារី (កូន) ៥) ឡុង ធីរ៉ាវុធ (កូន) ៦) ឡុង សេរីរដ្ឋ (កូន) ៧) ឡុង មរកត (កូន) ៨) ឡុង នារី (កូន) ៩) ឡុង វ៉ានីរដ្ឋ (កូន) ១០) ឡុង វីយ៉ាដា (កូន) ១១) ឡុង វត្ថនា (កូន) និង ១២) ឡុង បារមី (កូន) ។

◆◆◆ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧ នុន ហ៊ុយ បានផ្ញើបញ្ជីឈ្មោះចំនួន២គ្រួសារគឺ ស៊្រុន និង ម៉ៃ លន់ ដែលត្រូវកម្ទេច ជូនទៅ ឌុច គណៈមន្ទីរ ស-២១ ។ គ្រួសារទាំងពីរនេះមានសមាជិកសរុបចំនួន១៨នាក់ ។ ឌុច ប្រធានមន្ទីរ ស-២១ បានចារផ្ញើត្រឡប់មក ហ៊ុយ វិញថា «ស្នើសួរ៤នាក់ ក្រៅពីនេះវាយចោល» ។

◆◆◆ ក្នុង«បញ្ជីឈ្មោះអ្នកទោសកម្ទេចផ្នែកបងហ៊ុយស្រែ» ដែលធ្វើនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៧ បានបញ្ជាក់ថា ការកម្ទេចអ្នកទោស«ទាំងអស់ផ្នែកស្រែចំនួន១៧៨នាក់ រួមទាំងកុមារចំនួន១៦០នាក់» ។

◆◆◆ នៅលើបញ្ជីមួយមានចំណងជើងថា «សន្ទេបរបស់អ្នកជាប់និន្ទាការ» មានឈ្មោះមនុស្សចំនួន១៧នាក់ ក្នុងនោះ ៩នាក់ជាកុមារ ដែល ឌុច បានចារនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៨ ថា «ពូប៉េង វាយចោលឲ្យម៉ត់» ។ សរុបកុមារ៩នាក់ ដែលមានឈ្មោះក្នុងបញ្ជីនេះ ត្រូវសម្លាប់ទាំងអស់ ។

នៅក្នុងទស្សនាវដ្តីទង់បដិវត្ត លេខពិសេស ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៨ បានបង្ហាញអំពីទំនាក់ទំនងនៃគំនិតក្បត់បក្សរបស់ឪពុកម្តាយនិងកូនថា «បើឪពុកម្តាយមានធាតុជិះជាន់១០០ កូនមាន៥០» ។ ក្នុងន័យនេះ ខ្មែរក្រហមយល់ថា ប្រសិនបើឪពុកម្តាយមានគំនិតជិះជាន់មនុស្ស (គំនិតសក្តិភូមិ) យ៉ាងហោចណាស់កូនក៏មានគំនិតនេះស្មើនឹងពាក់កណ្តាលឪពុកម្តាយដែរ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោមទ្រឹស្តី «ដកស្មៅត្រូវដកទាំងឫស» ការសម្លាប់ទាំងក្រុមគ្រួសារកើតមានស្ទើរតែនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ។ ឌិន ឌុន អតីតប្រធានយុវជននៅភូមិកល់គម ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ បានឲ្យដឹងថា ក្រុមគ្រួសាររបស់ ព្រំ ចៅស៊ូ អតីតរដ្ឋមន្ត្រីក្រសួងអប់រំក្នុងរបបសាធារណរដ្ឋខ្មែរ ត្រូវបានខ្មែរក្រហមជម្លៀសទៅរស់នៅស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងឆ្នាំ១៩៧៥ ក្រោយមកក៏ត្រូវសម្លាប់អស់មួយគ្រួសារ ។ ចំណែក យ៉ែម គួយ បច្ចុប្បន្នរស់នៅភូមិថ្មី ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ បាននិយាយថា បងប្រុសរបស់គាត់ម្នាក់ដែលជាអតីតប៉ូលិសនៅខេត្តកំពង់ស្ពឺក្នុងរបបសាធារណរដ្ឋខ្មែរ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ព្រមគ្នាជាមួយប្រពន្ធនិងកូនទាំងអស់ ។

រស់ សមណ្ឌរៈវុឌ្ឍិ បច្ចុប្បន្នរស់នៅទីក្រុងភ្នំពេញ បានឲ្យដឹងថា គាត់បានរួចជីវិតដោយសារការរត់គេចខ្លួនទៅរស់នៅកន្លែងផ្សេងមួយទៀតដែលគ្មាននរណាស្គាល់ ចំណែកសមាជិកគ្រួសាររបស់គាត់ដែលរួមមានឪពុកម្តាយនិងបងប្អូនរបស់គាត់ ត្រូវខ្មែរក្រហមសម្លាប់ម្តងមួយៗលុះត្រាតែអស់ ។

តើខ្មែរក្រហមមានចេតនាក្នុងការសម្លាប់បំផុតពូជប្រជាជនខ្មែរ ឬក៏សម្លាប់ខ្មាំងដែលជាជនជាតិខ្មែរ? ផែនការសម្លាប់ទាំងគ្រួសារគឺជាជំហានដំបូងមុននឹងឈានទៅដល់ការបំផ្លាញឲ្យអស់នូវពូជសាសន៍កម្ពុជា ។ ដោយសារពេលវេលាមិនគ្រប់គ្រាន់ (៣ឆ្នាំ ៨ខែ ២០ថ្ងៃ) ទើបធ្វើឲ្យផែនការសម្លាប់ផ្តាច់ពូជសាសន៍កម្ពុជាមិនបានដល់គោលដៅ ។ ប្រសិនបើរបបខ្មែរក្រហមមិនត្រូវរលំរលាយនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទេនោះ ប្រហែលជាប្រទេសកម្ពុជាគ្មានសេសសល់ប្រជាជនខ្មែរណាម្នាក់ក្រៅពីក្រុមគូកនរបស់មេដឹកនាំខ្មែរក្រហមតែប៉ុន្មាននាក់នោះឡើយ ។

**សាន់ កល្យាណ**

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីខាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តពីលេខមុន)

| ល.រ | ល.រទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្តៅនិងជនរងគ្រោះ តាមជាក់ស្តែង | | ទិន្នន័យរណ្តៅនិងជនរងគ្រោះ តាមរបាយការណ៍ | | របាយការណ៍ ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ៣៥៦ | ០៨០៩០១ | ចម្ការស្វាយ | ២០-៥០ | ៣០០-៥០០ | ២០-៥០ | ៣០០-៥០០ | ១៩៩៨ |
| ៣៥៧ | ០៨០៩០៣ | វត្តកាសពព្រះវិហារ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៥៨ | ០៨០៩០៤ | វត្តអង្គសេរីសួស្តី | គ្មាន | ១ម៉ឺន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៥៩ | ០៨០៩០៥ | ប្រឡាយតាប៉ិ | បឹង | គ្មាន | ត្រពាំង២ | ២០០០-៥០០០ | ១៩៩៨ |
| ៣៦០ | ០៨០៩០៦ | ទ្វារទឹក | បឹង២ | ២០០០-៥០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣៦១ | ០៨០៩០៧ | បាសិដ្ឋត្រើយត្រឹង្ស | ?? | ៣០០ | គ្មាន | ជាង៧០០០ | ១៩៩៨ |
| ៣៦២ | ០៨០៩០៨ | ចម្ការស្វាយ | ?? | ៧០០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣៦៣ | ១០០២០១ | អូរលង | ?? | ២០០-៣០០ | គ្មាន | ២០០-៣០០ | ១៩៩៨ |
| ៣៦៤ | ១០០២០២ | វិទ្យាល័យព្រះកុសុមៈ | ?? | ២០០-៣០០ | គ្មាន | ៥០-១០០ | ១៩៩៨ |
| ៣៦៥ | ១០០៣០១ | សាលាស្រុកព្រែកប្រសព្វ | ១ | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៦៦ | ១០០៣០២ | វត្តជ្រោយអំពិល | អណ្តូង | ១០០-១៥០ | អណ្តូង | ១០០-១៥០ | ១៩៩៨ |
| ៣៦៧ | ១០០៤០១ | គោកក្តួច | ១ | ៨៩ | គ្មាន | ៨៩ | ១៩៩៨ |
| ៣៦៨ | ១០០៤០២ | គោកក្តួច | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៦៩ | ១៤០៣០៣ | ត្រពាំងម៉ុង | ១ | ៦០-៧០ | ១ | ៦០-៧០ | ១៩៩៨ |
| ៣៧០ | ១៤០៣០៤ | ត្រពាំងម្លូរថ្មីង | ២ | ១០០-២០០ | ២ | ១០០-១២០ | ១៩៩៨ |
| ៣៧១ | ១៤០៣០៥ | ត្រពាំងត្រាវ | ៣ | ១៥០-២០០ | ៣ | ១៥០-២៥០ | ១៩៩៨ |
| ៣៧២ | ១៤០៥០១ | ទួលដើងចាប | ២ | ១៣៨-១៥០ | ២ | ១៣៨-១៥០ | ១៩៩៨ |
| ៣៧៣ | ១៤០៥០២ | ត្រពាំងចំបក់ | ៣ | ៣៥០-៥០០ | ៤ | ៣៥០-៥០០ | ១៩៩៨ |
| ៣៧៤ | ១៤០៥០៣ | ផ្សារមេសាង | ១ | ១៥០-២០០ | ១ | ១៥០-២០០ | ១៩៩៨ |
| ៣៧៥ | ១៤០៥០៤ | វិទ្យាល័យមេសាង | ៨ | ៣០០-៥២០ | ៨ | ៣០០-៥០០ | ១៩៩៨ |
| ៣៧៦ | ១៤០៦០១ | ទួលពោធិ៍បូរី | ៥០-៧៤ | ៨ពាន់-១ម៉ឺន | ប្រហែល៧៤ | ៨ពាន់-១ម៉ឺន | ១៩៩៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣៧៧ | ១៨០៩០១ | ទួលអ្នកតាស្នាយ | ៣-៥ | ៤០-៥០ | លើសពី៧ | ១២០០០-១៥០០០ | ១៩៩៨ |
| ៣៧៨ | ១៨០៩០៤ | អ្នកតាយ៉ុងយ៉ូយ | ១០០ | ២០០ | ប្រហែល១០០ | ១០០-២៥០ | ១៩៩៨ |
| ៣៧៩ | ១៨០៩០៥ | ត្រពាំងរាំង | ១០៧ | ១៥០-២៥០ | ប្រហែល១០០ | ២០០-២៥០ | ១៩៩៨ |
| ៣៨០ | ១៨១២០១ | វត្តព្រៃស្វា | ៦០ | ៨០០-១៥០០ | ៤២ | ៨០៤ | ១៩៩៨ |
| ៣៨១ | ១៨១២០២ | វិទ្យាល័យព្រែកសណ្តែក | ១៥ | ១០៨៤-២៥០០ | ១០ | ១០៤៨ | ១៩៩៨ |
| ៣៨២ | ១៨១២០៣ | វត្តព្រៃដើមថ្នឹងខាងជើង | ៥ | ៥៦៤-៦៨០ | ៥ | ៦៨០ | ១៩៩៨ |
| ៣៨៣ | ១៨១២០៤ | វត្តព្រៃឈាង | ៤១ | ១២០០-២៥០០ | ៤០ | ១២០០០-២៥០០០ | ១៩៩៨ |
| ៣៨៤ | ១៦០២០១ | ទួលអូរកន្សែង | ២០-៣០ | ៣០០ | គ្មាន | គ្មាន | ១៩៩៨ |
| ៣៨៥ | ១៦០២០២ | គុកអូរកន្សែង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៨៦ | ១៧០៤០១ | វត្តគោកធ្លកលើ | ៤៧ | ៣៥០០០-៣៦០០០ | គ្មាន | ប្រហែល២០០ | ១៩៩៨ |
| ៣៨៧ | ១៧០៤០២ | វត្តគីនិន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៨៨ | ១៧០៤០៣ | ព្រៃប្រាសាទ | ៣ | ៩០-១០០ | ៣ | ២៧០-៣០០ | ១៩៩៨ |
| ៣៨៩ | ១៧០៦០១ | មន្ទីរសន្តិសុខក្រឡាញ់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៩០ | ១៧០៦០២ | ទួលពិឃាតភ្នំទ្រង់បាត្រ | គ្មាន | ៣៥០០០-៣៦០០០ | គ្មាន | ៣៥០០០-៣៦០០០ | ១៩៩៨ |
| ៣៩១ | ១៩០៣០១ | ដាបាំង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៩២ | ១៩០៣០២ | ព្រៃតាបែម | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៩៣ | ១៩០៣០៣ | ទួលខ្មោច | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៩៤ | ១៩០៣០៤ | ចាន់ទុតូច | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣៩៥ | ២១០៤០១ | វត្តព្រះធាតុសួស្តី | ២០០-៣០០ | ៥-៦ពាន់ | ២០០-៣០០ | ១៥០០០-១៧០០០ | ១៩៩៨ |
| ៣៩៦ | ២១០៥០១ | ទួលតាឃ្លោក | ៤០-៤៥ | ២៧៥-២៨០ | ៤០-៥០ | ២៧៥-២៨០ | ១៩៩៨ |
| ៣៩៧ | ២១០៥០២ | ទួលក្រសាំងអែម | ១៥-១៦ | ៧៥-៨០ | ១៥-១៦ | ៧៥-៨០ | ១៩៩៨ |
| ៣៩៨ | ២១០៥០៣ | ព្រៃសុខុន | ៤-៥ | ១០០០-១២០០ | ៤ | ១២០០០-១៥០០០ | ១៩៩៨ |
| ៣៩៩ | ០១០៧០១ | បន្ទាយ | ៤ | ជាង៤០០ | គ្មាន | គ្មាន | ១៩៩៩ |
| ៤០០ | ០១០៧០២ | អណ្តូងសេហ្សដេង | ១ | ជាង៣០០ | គ្មាន | គ្មាន | ១៩៩៩ |
| ៤០១ | ០១០៧០៣ | ត្រពាំងស្នួន | ២ | គ្មាន | ២ | គ្មាន | ១៩៩៩ |

**(នៅមានត)**

◆ តួលេខដែលចុះផ្សាយនៅក្នុងលេខនេះសម្រាប់ខេត្តកណ្តាល ក្រចេះ ព្រៃវែង រតនគិរី សៀមរាប ស្ទឹងត្រែង តាកែវ និងខេត្តបន្ទាយមានជ័យ ។

◆ ចំពោះពត៌មានដែលដាក់ថា "គ្មាន" មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេង ។

◆ ចំពោះពត៌មានជាក់ស្តែងនិងពត៌មានតាមរបាយការណ៍ មានន័យខុសគ្នាត្រង់ថា ពត៌មានជាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍ មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

# លោកទស្សនៈបដិវត្តនិងមិនបដិវត្ត ចំពោះបញ្ហាកសាងគ្រួសារ

## (ទស្សនៈខ្មែរក្រហម)

បញ្ហាកសាងគ្រួសារជាបញ្ហាធម្មជាតិរបស់មនុស្សលោក ។ បើគ្មានការកសាងគ្រួសារក៏សង្គមមនុស្សយើងពុំអាចរីកចម្រើនលូតលាស់ទៅមុខបានដែរ ។ តែបើមានលោកទស្សនៈមិនត្រឹមត្រូវចំពោះបញ្ហានេះទេ នោះក៏ពុំអាចកសាងគ្រួសារបានល្អដែរ ។ ម្ល៉ោះហើយដំណើរជីវិតនៅក្នុងគ្រួសារយើងមុខជានឹងជួបប្រទះវិបត្តិទាំងផ្លូវកាយទាំងផ្លូវចិត្តអស់មួយជីវិត ។ ដូច្នោះយុវជន-យុវនារីបដិវត្តយើងចាំបាច់ត្រូវក្តាប់ ត្រូវយល់ និងមានទស្សនៈគោលជំហរនិងលោកទស្សនៈឲ្យត្រឹមត្រូវចំពោះបញ្ហាកសាងគ្រួសារនេះ ដើម្បីឲ្យដំណើរជីវិតបដិវត្តយើងចេះតែវិវត្តទៅមុខតាមផ្លូវល្អផ្លូវចំរើនលូតលាស់ជានិច្ច ។

### I. *លោកទស្សនៈមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារ*

នៅក្នុងសង្គមចក្រពត្តិសក្តិភូមិនាយទុន និងក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្នសព្វថ្ងៃ គេច្រើនយកបញ្ហាកសាងគ្រួសារទៅភ្ជាប់នឹងផលប្រយោជន៍សេដ្ឋកិច្ច ។ គេយល់ថាទាល់តែមានមូលដ្ឋានសេដ្ឋកិច្ចស្តុកស្តម្ភ ឬមានបុណ្យសក្តិខ្ពង់ខ្ពស់ មានមុខមានមាត់នៅក្នុងសង្គម ទោះត្រូវប្រើមធ្យោបាយឬឧបាយកលខ្មៅងងឹតឧក្រិដ្ឋយ៉ាងណាក៏គេមិនញញើតដែរ ទោះប្រទេសជាតិត្រូវចក្រពត្តិបរិវារយោរយៅរុករានទន្រ្ទានឈ្លានពានយ៉ាងណាក៏គេមិនខ្វល់ដែរ ទោះប្រជាជនរងទុក្ខលំបាកវេទនាយ៉ាងណាក៏គេមិនឈឺឆ្អាលដែរ ។ ពោលគឺគេគិតតែពីសុភមង្គល ពីផលប្រយោជន៍ស្ងួនតួផ្ទាល់គ្រួសារគេតែប៉ុណ្ណោះ ។

មិនត្រឹមតែប៉ុណ្ណោះ ពួកចក្រពត្តិសក្តិភូមិនាយទុនវានៅបានខំឃោសនាអប់រំផ្សព្វផ្សាយជាខ្សែសង្វាក់នូវលោកទស្សនៈខុសឆ្គងនេះឲ្យដល់យុវជន-យុវនារីយើងទៀត ធ្វើឲ្យយុវជនយុវនារីយើងរត់តាមតែផលប្រយោជន៍ស្ងួនតួ លុយកាក់ មាសពេជ្រ បុណ្យស័ក្តិ មុខមាត់ លែងនឹកគិតដល់ជោគវាសនានៃប្រទេសជាតិនិងប្រជាជន លែងមើលឃើញនិងលែងចេះឈឺចាប់នឹងការជិះជាន់ឆក់ប្លន់របស់ពួកវា ។ ដូច្នេះហើយបានជាកាលពីនៅក្នុងសង្គមចាស់មុនពេលរំដោះ និងនៅក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្នសព្វថ្ងៃ យុវជនយុវនារីយើងជាច្រើនដែលជ្រួតជ្រាបនូវលោកទស្សនៈវណ្ណៈជិះជាន់នេះ គេរើសរកគ្រួសារឬកសាងគ្រួសារសុទ្ធតែដើម្បីលាភសក្ការៈផ្ទាល់ខ្លួន ។ ពោលគឺគេស្វែងរកផលប្រយោជន៍ឬសុភមង្គលគ្រួសារដោយផ្តាច់ចេញស្រឡះពីផលប្រយោជន៍ជោគវាសនានៃប្រទេសជាតិនិងប្រជាជនទាំងមូល ។

ឧទាហរណ៍ៈ បើបុរស គេរើសរកប្រពន្ធដែលមានរូបសម្បត្តិល្អ ជាកូនអ្នកមានសម្បត្តិស្តុកស្តម្ភ ឬជាអ្នកមានបណ្តាស័ក្តិខ្ពង់ខ្ពស់ ដើម្បីខ្លួនគេបានឡើងទៅជាអ្នកមាន ឬបានឡើងបុណ្យសក្តិទៅតាមឪពុកម្តាយក្មេក ។

បើនារីឬឪពុកម្តាយកូនស្រីវិញ គេសម្លឹងរកតែអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬអ្នកមានបុណ្យសក្តិ មានប្រាក់ខែច្រើន ដើម្បីការរួចទៅ ខ្លួនគេ កូនគេ បានស្រណុកស្រួល មានមុខមាត់ដោយសារប្តី ។ ទោះបីជានារី-បុរសនោះមានចរិយាមារយាទមានសីលធម៌រស់នៅពុករលួយពាលាអាវាសែយ៉ាងណាក៏គេមិនគិតដែរ ។ ទោះគ្រួសារឪពុកម្តាយក្មេកមានប្រវត្តិក្បត់ជាតិរិបជាន់ឆក់ប្លន់កាប់សម្លាប់ប្រជាជនយ៉ាងណាក៏គេមិនខ្វល់ដែរ ។ ដូច្នេះហើយបានជាមាននារីខ្លះរហូតដល់សុខចិត្តធ្វើប្រពន្ធចុងគេក៏ធ្វើដែរ យកប្តីដែលមានវ័យស្មើនឹងឪពុកឬរហូតជីតាខ្លួនទៀតក៏សុខចិត្តដែរ ឲ្យតែបុរសនោះមានទ្រព្យសម្បត្តិស្តុកស្តម្ភឬមានបុណ្យស័ក្តិខ្ពស់ ។

ដោយមានលោកទស្សនៈខុសឆ្គងយ៉ាងនេះហើយ បានជានៅក្នុងសង្គមចក្រពត្តិសក្តិភូមិនាយទុន គេមិនសូវឃើញមានគ្រួសារណាបានសុខស្រួលនឹងគ្នាទេ ។ រឿងរ៉ាវដ៏អាស្រូវជាច្រើនដូចជា ការទាស់ទែងឈ្លោះប្រកែកគ្នា ការវាយដំប្រំធាក់រវាង

ប្តីនិងប្រពន្ធ ការលែងលះគ្នា ការអស់សង្ឃឹមធ្វើអត្តឃាតចងក ឬបាញ់សម្លាប់ខ្លួនឯង ។ល។ តែងកើតមានឡើងជាហូរហែ ញឹកញាប់ណាស់នៅក្នុងគ្រួសារនីមួយៗ ។

មូលហេតុសំខាន់គឺមកពីគ្រួសារនីមួយៗសុទ្ធតែស្ថិតនៅក្នុងសង្គមជាតិមួយដែលពោរពេញទៅដោយអំពើអយុត្តិធម៌ មនុស្សជិះជាន់មនុស្ស ពោរពេញទៅដោយអំពើអបាយមុខ ពុករលួយពាលាអាវ៉ាសែគ្រប់បែបយ៉ាង ។ ម៉្លោះហើយគ្រួសារនីមួយៗក៏សុទ្ធតែទទួលឥទ្ធិពលអាក្រក់ពីសង្គមជាតិនេះដែរ ។ ដូច្នោះសូម្បីតែនៅក្នុងគ្រួសារតូចមួយក៏គ្មានមនោសញ្ចេតនាស្រលាញ់ស្មោះត្រង់រកគ្នាទៅវិញទៅមកដែរ ។ ម្នាក់ៗគិតតែពីកេងយកចំណេញរកសប្បាយតែរៀងៗខ្លួន ។ នេះចំពោះគ្រួសារអ្នកមានធំ ។ តែចំពោះគ្រួសារអ្នកក្រីក្រវិញនោះរឹតតែលំបាកវេទនាណាស់ទៅទៀត ដោយរងអំពើរិបជាន់ឆក់ប្លន់យ៉ាងសែនធ្ងន់ធ្ងរពីសំណាក់ចក្រពត្តិសក្តិភូមិនាយទុន និងក្នុងតំបន់ខ្លាំងកាន់កាប់បណ្តោះអាសន្នសព្វថ្ងៃ គ្មានគ្រួសារណាអាចស្វែងរកសុភមង្គលផ្ទាល់គ្រួសារតែឯកឯងបានទេ ។

## II. *លោកទស្សនៈបដិវត្តចំពោះបញ្ហាកសាងគ្រួសារ*

ចំពោះយើងជាយុវជនយុវនារីបដិវត្ត យើងទុកបញ្ហាគ្រួសារជាផ្នែកមួយបេះមិនដាច់ពីបញ្ហាប្រទេសជាតិនិងប្រជាជនទាំងមូល ។ បើប្រទេសជាតិត្រូវចក្រពត្តិឈ្លានពាន បើប្រទេសជាតិធ្លាក់ខ្លួនទៅជា«ខ្ញុំគេ» នោះគ្រួសារយើងក៏មានឈ្មោះ«ខ្ញុំគេ»ដែរ ។ បើប្រជាជនយើងត្រូវចក្រពត្តិសក្តិភូមិនាយទុនប្រតិកិរិយាជិះជាន់សង្កត់សង្កិន រងទុក្ខវេទនាឥតត្រើយត្រាណនោះ គ្រួសារយើងក៏នឹងត្រូវទទួលការជិះជាន់ដូចគ្នាដែរ ។ ដូច្នេះដើម្បីឲ្យគ្រួសារយើងស្គាល់សុភមង្គលពិតប្រាកដមានសេចក្តីសុខសាន្តចម្រុងចម្រើនបាន លុះត្រាតែប្រទេសជាតិនិងប្រជាជនយើងទាំងមូលត្រូវបានរំដោះរួចផុតពីការជិះជាន់គ្រប់បែបយ៉ាងរបស់ចក្រពត្តិសក្តិភូមិនាយទុនប្រតិកិរិយាផង ។ ដូច្នេះការកសាងគ្រួសារបដិវត្តយើងគឺមិនមែនគ្រាន់តែដើម្បីផលប្រយោជន៍ស្វួនតួ បានសុខបានសប្បាយ មានកូនមានចៅសម្រាប់បន្តពូជពង្សខ្លួនប៉ុណ្ណោះទេ ។ តែសំខាន់គឺដើម្បីធ្វើបដិវត្តសម្រេចភារកិច្ចដ៏ខ្ពង់ខ្ពស់រំដោះប្រទេសជាតិ ប្រជាជន និងវណ្ណៈក្រីក្រ ហើយឈានទៅកសាងសង្គមនិយមនិងកុម្មុយនិស្តនិយមដែលជាសង្គមគ្មានមនុស្សជិះជាន់មនុស្សទៀត ។

*ក) តើយុវជនយុវនារីបដិវត្តយើងត្រូវរើសគ្រួសារបែបណា?*

ដើម្បីសម្រេចភារកិច្ចបដិវត្តដោយជោគជ័យ ហើយឈានទៅដល់ទិសដៅដ៏ខ្ពង់ខ្ពស់ដូចពោលខាងលើ យុវជនយុវនារីបដិវត្តយើងត្រូវប្រុងប្រយ័ត្នឲ្យមែនទែនក្នុងការជ្រើសរើសគ្រួសារនេះ ។

១) ត្រូវប្រុងប្រយ័ត្នខាងសីលធម៌ស្រីញីប្រុសឈ្មោល កុំសេរីផ្តេសផ្តាសពាសវាលពាសកាល ។ បើមានការអីត្រូវលើកស្នើដល់អង្គការ ដល់សមូហភាពដោយស្មោះត្រង់ ឲ្យជួយដោះស្រាយ ។

២) ត្រូវគោរពអង្គការវិន័យដាច់ខាត ។ ក្នុងបញ្ហាកសាងគ្រួសារនេះ បើអង្គការសមូហភាពពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាងណា ត្រូវគោរពតាមដាច់ខាត កុំទោមនស្ស កុំថ្នាំងថ្នាក់ ។ ព្រោះមានតែអង្គការ មានតែសមូហភាពទេ ដែលអាចពិនិត្យមើលបានម៉ត់ចត់និងគ្រប់ជ្រុងជ្រោយបាន ។ ដូច្នេះកុំអត្តនោម័តិទៅតាមតែមនោសញ្ចេតនាបុគ្គលស្វួនតួ ។

៣) កុំតក់ក្រហល់ ប្រញាប់ប្រញាល់ពេក កុំអន្ទះអន្ទែងតាមតែចិត្តខ្លួននឹកឃើញ ត្រូវពិនិត្យមើលប្រវត្តិរូបឲ្យបានច្បាស់លាស់សិន ។ ពោលគឺត្រូវស្អាតទាំងសីលធម៌រស់នៅស្អាតទាំងខាងនយោបាយ គ្មានជំពាក់ជំពាក់វិននឹងខ្មែរខ្លាំងឬជាមួយពួកសមាសភាពមិនល្អសោះ ។

៤) បើនៅក្នុងជួរដូចគ្នា គឺត្រូវរើសយកអ្នកដែលមានគោលជំហរបដិវត្តរឹងប៉ឹង ទោះជាមិត្តនោះឯងទទួលនាទីជាអ្វីក៏ដោយ ឲ្យតែគេមានគោលជំហរប្រយុទ្ធដាច់ខាត បំពេញភារកិច្ចបដិវត្ត ជូនបក្ស បដិវត្តន៍ និងប្រជាជន បានល្អជានិច្ច ។

ដូច្នេះយើងមិនមែនរើសរកអ្នកណាដែលមានរូបសម្បត្តិល្អបេះស្មៀកពាក់តុបតែងកាយហ៊ឺហាទាន់សម័យចក្រពត្តិ ឬកូនអ្នកមានសម្បត្តិទ្រព្យ ឬជាអ្នកមានសមត្ថភាពវប្បធម៌សង្គមចាស់ខ្ពង់ខ្ពស់ ឬជាអ្នកមានវោហារព្រោកប្រាជ្ញ ឬជាសមមិត្តដែលមានកាំភ្លើងខ្លី កាំភ្លើងវែង ឬមាននាទីតំណែងខ្ពង់ខ្ពស់នោះទេ ។

កន្លងមក នៅក្នុងជួរបដិវត្តន៍យើង មានសមមិត្តខ្លះដែលមិនទាន់ជ្រួតជ្រាបនូវលោកទស្សនៈបដិវត្តចំពោះបញ្ហាកសាងគ្រួសារនេះ ក៏បានកសាងគ្រួសារទៅតាមមនោសញ្ចេតនាអត្តនោម័តិរបស់ខ្លួន ហើយខ្លះទៀតទៅតាមលោកទស្សនៈចាស់ ។

ឧទាហរណ៍ៈ បើសមមិត្តបុរសគឺរើសរកប្រពន្ធដែលមានរូបស ល្អ ស្អាត ឬជាកូនអ្នកមានធនធាន ឬជានារីដែលមានសមត្ថភាពវប្បធម៌សង្គមចាស់ខ្ពង់ខ្ពស់ ។ លុះដល់ការរួច នារីខ្លះក៏ភ្លើតភ្លើនទៅតាមនាទីតំណែងរបស់ប្តី ។

បើយុវនារី គេរើសរកប្តីដែលមានកាំភ្លើងខ្លី ដែលចេះស្លៀកពាក់ហ៊ឺហា ដែលមានវោហារព្រោកប្រាជ្ញ ដែលមានសញ្ញាប័ត្រពីសង្គមចាស់ ឬដែលមាននាទីតំណែងខ្ពស់ក្នុងបដិវត្តន៍ ។ល ។ ដោយឈរលើលោកទស្សនៈខុសឆ្គងយ៉ាងនេះ មិត្តយើងខ្លះកសាងគ្រួសារទៅប៉ះទៅលើសមាសភាពមិនល្អ ដែលជាគ្រោះមហន្តរាយដល់បក្ស បដិវត្តន៍ ក៏ដូចជាចំពោះខ្លួនផ្ទាល់ដែរ ។

*១) ផលវិបាកនៃការកសាងគ្រួសារមិនបានត្រឹមត្រូវ*

ដូចមិត្តយើងជ្រាបស្រាប់ហើយ សព្វថ្ងៃខ្មាំងជាចក្រពត្តិអាមេរិកនិងបរិវារក្បត់ជាតិ ខ្មាំងជាសក្តិភូមិនាយទុនប្រតិកិរិយាវាកំពុងត្រូវបរាជ័យធ្ងន់ធ្ងរលើគ្រប់វិស័យ គ្មានពេលណាងើបមុខរួចឡើយ ។ វាវាយយើងខាងយោធាក៏ចាញ់ ។ វាលេងយើងតាមខាងសេដ្ឋកិច្ចក៏បរាជ័យទៀត ។ ដូច្នេះវាវាយយើងពីក្រៅមិនបែកសោះ ។ ម្ល៉ោះហើយខ្មាំង ទាំងខ្មាំងជាយុទ្ធសាស្ត្រ ទាំងខ្មាំងជាយុទ្ធវិធី ទាំងខ្មាំងវណ្ណៈ ដែលរស់នៅក្នុងតំបន់រំដោះនៅឡើយ វាមានឧបាយកលចង់វាយយើងពីក្នុងពោះវៀនយើងទៅវិញ ដោយបញ្ចូលគ្នាវាមកស៊ីរូងបំផ្លិចបំផ្លាញនៅក្នុងជួរយើងតែម្តង ដោយទាក់ទាញឲ្យកូនឲ្យចៅភ្ជាប់ជាសាច់ញាតិ ហើយអូសទាញតាមមនោសញ្ចេតនាគ្រួសារ ញុះញង់បំបែកបំបាក់យើងពីបដិវត្តន៍ ឲ្យប្រឆាំងនឹងបដិវត្តន៍ ឬឲ្យក្បត់នឹងផលប្រយោជន៍បដិវត្តន៍និងប្រជាជន ទៅបម្រើផលប្រយោជន៍គ្រួសារគេ ការពារវណ្ណៈគេទៅវិញ ។ល ។

នេះជាសភាពពិតជាក់ស្តែងដែលខ្មាំងគ្រប់ប្រភេទវាកំពុងមមាញឹកគ្រោងឧបាយកលធ្វើនៅក្នុងជួរបដិវត្តន៍យើងនិងក្នុងតំបន់រំដោះយើង ។ ដូច្នេះ មិត្តយុវជនយុវនារីយើងត្រូវចាប់អារម្មណ៍ហើយប្រុងប្រយ័ត្នឲ្យមែនទែនចំពោះបញ្ហាកសាងគ្រួសារនេះ ។ បើសិនជាយើងមិនគោរពអង្គការវិន័យ មិនគោរពសមូហភាព មិនប្រកាន់គោលជំហរបដិវត្តរឹងប៉ឹង ហើយសេរីខាងសីលធម៌ពាសវាលពាសកាល នោះមុខជាកសាងគ្រួសារមិនបានត្រឹមត្រូវល្អតាមគន្លងមាគ៌ាបដិវត្តយើងឡើយ នោះមុខជានឹងប៉ះទៅលើសមាសភាពមិនល្អ ឬរហូតដល់ប៉ះទៅលើភ្នាក់ងារបង្កប់របស់ខ្មាំងទៀតក៏មាន ។

ឧទាហរណ៍ៈ នៅកន្លែងខ្លះ មិត្តយើងកាន់រដ្ឋអំណាច ហើយទៅការជាមួយកូននាយទុនឬសក្តិភូមិម្ចាស់ដី ។ ដល់វាបញ្ចុកបន្ស៊ីអូសទាញតាមមនោសញ្ចេតនាគ្រួសារទៅ មិត្តយើងក៏ទោរទន់ទៅខាងវា ហើយរវាតពីគោលជំហរបដិវត្ត ។ ពេលមានទំនាស់រវាងមាគ៌ាបក្សនិងផលប្រយោជន៍ពួកសក្តិភូមិម្ចាស់ដីឬនាយទុន មិត្តយើងមុខជាអនុគ្រោះឲ្យពួកវាបើមិនច្រើនក៏តិចដែរ ហើយសុខចិត្តរំលោភលើមាគ៌ាបក្សខ្លះហើយ ។

ឧទាហរណ៍១ទៀតៈ នៅកន្លែងមួយនោះ ខ្មាំងវាបញ្ចូលចារនារីរូបស្អាតម្នាក់ឲ្យមកតាមចែចង់ផ្ទាប់ផ្ទួនកម្មាភិបាលយោធាយើង ។ ដោយមិត្តនោះសេរីខាងសីលធម៌ ក៏លួចស្រលាញ់គ្នាដោយមិនឲ្យអង្គការសមូហភាពដឹង ។ ក្រោយមកដោយឃើញថាមិត្តយើងស្រលាញ់វាស៊ប់ហើយ វាក៏ចាប់ផ្តើមញុះញង់ចាក់រុកអុជអាលប្តី បំផុសពាក្យចចាមអារ៉ាមវាយប្រហារយោធាវាយប្រហារកម្មាភិបាលផ្សេងៗ វាយបំបែកពីអង្គភាពមួយទៅអង្គភាពមួយមិនចេះចប់ ។ ដោយមិនដឹងខ្លួន មិត្តនោះជឿតាមវា ហើយក៏ចេះតែយកពាក្យចចាមអារ៉ាមដែលវាប្រឌិតទៅនិយាយផ្សព្វផ្សាយតៗគ្នា ធ្វើឲ្យមានការប្របូកប្របល់ក្នុងយោធា រហូតដល់ធ្វើឲ្យសាមគ្គីភាពឯកភាពផ្ទៃក្នុងយោធាឬរវាងយោធានិងអង្គការមូលដ្ឋាន មានការប្រេះឆាទៀត ។ លុះដល់អង្គការរកដើមហេតុមិនឃើញ វាក៏អូសទាញនាំមិត្តយើងជិះរត់ទៅចូលខ្មាំងបាត់ ។

រឿងរ៉ាវបែបនេះសុទ្ធតែធ្លាប់កើតមានឡើងជាហូរហែដែរ នៅក្នុងអង្គភាពយោធាក៏មាន នៅក្នុងជួររដ្ឋអំណាចក៏មាន នៅក្នុងអង្គការយុវជនយុវនារីក៏មាន ។

បច្ច័យអាក្រក់ដែលបណ្តាលមកពីការកសាងគ្រួសារដោយសេរី មិនគោរពអង្គការវិន័យ មិនប្រកាន់គោលជំហរបដិវត្ត មានច្រើនបែបច្រើនយ៉ាងណាស់ ហើយសុទ្ធតែនាំឲ្យមានគ្រោះមហន្តរាយដល់បក្ស ដល់ចលនាបដិវត្ត និងដល់ខ្លួនទាំងអស់ ។ បើកសាងគ្រួសារប៉ះទៅលើសមាសភាពមិនល្អ យ៉ាងហោចណាស់ក៏វាអូសទាញឲ្យយើងអសកម្មក្នុងភារកិច្ចបដិវត្តដែរ ។ ខ្លះទៀតរហូតដល់សុំចេញពីបក្ស ចេញពីចលនាបដិវត្តដែលកំពុងតែផុលផុស គគ្រឹកគគ្រេង និងដណ្តើមបានជ័យជំនះយ៉ាងធំសម្បើម ។ ដូច្នេះអនាគតរបស់ខ្លួនគឺពិតជាឈានទៅកាន់ភាពងងឹតសូន្យសុងគ្មានពន្លឺរស្មីអ្វីឡើយ ។

*ក) ទស្សនៈកសាងអប់រំគ្រួសារក្រោយពេលដែលការរួចហើយ*

យើងត្រូវមានទស្សនៈឲ្យច្បាស់លាស់ថា គ្រួសារយើងជាផ្នែកមួយបេះមិនដាច់ពីមហាគ្រួសារបដិវត្តន៍ ។ ដូច្នេះ ប្តីប្រពន្ធយើងក៏ជាមហាជនម្នាក់របស់បក្ស ជាសមាជិកម្នាក់នៃចលនាបដិវត្តន៍ដែរ ។ ដើម្បីឲ្យគ្រួសារយើងបានទៅជាគ្រួសារបដិវត្តល្អ អាចបំពេញភារកិច្ចបដិវត្តជូនបក្ស ជូនបដិវត្តន៍ និងប្រជាជន បានល្អជារៀងរហូតទៅ ចាំបាច់ត្រូវអប់រំកសាងគេឲ្យយល់នូវមាគ៌ានយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ជាបណ្តើរៗ ។ កុំទុកគេចោលទុកគ្រាន់តែដាំបាយ មើលកូនមើលផ្ទះ ដូចតែគ្រួសារនៅក្នុងសង្គមចាស់ទៀត ។ ម្យ៉ាងយើងជាប្តីត្រូវយកចិត្តទុកដាក់ឃោសនាអប់រំកសាងគេទៅតាមគន្លងមាគ៌ារបស់បក្ស តែសំខាន់បំផុតគឺត្រូវប្រគល់គេជូនអង្គការ ជូនសមូហភាព ជួយអប់រំកសាង ។ ពោលគឺត្រូវឲ្យគេចុះប្រឡូកធ្វើការងារពលកម្មជាមួយប្រជាជន មហាជន ដើម្បីកសាងខ្លួនក្នុងចលនាក្តៅ ។

ត្រូវចៀសវាងដាច់ខាតកុំទំរើសគ្រួសារមិនហ៊ានឲ្យចុះប្រឡូកធ្វើពលកម្មជាមួយមហាជនដោយខ្លាចហត់នឿយ ខ្លាចថោកទាប ខ្លាចបាក់មុខបាក់មាត់ ឬកុំចាត់ទុកគ្រួសារខ្លួនជាមហាជនពិសេសម្នាក់ដែលមានតែខ្លួនទេទើបអប់រំកសាងបាន ។ យើងត្រូវចៀសវាងដាច់ខាតកុំកសាងអប់រំគ្រួសារទៅតាមតែមនោសញ្ចេតនាបុគ្គលស្ងួនគួររបស់ខ្លួនឲ្យសោះ ។ តាមពិសោធន៍ជាហូរហែកន្លងមកឃើញថា ការកសាងអប់រំគ្រួសារក្នុងក្របខ័ណ្ឌរួញក្តោបតែក្នុងគ្រួសារឯង មិនសូវបានចម្រើនទេ ។ មានតែការប្រគល់គ្រួសារជូនអង្គការ ជូនសមូហភាព ជួយអប់រំកសាង និងឲ្យចុះប្រឡូកក្នុងចលនាមហាជនទេ ទើបអាចកសាងគ្រួសារយើងបានល្អ បានចម្រើនទៅតាមទិសរបស់បក្ស ។

បើយើងបានគេជាគ្រួសារហើយតែទុកគេចោល មិនអប់រំកសាងគេឲ្យយល់ដឹងបដិវត្តន៍ផង ឬក៏អប់រំទំរើសគេទៅតាមមនោសញ្ចេតនាគ្រួសារនិយមបុគ្គលស្ងួនគួនិយមនោះ នារីខ្លះកាលនៅជាមួយឪពុកម្តាយជួនកាលល្អទេ តែដល់បានមកធ្វើជាគ្រួសារយើងទៅជាភ្លើតភ្លើនឡើងចាងតាមនាទីតំណែងរបស់ប្តីរបៀបប្រពន្ធនាម៉ឺនក្នុងសង្គមចាស់ ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់ឥទ្ធិពលបក្ស បដិវត្តន៍ និងដល់ឥទ្ធិពលនៃបុគ្គលខ្លួនជាប្តី ធ្វើឲ្យប្រជាជនមហាជនបាត់ជំនឿ ឬគ្មានការកក់ក្តៅលើការដឹកនាំរបស់យើង ។

ដូច្នេះ យុវជនយុវនារីបដិវត្តយើងត្រូវក្តាប់ទិសនិងទស្សនៈអប់រំកសាងគ្រួសារនេះរបស់បក្សឲ្យជាប់ ។

## III. *ភារកិច្ចរបស់យុវជនយុវនារីបដិវត្ត និងបញ្ហាកសាងគ្រួសារ*

ចំពោះបញ្ហាកសាងគ្រួសារនេះ បក្សមិនដែលហាមឃាត់ទេ តែយុវជនយុវនារីបដិវត្តយើងត្រូវមានលោកទស្សនៈបដិវត្តច្បាស់លាស់ចំពោះបញ្ហានេះ ។ ហើយសំខាន់បំផុត យុវជនយុវនារីបដិវត្តយើងត្រូវក្តាប់ឲ្យជាប់នូវភារកិច្ចបដិវត្តន៍ដ៏ធ្ងន់ធ្ងររបស់យើង ឃើញឲ្យច្បាស់នូវភាពរុងរឿងខ្ពង់ខ្ពស់នៃភារកិច្ចយើង និងយល់ឲ្យច្បាស់ថាជាកិត្តិយសថ្លៃថ្នូររបស់យុវជនយុវនារីបដិវត្តន៍យើងដែលត្រូវបានបក្សមានទំនុកចិត្តប្រគល់ភារកិច្ចបដិវត្តដ៏ធ្ងន់ធ្ងរតែរុងរឿងខ្ពង់ខ្ពស់នេះមកឲ្យយើងរាល់គ្នា ។

ដូចមិត្តយើងរាល់គ្នាជ្រាបស្រាប់ហើយ បក្សកុម្មុយនិស្តកម្ពុជាបាននិងកំពុងតែដឹកនាំប្រជាជាតិប្រជាជននិងយុវជនយុវនារីយើងធ្វើបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ វាយបណ្តេញចក្រពត្តិ អាមេរិកបរិវារ និងវាយរំលំពួកអាក្បត់ លន់ណុល សិរិមតៈ សឺងង៉ុកថាញ់ អ៊ិនតាំ ដែលជាតំណាងសក្តិភូមិនាយទុនប្រតិកិរិយា បរិវារចក្រពត្តិអាមេរិក ឲ្យរលំរលាយសាបសូន្យអស់ពីកម្ពុជា រួចហើយឈានទៅកសាងសង្គមនិយម

និងកុម្មុយនិស្តនិយមទៀត ដែលជាសង្គមគ្មានមនុស្សជិះជាន់មនុស្ស ។ ដូច្នេះ បដិវត្តន៍យើងនៅត្រូវធ្វើយូរជាបន្តទៅទៀត ។ យុវជនយុវនារីយើងមានភារកិច្ចបន្តវេនធ្វើបដិវត្តន៍នេះបន្តពីរៀមច្បងជំនាន់នេះ រហូតដល់សម្រេចទិសដៅជាយុទ្ធសាស្ត្រទីចុងបំផុត ។ ដូច្នេះយុវជនយុវនារីយើងចាំបាច់ត្រូវត្រៀមរៀបចំខ្លួនតាំងពីឥឡូវនេះទៅ ដើម្បីទទួលបន្តវេនធ្វើបដិវត្តន៍ ដឹកនាំបដិវត្តន៍ និងកសាងប្រទេសជាតិទៅមុខទៀត ។ ពិសេសត្រូវខិតខំហ៊ឹកហ៊ឺនលត់ដំខ្លួនក្នុងគ្រប់កិច្ចការងារបដិវត្តទាន់ខ្លួននៅក្មេង កម្លាំងនៅមាន ដើម្បីកសាងពង្រឹងពង្រីកគោលជំហរបដិវត្តខ្លួនលើគ្រប់ផ្នែក ទាំងខាងនយោបាយ សតិអារម្មណ៍ ទាំងខាងចាត់តាំងឲ្យបានកាន់តែរឹងប៉ឹងឡើងជាលំដាប់ ដើម្បីធានានិងធ្វើឲ្យអនាគតបដិវត្តន៍យើងនៅតែក្រហមឆ្អិនឆ្អៅ និងកាន់តែក្រហមឆ្អិនឆ្អៅឡើងជារៀងរហូតទៅ ។

សព្វថ្ងៃ ពិសេសនៅរដូវប្រាំងនេះ បក្សកុម្មុយនិស្តកម្ពុជាកំពុងតែដឹកនាំប្រជាជាតិប្រជាជននិងយុវជនយុវនារីយើងទាំងមូល វាយសំរុកខ្លាំងយ៉ាងខ្លាំងក្លាបំផុត និងមានលក្ខណៈជាប្រវត្តិសាស្ត្រផង ។ ពោលគឺ នៅសមរភូមិមុខយើងវាយសំរុកខ្លាំងឲ្យខ្លាំងក្លាបំផុត ធ្វើឲ្យវាកាន់តែរលំរលាយខ្លាំងថែមទៀត រហូតដល់រលំរលាយទាំងស្រុងតែម្តង ។ នៅសមរភូមិក្រោយ យើងត្រូវសម្រុកឲ្យខ្លាំងក្លាបំផុតនិងសកម្មបំផុត បង្កបង្កើនផលកែប្រែជីវភាពប្រជាជនមូលដ្ឋាននិងពង្រឹងពង្រីកចលនាសហករណ៍ភាវូបនីយកម្ម ។ ទន្ទឹមនឹងនេះ យើងត្រូវជំរុញឲ្យខ្លាំងនិងឲ្យសកម្មបំផុតនូវចលនាកសាងកម្លាំងបដិវត្តគ្រប់ផ្នែក ពិសេសកសាងពង្រឹងពង្រីកសម្ព័ន្ធយុវកកយើង ដែលជាផ្នែកមួយសំខាន់នៃកម្លាំងសម្ព័ន្ធភាពកម្មករកសិករឲ្យកាន់តែរឹងមាំឡើងសមស្របនឹងឋានៈជាដៃស្តាំរបស់បក្ស ។

នេះជាឱកាសល្អប្រសើរបំផុតសម្រាប់ជនបដិវត្តយើងគ្រប់រូប ពិសេសយុវជនយុវនារីយើង ចុះប្រឡូកហ៊ឹកហ៊ឺនលត់ដំកសាងខ្លួនក្នុងចលនាក្តៅធំបីនេះ ។ ដូច្នេះ យុវជនយុវនារីយើងត្រូវកម្ចាត់ចោលចេញឲ្យអស់និងឲ្យជ្រះស្រឡះនូវទស្សនៈគោលជំហរខុសឆ្គងទាំងអម្បាលម៉ាន និងលោកទស្សនៈមិនបដិវត្តទាំងអស់ចំពោះបញ្ហាកសាងគ្រួសារនេះ ដូចជាសេរីខាងសីលធម៌ តក់ក្រហល់អន្ទះអន្ទែង ឬរវើរវាយ ចង់កសាងគ្រួសារពីក្មេងពេក ឬសេរីមិនគោរពអង្គការវិន័យ មិនគោរពមតិសមូហភាពក្នុងការកសាងគ្រួសារជាដើម ។ យើងត្រូវយល់ថាបញ្ហាគ្រួសារយើងចង់កសាងពេលណាក៏បានដែរ ។ តែវ័យយុវភាពយើងមានតែម្តងគត់ក្នុងមួយជីវិតរបស់យើង ។ តែយើងបណ្តែតបណ្តោយឲ្យវាកន្លងផុតទៅដោយឥតប្រយោជន៍ហើយ វាគ្មានពេលណានឹងវិលត្រឡប់មកវិញបានទេ ហើយយើងមុខជានឹងស្តាយក្រោយមិនខានឡើយ ។

ដូច្នេះ សូមមិត្តយុវជនយុវនារី បដិវត្តយើងឆក់ឱកាសល្អកម្រមាននេះ ចូលប្រឡូកលត់ដំកសាងខ្លួនក្នុងចលនា វាយសម្រុកធំបីក្នុងរដូវប្រាំងនេះ ដើម្បីសម្រេចភារកិច្ចដ៏ឧត្តុង្គឧត្តមនារដូវប្រាំងនេះ និងតទៅអនាគតទៀត ជូនបក្ស បដិវត្តន៍ និងប្រជាជនឲ្យបានជោគជ័យជាអតិបរមា ។

## ប្រវត្តិរូបសង្ខេបរបស់ កែ ពក

ឈ្មោះដើមៈ កែ វិន

ឈ្មោះបដិវត្តៈ កែ ពក

បុគ្គលិកលក្ខណៈ មាឌធំ សម្បុរខ្មៅ

ស្រុកកំណើតៈ ស្រុកចំការលើ ខេត្តកំពង់ចាម

ឆ្នាំកំណើតៈ ១៩៣៤

ស្លាប់នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០២

ប្រពន្ធឈ្មោះៈ សឿន (មានកូន៦នាក់)

## ពាក្យស្លោកខ្មែរក្រហម

◆ **បន្តពង្រឹងពង្រីកគោលជំហរតស៊ូយូរអង្វែង ទ្រាំទ្រលំបាកវេទនានិងគោលជំហរវាយសំរុកដាច់ខាត ដើម្បីដណ្តើមជ័យជំនះគ្រប់បែបយ៉ាង។** *(កំណត់ហេតុលេខ១៣៥)*

◆ **ប្រុងប្រយ័ត្នពង្រឹងពង្រីកមហាសាមគ្គីបាពឯកភាពផ្ទៃក្នុងបក្សឱ្យផូរផង់ជានិច្ច។** *(កំណត់ហេតុលេខ១៣៥)*



សមមិត្ត ខៀវ សំផន

សមមិត្ត នួន ជា
ប្រធានសភាតំណាងប្រជាជនកម្ពុជា
នៃកម្ពុជាប្រជាធិបតេយ្យ

សមមិត្ត ប៉ុល ពត

# ការបោះឆ្នោតនៅកម្ពុជាក្នុងឆ្នាំ១៩៧៦

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ខ្មែរក្រហមបានបើកអង្គប្រជុំការងារមូលដ្ឋានមួយ ដោយមានការចូលរួមពីសមមិត្តលេខា (ប៉ុល ពត) សមមិត្តអនុលេខា (នួន ជា) សមមិត្តហែម (ខៀវ សំផន) សមមិត្តឌឿន សមមិត្តស្រេង សមមិត្តហង់ សមមិត្តសុត និងសមមិត្តទូច ។ របៀបវារៈនៃការប្រជុំនេះស្តីអំពីបញ្ហាបោះឆ្នោតថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ និងសភាពការណ៍នៅខត្តរ (មន្ទីរ) ១០៩ និង ១០៣ ។

បញ្ហាបោះឆ្នោតនេះ សមមិត្តហែមបានរាយការណ៍ជូនមូលដ្ឋានអំពីគោលការណ៍នៃការបោះឆ្នោតថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ សំណូមពរនៃការបោះឆ្នោត វិធីបោះឆ្នោត លក្ខណៈផ្សេងៗដើម្បីឈរឈ្មោះជាតំណាង និងវិធីអប់រំឃោសនា ។

នៅពេលជាមួយគ្នានេះដែរ មតិបញ្ជាក់បន្ថែមរបស់អង្គការបានសង្កត់ធ្ងន់លើន័យនយោបាយនៃការបោះឆ្នោត វិធីដំណើរការនៃការបោះឆ្នោតសភាតំណាងប្រជាជន និងការឃោសនាអប់រំ ។ អង្គការបានលើកឡើងថា «ពីមុនមានរដ្ឋធម្មនុញ្ញពីរគឺធម្មនុញ្ញឆ្នាំ១៩៤៧មួយដែលជាធម្មនុញ្ញរបស់ស្តេច និងរដ្ឋធម្មនុញ្ញមួយទៀតរបស់ពួកអាក្សត់ (សាធារណរដ្ឋខ្មែរ) ។ ឥឡូវនេះយើងមានរដ្ឋធម្មនុញ្ញរបស់យើង ។ ហើយឥឡូវយើងរៀបចំបោះឆ្នោតជ្រើសរើសសភាតំណាងប្រជាជនទៀត ។ នេះជាការរៀបចំបញ្ចប់តាមផ្លូវច្បាប់នូវរបបចាស់ ។ ជាក់ស្តែងយើងបញ្ចប់រួចហើយ ។ តែយើងត្រូវធ្វើតាមផ្លូវច្បាប់ទៀត ។ ដូច្នេះ យើងនឹងមានសភាប្រជាជនដែលជា**អង្គការធ្វើច្បាប់** ។ អង្គការនេះរៀបចំរដ្ឋាភិបាលថ្មីដែលជា**អង្គការអនុវត្តច្បាប់** ។ ដល់យើងរៀបចំបានដូច្នេះ របបចាស់ត្រូវបិទឆាកទាំងស្រុង ។ នេះជាខ្លឹមសារនយោបាយនៃការបោះឆ្នោតទាំងក្នុងប្រទេសទាំងនៅក្រៅប្រទេស» ។

ក្នុងវិធីដំណើរការនៃការបោះឆ្នោត អង្គការបានលើកឡើងថា «យើងមិនមែនរៀបចំការបោះឆ្នោតតាមរបៀបនាយទុនទេ ។ យើងប្រើផ្តាច់ការវណ្ណៈអធនរបស់យើង ។ តែយើងក៏ត្រូវរៀបចំបោះឆ្នោតឲ្យបានស្រួល ដើម្បីកុំឲ្យខ្មាំងវាឆ្លៀតវាយយើង ។ ម្យ៉ាងទៀត សកលលោកក៏រង់ចាំមើលយើងដែរ ។ យើងចង់បង្ហាញថាយើងឈ្នះហើយ តែយើងមិនប្រង៉េងប្រង៉ាងយើងធ្វើសមរម្យ ទាំងខាងក្នុងប្រទេស ទាំងខាងក្រៅប្រទេស» ។

អង្គការក៏បានបញ្ជាក់យ៉ាងច្បាស់ដែរអំពីភារកិច្ចរបស់គណៈកម្មាធិការដែលត្រូវរៀបចំបោះឆ្នោត លក្ខណៈរបស់បេក្ខជនដែលត្រូវឈរឈ្មោះដែលកម្មាភិបាលមូលដ្ឋានត្រូវក្តាប់ដើម្បីពន្យល់អប់រំឃោសនាក្នុងប្រជាជន មូលដ្ឋានបោះឆ្នោតដែលឈរលើការដ្ឋានធំៗនៅជនបទ ការបោះឆ្នោតនៅតាមរោងចក្រនិងនៅក្នុងកងទ័ព ។ កងទ័ពនៅមូលដ្ឋាន ភាគ តំបន់ឈប់ ទុកដូចជាកសិករ ដូច្នេះអត់មានការរៀបចំឲ្យបោះឆ្នោតដោយឡែកទេ ។ ឯតំណាងទ័ពត្រូវជ្រើសរើសតែនៅខាងលើទេ ។

ចំពោះសភាតំណាងប្រជាជន អង្គការបានលើកឡើងថា «គ្មានលក្ខណៈដូចសភាចាស់ទេ ។ តំណាងរបស់យើងរស់នៅជាប់នឹងប្រជាជន ធ្វើការជាមួយប្រជាជន ដោះស្រាយជីវភាពប្រជាជន ។ ដល់ប្រប្រជុំម្តងបួពីរដងក្នុងមួយឆ្នាំ ឬមានប្រជុំពិសេស ទើបអញ្ជើញមកប្រជុំ ។ ទន្ទឹមនេះ យើងចាត់តាំងគណៈអចិន្ត្រៃយ៍របស់សភាពមួយសម្រាប់ដំណើរការជាប្រចាំនៅភ្នំពេញ» ។

ក្នុងការឃោសនាអប់រំ អង្គការបានលើកឡើងថា «បើមានគេសួរ យើងត្រូវពន្យល់ កុំប្រង៉េងប្រង៉ាង កុំឲ្យឃើញថាយើងចង់បង្ក្រាប ។ ទន្ទឹមនេះក៏កុំនិយាយលេងពីសភានៅមុខប្រជាជន ឲ្យឃើញថាយើងបន្ទឹមបន្ទំ ហើយសភាយើងគ្មានតម្លៃអី ។ ការពិតនៅតែជាភារកិច្ចរបស់បក្សដដែល ។ ត្រូវអប់រំផ្ទៃក្នុងយើងឲ្យយល់ថា សមមិត្តដែលមកធ្វើតំណាងមិនមែនជាបញ្ហាយសសក្តិឬមុខមាត់ទេ ។ កុំឲ្យមានសតិអារម្មណ៍នេះ ។ កុំឲ្យបែកបាក់សាមគ្គីគ្នា» ។

**ឌុង សុភារិទ្ធ**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| លរ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១៣២ | អ៊ូ ស ហៅ សារិន | ប្រជាជន | តំបន់២៥ | ១៨-៧-៧៦(?) | ២២-២-៧៦(?) | |
| ១៣៣ | កា អ៊ុម | ទាហានគិញ | ?? | ?? | ២-៣-៧៦ | |
| ១៣៤ | ឃួន ចាន់ | ទាហាន កាប៊ូរ៉ាល់ | ?? | ?? | ៥-៣-៧៦ | ឃើស្លាប់ |
| ១៣៥ | ប៉ោ ហ៊ូរៈ | និស្សិត | ?? | ?? | ៨-៣-៧៦ | |
| ១៣៦ | សួង ឆេង | តំណាងរាស្ត្រ | ?? | ?? | ១៤-៣-៧៦ | ឃើស្លាប់ |
| ១៣៧ | ស៊ឹម ឈាង | ប្រជាជន | ?? | ?? | ១៩-៣-៧៦ | ឃើស្លាប់ |
| ១៣៨ | អ៊ុំ សឿន | ទាហាន ពលទោ | ?? | ?? | ១៩-៣-៧៦ | ឃើស្លាប់ |
| ១៣៩ | ឃឹម នៅ | ប្រជាជន | ?? | ?? | ២៦-៣-៧៦ | ឃើស្លាប់ |
| ១៤០ | មាស ស៊ីហ៊ូ | ប្រជាជន | ?? | ?? | ២៧-៣-៧៦ | ឃើស្លាប់ |
| ១៤១ | អ៊ុំ បូប៊ី | គ្រូបង្រៀន | ?? | ?? | ២៨-៣-៧៦ | ឃើស្លាប់ |
| ១៤២ | ស ខុម | ទាហាន ពលទោ | ?? | ?? | ២៩-៣-៧៦ | |
| ១៤៣ | ឃួស ម៉េង | ទាហាន សក្តិ២ | ?? | ?? | ២៩-៣-៧៦ | |
| ១៤៤ | ម៉ី មុនីរតនៈ | ទាហាន សក្តិ២ | ?? | ?? | ២៩-៣-៧៦ | |
| ១៤៥ | ជុំ សារ៉ាត | ទាហាន ពលទោ | ?? | ?? | ២៩-៣-៧៦ | |
| ១៤៦ | ទេស វ៉ាន់ស៊ី | ទាហាន ដោយសេហ្វ | ?? | ?? | ២៩-៣-៧៦ | |
| ១៤៧ | ឌី ឈុត | ទាហាន ពលទោ | ?? | ?? | ២៩-៣-៧៦ | |
| ១៤៨ | មុត សាម៉េត | ទាហាន ដោយ១ជាន់ | ?? | ?? | ២៩-៣-៧៦ | |
| ១៤៩ | ដា ម៉ៅ | ទាហាន ពលទោ | ?? | ?? | ២៩-៣-៧៦ | |
| ១៥០ | ង៉ួន អថា | ប៉េអឹម ពេទ្យ | ?? | ?? | ២៩-៣-៧៦ | |
| ១៥១ | អ៊ឹម សុឃុន (ស្រី) | ទាហាន លេខាធិការ | ?? | ?? | ២៩-៣-៧៦ | |
| ១៥២ | ឡុង មរកត (ស្រី) | ស្មៀនហិរញ្ញវត្ថុ | ?? | ?? | ២៩-៣-៧៦ | ខ្សែឡុងបូរ៉េត |
| ១៥៣ | ឡុង នារី ស្រី) | និស្សិត | ?? | ?? | ២៩-៣-៧៦ | ខ្សែឡុងបូរ៉េត |
| ១៥៤ | គឹម ដារី | កូនសិស្ស | ?? | ?? | ២៩-៣-៧៦ | |
| ១៥៥ | គឹម សុង | ប្រជាជន | ?? | ?? | ៣០-៣-៧៦ | ឃើស្លាប់ |
| ១៥៦ | គឹម កេតសាមនី | ?? | ?? | ?? | ៣០-៣-៧៦ | សាសនាកាតូលិក |
| ១៥៧ | គឹម សុវ៉ាន់ដារ៉ា | ?? | ?? | ?? | ៣០-៣-៧៦ | សាសនាកាតូលិក |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥៨ | ឡុង វ៉ានីរដ្ឋ | ?? | ?? | ?? | ៣០-៣-៧៦ | ខ្មែរឡុងបូរ៉េត |
| ១៥៩ | អ៊ូ ដាលីន (ស្រី) | កូន អ៊ូ លុន | ?? | ?? | ៣០-៣-៧៦ | |
| ១៦០ | អ៊ូ ពីដែង | កូន អ៊ូ លុន | ?? | ?? | ៣០-៣-៧៦ | |
| ១៦១ | អ៊ូ ពុន | កូន អ៊ូ លុន | ?? | ?? | ៣០-៣-៧៦ | |
| ១៦២ | ឡុង វីយ៉ាដា | ?? | ?? | ?? | ៣០-៣-៧៦ | ខ្មែរឡុងបូរ៉េត |
| ១៦៣ | ឡុង វត្ថា | ?? | ?? | ?? | ៣០-៣-៧៦ | ខ្មែរឡុងបូរ៉េត |
| ១៦៤ | ឡុង បារមី | ?? | ?? | ?? | ៣០-៣-៧៦ | |
| ១៦៥ | អ៊ឹម សោម | ទាហាន ពលទោ | ?? | ?? | ៣០-៣-៧៦ | |
| ១៦៦ | មួ ប៉ិច | យុទ្ធជន | ?? | ?? | ៣០-៣-៧៦ | |
| ១៦៧ | តៅ គឹមហ៊ុយ | យុទ្ធជន | ?? | ?? | ៣០-៣-៧៦ | |
| ១៦៨ | កូនរបស់ ផាច់ ដា ចំនួន៤នាក់ | | ?? | ?? | ៣០-៣-៧៦ | |
| ១៦៩ | ណាង កែវ (ស្រី) | ?? | តំបន់៣៣ | ៧-៤-៧៦ | ?? | ជនជាតិលាវ |
| ១៧០ | ណាង ដាវ (ស្រី) | ប្រពន្ធ ចឹរីន ស៊ុប | តំបន់៣៣ | ៧-៤-៧៦ | ?? | ជនជាតិលាវ |
| ១៧១ | ម៉ាយ ចំរឹនស៊ុប | ជាងម៉ាស៊ីន | តំបន់៣៣ | ៧-៤-៧៦ | ?? | ជនជាតិលាវ |
| ១៧២ | ថាវ ប៊ុនថាវី | ជាងយន្តហោះ | តំបន់៣៣ | ៧-៤-៧៦ | ?? | ជនជាតិលាវ |
| ១៧៣ | កេ វ៉ាល់វ៉ា | ?? | តំបន់២២ | ?? | ៨-៤-៧៦ | ឥណ្ឌូ |
| ១៧៤ | ម៉ូហាម៉េត | ?? | តំបន់២២ | ?? | ៨-៤-៧៦ | ឥណ្ឌូ |
| ១៧៥ | កេ សូដា | ?? | តំបន់២២ | ?? | ៨-៤-៧៦ | ឥណ្ឌូ |
| ១៧៦ | អ៊ីស ស្មាអ៊ី | ?? | តំបន់៣៣ | ?? | ៨-៤-៧៦ | ឥណ្ឌូ |
| ១៧៧ | ម៉ូហ្គាំម៉ា ខូឃិត្រិយ៉ា | ?? | តំបន់៣៣ | ?? | ៨-៤-៧៦ | ឥណ្ឌូ |
| ១៧៨ | អាហ្សីហ្ សារ៉ាប៊ីប៊ី (ស្រី) | ចិញ្ចឹមគោ | តំបន់២៥ | ?? | ២៩-៤-៧៦ | ឥណ្ឌូ |
| ១៧៩ | គឹម ដាត | ចិញ្ចឹមគោ | ?? | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៨០ | អាសុខាន់វន ប្រាហីម | កូនសិស្ស | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៨១ | មេ ដាម | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៨២ | អាប់ឌុលឡា | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៨៣ | គង់ សេន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | អារ៉ាប់ |
| ១៨៤ | ណាស៊ី អាស់ស្មាត់ | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៨៥ | គឹម ការីន យ៉ាវប៊ូ | អាហារណ៍នីហរណ៍ | តំបន់២៥ | ១១-៤-៧៦ | ?? | ឥណ្ឌូ |
| ១៨៦ | សា ហ្វា | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | អារ៉ាប់ |
| ១៨៧ | សា អ៊ីត | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៨៨ | ហាស់សាន់ | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |
| ១៨៩ | ការីម | លក់ដូរ | តំបន់២៥ | ១១-៤-៧៦ | ?? | ប៉ាគីស្ថាន |

**(នៅមានត)**

# កំណប់ព្រលឹងប្រវ

## ឯកសារខ្មែរក្រហមនៅស្រុករំដួល



# ត្តិសាស្ត្រ

## ខេត្តស្វាយរៀង



រូបថត: ហេង ស៊ីនិត

ឆ្លៀតក្នុងឱកាសទំនេរពីការងារស្រែចម្ការ សួស សារ៉ន បានប្រកបមុខរបរថ្មីមួយទៀត ជាអ្នកស៊ីឈ្នួលរែកដីនៅក្នុងភូមិកំណើតរបស់ខ្លួនឯភូមិព្រៃគាវ ឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង ។ ក្នុងរយៈពេលជាង១០ថ្ងៃមុនថ្ងៃដាក់បិណ្ឌនារដូវភ្ជុំឆ្នាំ២០០១ សួស សារ៉ន ត្រូវបានជួលឲ្យរែកដីបំពេញមុខផ្ទះហ៊ីង ភុន និងប្រពន្ធឈ្មោះ ខឹម សំហេង ក្នុងតម្លៃ២៥០០រៀលក្នុងមួយម៉ែត្រគូប ។ ក្នុងអំឡុងពេលនៃការជីកដី សារ៉ន បានប្រទះឃើញកេសគ្រាប់កាំភ្លើងអាមេរិកាំងចំនួន៣ដែលកប់ទន្ទឹមគ្នាក្នុងជម្រៅដីប្រហែលកន្លះម៉ែត្រ ។ សារ៉ន បានកកាយមើលកេសទាំងបីនេះ ហើយបានឃើញឯកសារមួយកេសដែលមានរុំថង់ផ្លាស្ទិក ហើយចងរឹតដោយខ្សែយ៉ាងតឹង ។ ពិតមែនតែសារ៉ន ជាមនុស្សមិនចេះអក្សរ ប៉ុន្តែគាត់បានដឹងយ៉ាងប្រាកដថាឯកសារនេះគឺជាបញ្ជីឯកសាររបស់ខ្មែរក្រហម ដែលត្រូវបានកប់លាក់ទុក ។ ចំណែកកេស២ទៀតដែលគ្មានអ្វីសោះនោះត្រូវបានសង្ស័យថាជាកេសដាក់មាសពេជ្រ ។ សារ៉ន បានយកកេសទាំង៣នោះទៅប្រគល់ឲ្យម្ចាស់ផ្ទះ ដោយគ្រាន់តែស្រាយយកថង់ផ្លាស្ទិកដែលរុំឯកសារនោះទៅទ្រាប់បាតបង្គីរបស់គាត់តែប៉ុណ្ណោះ ។ សារ៉ន នៅតែបន្តរែកដីតទៅទៀតរហូតដល់ចប់ការងារនេះ ។

ឯកសារដែលកប់បាត់ក្នុងដីរាប់ឆ្នាំទៅហើយនោះ ត្រូវបានគាស់និងបើកកកាយនូវរឿងពិតមួយចំនួនក្នុងសម័យកាលនៃរបបខ្មែរក្រហម ។ ប្រជាជនក្នុងភូមិព្រៃគាវជាច្រើននាក់បាននាំគ្នាអានឯកសារយ៉ាងយកចិត្តទុកដាក់ និងនឹកគិតទៅដល់អតីតកាលរបស់ខ្លួនដែលធ្លាប់បានហែលឆ្លងក្នុងរបបដែលមានតែការកាប់សម្លាប់មនុស្សឥតញញើតដៃ ។ ក្នុងអារម្មណ៍ភ័យខ្លាចដោយសារតែការនឹកឃើញជីវិតដ៏ជូរចត់របស់ខ្លួនបែបនេះ ហ៊ីង ភុន និងប្រពន្ធ បាននាំយកឯកសារខ្មែរក្រហមទាំងនេះទៅប្រគល់ឲ្យប្រធានភូមិព្រៃគាវជាអ្នកថែរក្សាជំនួស ។ ឯកសារត្រូវបានរើកកាយមើលម្តងទៀតបន្ទាប់ពីបានចងយ៉ាងត្រឹមត្រូវរួចមក ។ កេសគ្រាប់កំពុកកំបាក់ទាំង៣ត្រូវបានបោះគរចោលនៅកន្លៀតជញ្ជាំងផ្ទះបាយ ។ ឯកសារដែលមានចំនួនច្រើនទំព័រ

ត្រូវបាត់អស់មួយចំនួន ។ ឯកសារខ្លះត្រូវបានយកទៅអាន ហើយក្រោយមកក៏បាត់ស្រមោលទៅដោយសារការធ្វេសប្រហែស ។ ពៅ វុន បានអធិប្បាយអំពីស្ថានភាពឯកសារទាំងនោះថា ពុកផុយអស់មួយចំនួននៅផ្នែកខាងក្រោម និងមួយចំនួនធំទៀតនៅល្អទាំងអស់ ។ សៀវភៅសរសេរមានក្របខាងក្រៅរូបកិន្នរឬរូបទេវតាដែលតំណាងនូវភាពទន់ភ្លន់សុភាពរាបសា បានក្លាយទៅជាសៀវភៅកម្មសិទ្ធិរបស់សន្តិសុខខ្មែរក្រហមដែលពោរពេញទៅដោយអំពើកាចសាហាវខ្មៅកខ្វក់ និងមានសុទ្ធតែឈ្មោះអ្នកទោសស្លូតត្រង់ដែលត្រូវសម្លាប់ ។ ឈ្មោះអ្នកទោសជាច្រើនរយនាក់ដែលមានក្នុងបញ្ជី សុទ្ធតែបានឆ្លងកាត់ការសួរចម្លើយជាមុនសិន ទើបត្រូវបានបញ្ជូនទៅកាន់ទីតាំងសម្លាប់ ។ ក្រៅពីសៀវភៅទាំងនេះ មានបញ្ជីឯកសារជាក្រដាសទំហំ A៤ និងជាសន្លឹកសៀវភៅផ្សេងៗជាច្រើនទៀត ដែលមានបញ្ជាក់យ៉ាងច្បាស់អំពីកំណត់ហេតុនៃការប្រជុំ កម្មវិធី បញ្ជីឈ្មោះអ្នកទោស របាយការណ៍ និងចម្លើយសារភាពរួមជាមួយនឹងការចុះហត្ថលេខាដឹងឮពីប្រធានគុក អ្នកសួរចម្លើយ អ្នកចាំស្តាប់ ជាដើម ។ ឈ្មោះអ្នកភូមិព្រៃគាវនិងភូមិឯទៀតជាច្រើននាក់ ត្រូវបានស្គាល់ឥតស្រពេចស្រពិលថាជាអ្នកទោសខ្មែរក្រហម ហើយត្រូវបានកត់បញ្ចូលក្នុងបញ្ជីនេះទាំងអស់ ។ រហូតមកដល់បច្ចុប្បន្ននេះ អ្នកទាំងនោះនៅតែចង់ឲ្យគេឯងដឹងថាខ្លួនពិតជាមិនបានធ្វើអ្វីដែលខុសនឹងគន្លងរបស់អង្គការបក្សដូចដែលត្រូវចោទប្រកាន់នោះឡើយ ។ ប្រជាជនមួយចំនួនក្នុងភូមិព្រៃគាវ បានពោលទាំងក្រៀមក្រំថា «ឃើញឯកសារនឹកឃើញរឿងដើមក្នុងសម័យប៉ុលពត» ។ ពៅ វុន បានឲ្យដឹងថា ឈ្មោះអ្នកទោសទាំងអស់ភាគច្រើនត្រូវបានស្គាល់យ៉ាងច្បាស់ថាជាមនុស្សដែលបានចាប់មកពីឃុំបុសមននិងឃុំថ្នាធ្នង់ ក្នុងស្រុករំដួល ។ ពៅ វុន មិនបានបញ្ចេញឈ្មោះអ្នកទោសទាំងអស់នោះឲ្យដឹងឡើយ ។ គាត់គ្រាន់តែបង្ហាញឧទាហរណ៍របៀបសាមញ្ញមួយថា ឈ្មោះ «ក» ត្រូវខ្មែរក្រហមចាប់យកទៅដោយចោទថាលួចគោ ដឹកស្រាប្លន់ប្ងន់ ។

បញ្ជីឯកសាររាប់រយសន្លឹកត្រូវបានកំណត់យ៉ាងច្បាស់ថាជាបញ្ជីឯកសារដែលបានធ្វើឡើងនៅក្នុងមន្ទីរសន្តិសុខមួយកន្លែងដែលស្ថិតនៅក្នុងវត្តបាក្រុង ឃុំស្វាយចេក ស្រុករំដួល ។ ពៅ វុន បានហៅឯកសារទាំងនោះថាបានបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរថែមទៀតលើអ្នកជាប់ទោសដែលមិនមែនជាអ្នកលេងបៀអាប៉ោង និងធ្លាប់លួចស៊ីតាមផ្ទះបន្តិចបន្តួច ។ ទាក់ទិននឹងរឿងរ៉ាវនៃបញ្ជីឯកសាររបស់ខ្មែរក្រហម ពៅ វុន បានពន្យល់ពីហេតុការណ៍នានាដែលបានកើតឡើងកាលពីជំនាន់ខ្មែរក្រហមថា មានមនុស្សជាច្រើនត្រូវបានចងបណ្តើរកាត់មុខផ្ទះគាត់ស្ទើរតែរាល់ថ្ងៃយកមកដាក់ក្នុងមន្ទីរសន្តិសុខមួយកន្លែង ។ អ្នកទោសទាំងនោះត្រូវបញ្ចេញមកសួរចម្លើយនៅខាងក្រៅ គឺនៅក្រោមដើមព្រីងពីរដើមដែលស្ថិតនៅចម្ងាយប្រមាណ៣០ម៉ែត្រពីកន្លែងដែលឯកសារត្រូវបានគាស់ឃើញ ។ ចំណែកឯផ្ទះរបស់ ហ៊ីង ភុន និងប្រពន្ធ រស់នៅសព្វថ្ងៃ គឺជាអតីតផ្ទះសម្រាប់កងសន្តិសុខខ្មែរក្រហម ។ ខឹម ណារ៉ា ជាប្អូនបង្កើតរបស់ ខឹម សំហេង បាននិយាយថា ផ្ទះសម្រាប់សន្តិសុខខ្មែរក្រហមស្នាក់នៅមានច្រើន ស្ថិតនៅក្បែរៗគ្នា ។ ណារ៉ា គឺជាអតីតកងនារីក្នុងសហករណ៍ភូមិព្រៃគាវ ឃុំកំពង់ចក ។ ណារ៉ា ធ្លាប់បានឃើញខ្មែរក្រហមបណ្តើរអ្នកទោសមកសួរចម្លើយជារៀងរាល់ថ្ងៃ ប៉ុន្តែមិនបានឃើញការសួរចម្លើយទេ គ្រាន់តែបានឮសម្រែកឲ្យជួយ ដែលបញ្ជាក់ពីការឈឺចាប់ខ្លាំងបំផុតនៃអ្នកទោសទាំងនោះ ។ ឈ្មោះ កន គឺជាអ្នកសួរចម្លើយប្រចាំនៅមន្ទីរសួរចម្លើយក្រោមដើមព្រីងទាំងពីរដើម ។ ពៅ វុន និយាយថា អក្សរដែលសរសេរលើឯកសារចម្លើយសារភាពដែលគាស់បាននេះ មានលក្ខណៈដូចអក្សររបស់ កន បេះបិទ ។ កន ត្រូវបានប្រជាជនមូលដ្ឋាននៅឃុំកំពង់ចក ស្រុករំដួល ស្គាល់យ៉ាងច្បាស់ថាជាមនុស្សតែម្នាក់ដែលបានធ្វើទារុណកម្មយ៉ាងសាហាវទៅលើអ្នកទោស ។ មនុស្សម្នាក់ទៀតឈ្មោះ ឯក សារ៉េន ហៅ ណាំ សារ៉េន គឺជាអ្នកចាប់ចងយ៉ាងសាហាវម្នាក់ដែរ ។ ម្នាក់ទៀតឈ្មោះ សោ សារ៉េត គឺជាប្រធានមន្ទីរសន្តិសុខនៅវត្តបាក្រុង និងជាអ្នកគ្រប់គ្រងរាល់រចនាសម្ព័ន្ធការងារទាំងអស់ ។ ទាំងបីនាក់ត្រូវ



កេសគ្រាប់កាំភ្លើងអាមេរិកដែលលាក់ទុកឯកសារខ្មែរក្រហម

រូបថត: ហេង ស៊ីនិត

សម្លាប់នាពេលក្រោយមកទៀត គឺពេលដែលខ្មែរក្រហមខាងនិរតីចូលមកគ្រប់គ្រងតំបន់បូព៌ានេះ ។

នៅចុងឆ្នាំ១៩៧៧ ភាពចលាចលមួយបានកើតមានឡើងនៅទូទាំងខេត្តស្វាយរៀង ហើយក៏ជាចំណុចចាប់ផ្តើមនៃការតាមចាប់ជនក្បត់ដែលជាបក្ខពួកខាង សោ ភឹម ប្រធានភូមិភាគបូព៌ា ។ ប្រជាជនមួយចំនួនធំនៅខេត្តស្វាយរៀង ត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ ។ ចំណែកអ្នករស់នៅម្តុំឃុំកំពង់ចក ស្រុករំដួល ក៏ដូច្នោះដែរ ។ កម្មាភិបាលខ្មែរក្រហមខាងបូព៌ាស្ទើរតែទាំងអស់ត្រូវបានសម្លាប់ និងរត់ប្រាសអាយុយករួចខ្លួន ។ ខឹម ណាក់ា បានពន្យល់ថា ដោយសារតែមូលហេតុនេះហើយទើបមានការប្រមូលឯកសារទាំងឡាយដែលជាអំពើរបស់ខ្លួនមកទុកដាក់យ៉ាងត្រឹមត្រូវក្នុងកេសគ្រាប់នេះ ។ ខឹម សំហេង បានហៅរឿងកប់ឯកសារនេះថាជាការបិទបាំងនូវអំពើឧក្រិដ្ឋរបស់ខ្លួន ។ ប្រធានសន្តិសុខឈ្មោះ សៅ សារ៉េត អ្នកចាប់ចងឈ្មោះ ឯក សារ៉េន អ្នកសួរចម្លើយឈ្មោះ កន និងអ្នកឯទៀតដូចជា ចាន់ អៀង ជាអ្នកចាំស្តាប់ក្នុងពេលសួរចម្លើយត្រូវទាហានខ្មែរក្រហមខាងនិរតីសម្លាប់ទាំងអស់នៅឆ្នាំ១៩៧៨ ។ តំបន់បូព៌ាត្រូវធ្លាក់ទៅលើខ្មែរក្រហមខាងនិរតីជាអ្នកគ្រប់គ្រងជំនួស ។ របនាសម្ព័ន្ធការងារក៏ត្រូវរៀបចំសាជាថ្មី ។ រយៈពេលជិត១ឆ្នាំនៃការគ្រប់គ្រងតំបន់បូព៌ា ខ្មែរក្រហមមកពីភូមិភាគនិរតី បានផ្តល់មេរៀនយ៉ាងជូរចត់ដល់អតីតខ្មែរក្រហមនៅភូមិភាគបូព៌ា ក្នុងបំណងធ្វើឲ្យរាងចាល ។ ប៉ុន្តែការគ្រប់គ្រង

បែបនេះត្រូវបានវាយរំលំដោយកងកម្លាំងរណសិរ្សរំដោះជាតិកម្ពុជាសហការជាមួយកងទ័ពវៀតណាម នៅខែមករា ឆ្នាំ១៩៧៩ ។ ប្រជាជននៅឃុំកំពង់ចកបានរត់គៀសខ្លួនដើម្បីគេចផុតពីសង្គ្រាមក្នុងគ្រានេះ ។ ខឹម ណារ៉ា បានឲ្យដឹងថា កងទ័ពវៀតណាមបានមកបោះជំរំនៅចំទីតាំងមន្ទីរសន្តិសុខរបស់ខ្មែរក្រហមខាងបូព៌ាកាលពីមុន គឺចំកន្លែងដែលឯកសារខ្មែរក្រហមត្រូវបានគាស់នាពេលថ្មីៗនេះ ។ លេណដ្ឋានជាច្រើនត្រូវបានជីកដើម្បីការពារខ្សែត្រៀម ។ បន្ទាប់ពីកងទ័ពវៀតណាមដកចេញអស់ទៅ ប្រជាជនជាច្រើនគ្រួសារបាននាំគ្នាមករស់នៅក្នុងមូលដ្ឋានរបស់ខ្លួនវិញ និងប្រកបរបរចិញ្ចឹមជីវិតជាអ្នកស្រែចម្ការរហូតមកដល់បច្ចុប្បន្ននេះ ។

របបកម្ពុជាប្រជាធិបតេយ្យបានផុតរលត់ទៅ ។ សំណុំរឿងផ្សេងនៃរបបនេះក៏ត្រូវបានរកឃើញថ្មីៗជាច្រើនទៀតក្រោមកិច្ចស្រាវជ្រាវដ៏ហ្មត់ចត់មួយ ។ បញ្ជីឯកសារអ្នកទោស និងចម្លើយសារភាពជាង៦០០ទំព័រនេះ គឺជាឯកសារប្រវត្តិសាស្ត្រដ៏មានសារសំខាន់ ។ ឯកសារនេះជាផ្នែកមួយនៃការកាប់សម្លាប់និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃនៅប៉ែកបូព៌ានៃប្រទេសកម្ពុជា ហើយក៏ជាបច្ច័យមួយយ៉ាងសំខាន់ក្នុងការជួយជំរុញឲ្យថ្នាក់ដឹកនាំអង្គការបដិវត្តន៍សម័យនោះ (កម្ពុជាប្រជាធិបតេយ្យ) ត្រូវតែចេញមុខទទួលខុសត្រូវនៅចំពោះមុខច្បាប់ នូវទង្វើនៃខ្សែសង្វាក់បញ្ជារបស់ខ្លួនដែលបានអនុវត្តទូទាំងផ្ទៃប្រទេសកាលពីអំឡុងឆ្នាំ១៩៧៥-៧៩ ។ ស្របពេលដែលអង្គការសហប្រជាជាតិបានផ្តាច់ការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា អំពីដំណើរការបង្កើតតុលាការកាត់ក្តីមេដឹកនាំខ្មែរក្រហម ឯកសារជាង៦០០ទំព័រដែលទើបតែត្រូវបានរកឃើញនេះ អាចនឹងក្លាយជាកម្មវត្ថុមួយនៃការពិចារណាឡើងវិញសម្រាប់អនាគតកម្ពុជា ។

**រផង ពន្សរ៉ាស៊ី**



សួស សារ៉ន



ពៅ វុន

# ការងារដែលជាផ្លូវនឹងការរស់រានមានជីវិត

“ខ្ញុំមិនចង់ចូលធ្វើការនៅមន្ទីរ ស-២១ ទេ ។ ខ្ញុំមិនចង់នៅរង់ចាំថ្ងៃស្លាប់នោះទេ ។ ជារៀងរាល់ថ្ងៃ ខ្ញុំឃើញសភាពវេទនារបស់អ្នកទោសនិងមិត្តភក្តិរបស់ខ្ញុំដែលត្រូវទទួលរងទារុណកម្មនិងសម្លាប់ ។ ខ្ញុំចង់រត់ចេញពីមន្ទីរ ស-២១ ក៏ប៉ុន្តែប្រសិនបើខ្ញុំហ៊ានរត់ចេញពីមន្ទីរ ស-២១ គ្រួសារខ្ញុំនឹងត្រូវស្លាប់ទាំងអស់” ។ នេះគឺជាពាក្យសម្តីរៀបរាប់របស់ សោម ម៉េត អតីតយុទ្ធជនកងការពារនៅមន្ទីរ ស-២១ (គុកទួលស្លែង) ។

សោម ម៉េត ជាអតីតយុទ្ធជនកងការពារនៅមន្ទីរ ស-២១ ក្នុងចំណោមអតីតយុទ្ធជននិងកម្មាភិបាលនៅមន្ទីរ ស-២១ ដែលខ្ញុំបានជួបនាពេលថ្មីៗនេះ ។ ម៉េត បានឲ្យដឹងថា តាំងពីឆ្នាំ១៩៧៩រហូតមកដល់បច្ចុប្បន្ននេះ គាត់មិនដែលបានជួបពិភាក្សានិងផ្តល់ព័ត៌មានដល់អ្នកសារព័ត៌មានណាម្នាក់នៅឡើយទេ ។ នៅអំឡុងឆ្នាំ១៩៨០ អតីតអ្នកធ្វើការមួយចំនួននៅមន្ទីរ ស-២១ ត្រូវរដ្ឋាភិបាលនៃរបបសាធារណរដ្ឋកម្ពុជានិងជំនាញការវៀតណាមហៅយកទៅអប់រំកែប្រែ ។ ដោយឡែក ម៉េត មិនបានចូលមន្ទីរអប់រំដូចអ្នកទាំងនោះទេ ។ ម៉េត បញ្ជាក់ថា នេះដោយសារគាត់មានតួនាទីត្រឹមតែជាយុទ្ធជន ។

អស់រយៈពេល២៣ឆ្នាំដែល វ៉ាន់ ណាត និង ជុំ ម៉ាញ អតីតអ្នកទោសនៅមន្ទីរ ស-២១ និងជនរងគ្រោះនៃរបបខ្មែរក្រហមជាច្រើននាក់ទៀត បានទន្ទឹងរង់ចាំ“យុត្តិធម៌” ។ នាពេលថ្មីៗកន្លងទៅនេះ ដាន ផនចាន់ អតីតអ្នកទោសម្នាក់ទៀតនៅមន្ទីរ ស-២១ បានទទួលមរណភាពនៅក្នុងមន្ទីរពេទ្យឯកជនមួយក្នុងទីក្រុងភ្នំពេញ ។ មរណភាពរបស់ ដាន ផនចាន់ បានធ្វើឲ្យ វ៉ាន់ ណាត និង ជុំ ម៉ាញ មានការរន្ធត់ចិត្តយ៉ាងខ្លាំង ។ វ៉ាន់ ណាត និង ជុំ ម៉ាញ បាននិយាយថា គាត់នៅតែទន្ទឹងរង់ចាំយុត្តិធម៌ ។ គាត់ចង់ឃើញការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមនៅមុនពេលគាត់ស្លាប់ ។

សោម ម៉េង ជាបងប្រុសរបស់ ម៉េត ត្រូវបានចាប់ខ្លួននិងសម្លាប់នៅមន្ទីរ ស-២១ នៅឆ្នាំ១៩៧៨ ។ ដោយសារការបាត់បង់បងប្រុសម្នាក់នេះហើយដែលកាន់តែធ្វើឲ្យ ម៉េត មិនចង់ធ្វើការនៅមន្ទីរ ស-២១ ។ បើទោះជា ម៉េត ធ្លាប់បានបម្រើការនៅមន្ទីរ ស-២១ ក៏ប៉ុន្តែគាត់មានឆន្ទៈចង់បានយុត្តិធម៌ដូច វ៉ាន់ ណាត និង ជុំ ម៉ាញ ដែរ ។ ម៉េត និយាយថា គាត់ចង់ឲ្យមានការជំនុំជម្រះទោសចំពោះមេដឹកនាំខ្មែរក្រហម ហើយគាត់គិតថាប្រសិនបើតុលាការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមបង្កើតឡើងកាន់តែឆាប់ នឹងធ្វើឲ្យអ្នកស្រុកលែងមានភាពស្រពេចស្រពិលចំពោះអតីតកាលរបស់គាត់ ។ គាត់ចង់បានសេរីភាពពេញលេញក្នុងការរស់នៅប្រចាំថ្ងៃក្នុងជីវិតរបស់គាត់ ។

ម៉េត បានរៀបការនៅឆ្នាំ១៩៨០ ហើយបាននិយាយប្រាប់ប្រពន្ធរបស់គាត់អំពីការងារដែលគាត់ធ្លាប់បានធ្វើនៅមន្ទីរ ស-២១ ។ ម៉េត ក៏ធ្លាប់និយាយអំពីការងារដែលគាត់បានធ្វើនៅមន្ទីរ ស-២១ ប្រាប់អ្នកស្រុកអ្នកភូមិ នៅពេលដែលគាត់ជួបជុំគ្នាទទួលទានស្រា ។ ម៉េត បាននិយាយថា អ្នកស្រុកមួយចំនួនបានត្អូះតិះដៀលចំពោះរូបគាត់ ។

បច្ចុប្បន្ននេះ សោម ម៉េត មានអាយុ៤៣ឆ្នាំ ។ នៅឆ្នាំ១៩៧៣ គាត់បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមក្រោមការបង្ខិតបង្ខំពីកម្មាភិបាលភូមិ ។ គាត់បានចូលធ្វើជាយុទ្ធជននៅក្នុងអង្គភាពកងពលលេខ១២ ។ កងពលលេខ១២ស្ថិតនៅក្នុងភូមិភាគពិសេសរបស់ខ្មែរក្រហម ។ បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងពលលេខ១២បានប្តូរទៅជាកងពលលេខ៧០៣ ស្ថិតក្រោមបញ្ជាការរបស់សេនាធិការកងទ័ពខ្មែរក្រហម ។ នៅក្នុងអំឡុងសង្គ្រាមពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៥ ម៉េត ធ្លាប់បានធ្វើជាយុទ្ធជននិរសាឲ្យគណៈកងវរសេនាតូចជាច្រើននាក់ ។ ពាក់កណ្តាលឆ្នាំ១៩៧៤ ក្នុងខណៈដែលកងពលលេខ១២វាយលុកលើសមរភូមិទន្លេមេគង្គ

ទន្លេបាសាក់ និងក្តមសំណរ ម៉េត បានធ្វើជានិរសាររបស់ តាណាត លេខាកងពលលេខ១៧២ ។

នៅឆ្នាំ១៩៧៥ គណៈកងពលលេខ៧០៣បានចាត់តាំង ម៉េត ឲ្យទៅហាត់រៀនបច្ចេកទេសយោធានៅសាលាបច្ចេកទេស យោធា៧០៣ដែលស្ថិតនៅតាខ្មៅ ។ នៅឆ្នាំ១៩៧៦ តាណាត បានធ្វើជាជំនួយការសេនាធិការ ។ តាណាត បានជ្រើសរើស យុទ្ធជននីរសាឲ្យមកធ្វើការនៅមន្ទីរ ស-២១ ។ តាណាត មាន ឈ្មោះដើមថា អ៊ិន លន ។ តាណាត ត្រូវបានសម្លាប់នៅមន្ទីរ ស-២១ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ ដោយចោទប្រកាន់ថា ចូលដៃជើងជាមួយយួន ។ ចម្លើយសារភាពរបស់ តាណាត តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ម៉េត បានមកយាម "គុកពិសេស" ឬហៅថា "គុកដាំដេង" ដែលស្ថិតនៅម្តុំផ្សារថ្មី ។ ម៉េត និយាយថា គុកពិសេសស្ថិតនៅក្រោមការគ្រប់គ្រង របស់មន្ទីរ ស-២១ ។ អ្នកទោសដែលមានកំហុសស្រាលត្រូវ ឃុំឃាំងបណ្តោះអាសន្ននៅគុកពិសេស ។ អ្នកទោសមួយចំនួន នៅគុកពិសេសដែលអង្គការចាត់ទុកថាមានកម្រិតធ្ងន់ នឹងត្រូវ បញ្ជូនទៅមន្ទីរ ស-២១ ។

ម៉េត បានបណ្តោយឲ្យអ្នកទោសម្នាក់រត់ចេញពីគុកពិសេស ខណៈពេលដែលគាត់អនុញ្ញាតឲ្យអ្នកទោសនោះទៅបន្ទោរបង់ ។ ឃឹម វ៉ាត ហៅ ហ៊ី ជាអនុប្រធានមន្ទីរ ស-២១ បានចាប់ ម៉េត ដាក់ក្នុងគុកពិសេស ដោយសារតែការធ្វេសប្រហែសរបស់ ម៉េត ឲ្យអ្នកទោសរត់រួចពីគុក ។ ម៉េត នៅចាំសម្តីរបស់ ហ៊ី ដែល គំហកឲ្យគាត់ថា "អ្ហែងធ្វើឲ្យអ្នកទោសរត់រួច ឥឡូវអ្ហែងចូលគុក ជំនួសវាវិញម្តង" ។ ប្រមាណមួយសប្តាហ៍ក្រោយមក ហ៊ី បានដោះលែង ម៉េត បន្ទាប់ពីចាប់បានអ្នកទោសដែលរត់រួចនោះ មកវិញ ។ នៅឆ្នាំ១៩៧៩ ឌុច បានបាញ់សម្លាប់ ហ៊ី នៅខណៈដែលខ្មែរក្រហមចាញ់សង្គ្រាមជាមួយកងទ័ពវៀតណាម ហើយរត់ភៀសខ្លួនទៅព្រំដែនថៃ ។

នៅឆ្នាំ១៩៧៧ ឌុច ប្រធានមន្ទីរ ស-២១ បានចាត់តាំង ម៉េត ឲ្យមកយាមអ្នកទោសនៅមន្ទីរ ស-២១ ។ ម៉េត បានបម្រើ ការជាកងការពារអ្នកទោសនៅផ្នែកខាងក្នុង ស្ថិតក្រោមការ គ្រប់គ្រងរបស់ ប៉េង ។ ម៉េត ធ្លាប់យកបាយទៅឲ្យអ្នកទោស ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ម៉េត បានឃើញ ភី ជាលេខាកងវរ សេនាតូចរបស់កងពល៧០៣ ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។ នៅក្នុងសម័យសង្គ្រាម ម៉េត ធ្លាប់ធ្វើជានិរសាររបស់ ភី ។ ម៉េត និយាយថា គាត់មិនអាចជួយអ្វីដល់ ភី បានទេ ។ ប្រមាណ២សប្តាហ៍ក្រោយមក ភី ត្រូវបញ្ជូនទៅសម្លាប់នៅបឹង ជើងឯក ។

ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៧ ម៉េត បានឃើញ យុទ្ធជននិងកម្មាភិបាលជាច្រើននាក់នៃកងពលលេខ៧០៣ ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។ ការចាប់ខ្លួនយុទ្ធជន និងកម្មាភិបាលនៃកងពល ៧០៣ បានកើតឡើងស្របពេល ដែលខ្មែរក្រហមប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅតាម ព្រំដែន ។ ម៉េត និយាយថា អំឡុងពេលនោះ សូម្បីយុទ្ធជននៅ មន្ទីរ ស-២១ ក៏បាត់ខ្លួនជាច្រើននាក់ដែរ ។ ដោយមើលឃើញពី ការសម្លាប់ដ៏ព្រៃផ្សៃនៅមន្ទីរ ស-២១ ម៉េត មានគំនិតចង់លួច រត់ចេញពីមន្ទីរ ស-២១ ឆ្ពោះទៅប្រទេសវៀតណាម ។ ម៉េត និយាយថា "ប្រសិនបើខ្ញុំរត់ចេញពីមន្ទីរ ស-២១ ខ្ញុំអាចរស់តែ ម្នាក់ឯង ចំណែកក្រុមគ្រួសារខ្ញុំនឹងត្រូវស្លាប់" ។

នៅឆ្នាំ១៩៧៨ សោម ម៉េង ជាបងប្រុសរបស់ ម៉េត ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។ ហ៊ឹម ហ៊ុយ អនុប្រធាន កងការពារបណ្តោះអាសន្ននៅមន្ទីរ ស-២១ បានប្រាប់ ម៉េត អំពីការចាប់ខ្លួន សោម ម៉េង ។ ហ៊ុយ បានប្រាប់ ម៉េត កុំឲ្យបាក់ទឹកចិត្ត ហើយខិតខំធ្វើការងារឲ្យខ្លាំងឡើង កុំឲ្យអង្គការ ចាប់អារម្មណ៍ ។ មិនយូរប៉ុន្មាន អង្គការបានតាមដានប្រវត្តិរូប និងដក ម៉េត ពីមន្ទីរ ស-២១ ឲ្យទៅធ្វើការលត់ដំនៅព្រៃស ។ ម៉េត បានធ្វើស្រែជាមួយកងកុមារនៅព្រៃសរហូតដល់កងទ័ព វៀតណាមវាយរំដោះយកទីក្រុងភ្នំពេញនៅថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ ។

ព្រៃស មានឈ្មោះផ្សេងទៀតថា មន្ទីរ ស-២១ឃ ឬមន្ទីរ ២៤ ។ ព្រៃស ជាសាខារបស់មន្ទីរ ស-២១ ស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់ នុន ហ៊ុយ ហៅ ហ៊ុយស្រែ ។ មន្ទីរ ស-២១ឃ ជាកន្លែងផលិតភោគផលកសិកម្មសម្រាប់ផ្គត់ផ្គង់ ដល់អង្គភាពនិងសាខាមន្ទីរ ស-២១ ។ ម្យ៉ាងទៀត មន្ទីរ ស-


សោម ម៉េត ឆ្នាំ២០០២

២១យ គឺជាកន្លែងលត់ដំចំពោះយុទ្ធជននិងយុទ្ធនារីដែលមានកំហុសស្រាល ។ ប្រសិនបើយុទ្ធជននិងយុទ្ធនារីណាម្នាក់មិនព្រមកែប្រែកំហុសរបស់ខ្លួន នឹងត្រូវចាប់បញ្ជូនមកឃុំឃាំងនៅមន្ទីរ ស-២១ តែម្តង ។

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧ នុន ហ៊ុយ បានធ្វើបញ្ជីឈ្មោះចំនួន២គ្រួសារដែលត្រូវកម្ទេច ជូនទៅ ឌុច គណៈមន្ទីរ ស-២១ ។ នៅទំព័រខាងលើចំកណ្តាល ហ៊ុយ សរសេរថា "ឈ្មោះដែលត្រូវដក គ្រួសាររបស់ អាសុន និង ម៉ៃ លន់" ។ គ្រួសារទាំងពីរនេះមានសមាជិកចំនួន១៨នាក់ ។ នៅទំព័រខាងលើផ្នែកខាងឆ្វេង ឌុច បានសរសេរបញ្ជាក់មក ហ៊ុយ ថា "ស្នើសួរ៤នាក់ ក្រៅពីនេះវាយចោល" ។ ក្នុង"បញ្ជីឈ្មោះអ្នកទោសកម្ទេចផ្នែកបង ហ៊ុយស្រែ" ដែលធ្វើនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៧ បានបញ្ជាក់ថា ការកម្ទេចអ្នកទោស"ទាំងអស់ផ្នែកស្រែចំនួន១៧៨នាក់ រួចទាំងកុមារចំនួ១៦០នាក់" ។ នុន ហ៊ុយ ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៨ ដោយចោទប្រកាន់ថាចូលដៃជើងជាមួយយួន ។ ចម្លើយសារភាពរបស់ នុន ហ៊ុយ ហៅ ហ៊ុយស្រែ មានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ឯកសារប្រវត្តិរូបសង្ខេបកម្មាភិបាលមន្ទីរ ស-២១ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា បានសរសេរថា សោម ម៉េត កើតនៅឆ្នាំ១៩៥៧ វណ្ណភាពកសិករក្រ មុនចូលធ្វើបដិវត្តន៍ រកស៊ីធ្វើនំបញ្ចុកលក់ផង ដូរស្រូវផង ។ វណ្ណភាពក្រោយចូលបដិវត្តន៍ធ្វើយោធា ។ "មុនចូលបដិវត្តន៍ ខ្ញុំមិនដែលបម្រើនយោបាយទេ" ។ ម៉េត មានឪពុកឈ្មោះ សោម សុខ និងម្តាយឈ្មោះ អ៊ុក ណន ។ ម៉េត មានបងប្អូនប្រុស៥នាក់ ។

**ហ៊ុយ ខណ្ណៈ**

## ពាក្យស្លោកខ្មែរក្រហម

◆ **បំផុសមហាចលនាបដិវត្តរបស់មហាជន ការពារប្រទេស កសាងប្រទេស ធ្វើបដិវត្តសង្គមនិយមឱ្យសន្ទោសន្ទៅជាប់ជានិច្ច ដើម្បីកសាងវិនិច្ឆ័យ ស៊ើតសំរាំង និងជ្រើសរើសជួរកម្មាភិបាលរបស់មហាជន របស់បក្ស។** (កំណត់ហេតុលេខ១០៧៦)

◆ **សុខាភិបាលសង្គមកិច្ចត្រូវបម្រើកងកម្លាំង បម្រើកម្លាំងផលិតកម្ម និងកែប្រែជីវភាពរស់នៅរបស់ប្រជាពលករ។**

◆ **សុខាភិបាលសង្គមកិច្ចត្រូវដើរតាមមាគ៌ាមហាជន ដើម្បីកសាងក្រសួងរបស់ខ្លួនឱ្យបានរឹងប៉ឹង។**

◆ **ព្យាបាលជំងឺត្រូវរួមផ្សំទាំងពីរប្រភេទ ថ្នាំសម័យនិងថ្នាំបុរាណ។**

(កំណត់ហេតុលេខ១៨៨)

◆ **វាយប្រាកដជាឈ្នះ វាយមានការចាត់ចែង វាយមានការប្រុងប្រៀប ចេះវាយរហ័ស។**

◆ **ពង្រីកការវាយជិត វាយយប់ វាយរហ័ស វាយជាប់ជានិច្ចទាំងយប់ទាំងថ្ងៃ។**

◆ **ខ្នះខ្នែងធ្វើម្ចាស់ការ ប្តូរផ្តាច់ឈ្លាសវៃមោះមុត រះទើក សំងាត់ចល័តរហ័ស ចេះបញ្ឆោតបង្វែងដានខ្មាំង។**

◆ **ប្រយុទ្ធដោយឯករាជ្យម្ចាស់ការ រួមផ្សំយ៉ាងជិតស្និទ្ធរវាងទ័ពស្រួច តំបន់ និងឈ្លប ហើយពង្រីកងទ័ពទាំង៣ប្រភេទនេះ។**

(កំណត់ហេតុលេខ ២០០)



វិចិត្រករអាយុ១៨ឆ្នាំ



## សម្លេងពីមន្ទីរ ស-២១

**វគ្គទី៥: បង្ខំឱ្យឆ្លើយ**

**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

**(តពីលេខមុន)**

ចិននិងវៀតណាមបានលាយបញ្ចូលគ្នានូវសញ្ញាណដែលមិនអាចជំនួសបាននៃយុត្តិធម៌បដិវត្តរបស់សូវៀត ជាមួយគំនិត "កែទម្រង់ស្មារតី" ឬ "អប់រំកសាងខ្លួន" ដែលមាននៅប្រទេសចិននិងវៀតណាមតាំងពីសម័យមុនបដិវត្តមកម៉្លេះ ប៉ុន្តែនៅមានចំហាយរហូតមកនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

ដោយដើរតាមប្រពៃណីនេះ ចិននិងវៀតណាមបានអនុវត្តនូវអ្វីដែល ភីតធ័រ ប៊ីហ្គី និង ថមម៉ាស់ ឡាក់មែន ហៅថា យុទ្ធសាស្ត្រនៃ"ការព្យាបាលរោគ" ដើម្បីទប់ទល់ជាមួយមនុស្សខុសពីអ្នកដទៃ ដែលជាការខុសទៅនឹង "ការបំបាត់ចោល" ដែលធ្វើឡើងនៅសហភាពសូវៀត និងក្រោយមកនៅមន្ទីរស-២១ ។ នៅក្នុងប្រទេសទាំងបួននេះ អ្នកទោសត្រូវតែឆ្លើយយ៉ាងពេញលេញនិងជាចំហទៅនឹងការចោទប្រកាន់នានា និងនិយាយស្មានៗពីអតីតកាលរបស់ខ្លួនឲ្យដូចគ្នាទៅនឹងតម្រូវការរបស់បក្ស ។ ជាងនេះទៀត អ្នកទោសត្រូវតែសម្តែងនូវការសោកស្តាយយ៉ាងខ្លាំងទៀតផង ។ ប៉ុន្តែការទិញសេរីភាពពិបាកធ្វើណាស់ ហើយកម្របានពេញលេញទៅទៀត ។ អត្តចរិតរបស់អ្នកដែលត្រូវបានចោទប្រកាន់ថាធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ត្រូវបានធ្វើឲ្យខូចជាអចិន្ត្រៃយ៍ ប៉ុន្តែក្រោយពី "ការកែតម្រង់" រួចមក ចំនួនជនរងគ្រោះនៅប្រទេសចិននិងវៀតណាមស្លាប់តិចជាងនៅសូវៀតឆ្ងាយណាស់ ។ ផ្ទុយមកវិញ "ខ្មាំង"រាប់ពាន់នាក់បានចំណាយពេលយ៉ាងយូររស់នៅក្នុងគុក ។

នៅប៉ុន្មានខែចុងឆ្នាំ១៩៧៨ អ្នកធ្វើការនៅមន្ទីរ ស-២១ បានលេងសើចជាមួយនឹងគំនិតយកគំរូតាមយុទ្ធសាស្ត្រស្រដៀងគ្នានេះ ដែលប្រហែលជាស្របគ្នាទៅនឹងការលើកលែងទោសរបស់ ប៉ុល ពត ចំពោះអតីត "ខ្មាំង" នៅដើមឆ្នាំនោះដែរ ។ មុនឆ្នាំ១៩៧៥ ឯកសារមួយមកពីមន្ទីរ៨៧០ ដែលហៅថាគណៈកម្មាធិការមជ្ឈិមនោះ បានសន្យាអត់ឱនឲ្យអ្នកដែលបាន "ចូល សេ.អ៊ី.អា ធ្វើការឲ្យវៀតណាម ឬអ្នកដែលចូល កា.ហ្សេ.បេ" ។ អ្នកដែលធ្វើខុសក្រោយមកទៀតនឹងត្រូវចាត់ការតាមករណីជាក់ស្តែង ។

នៅឆ្នាំ១៩៧៨ដែលប្រហែលជាឆ្នាំឆ្លុះបញ្ចាំងឲ្យឃើញការប្រែប្រួលនៃវិធីសាស្ត្រនោះ មន្ទីរ ស-២១ត្រូវបានដាក់នៅក្នុងចម្លើយសារភាពមួយចំនួនថា "សាលាកែប្រែ" ជាឈ្មោះគុកនៅតាមខេត្តរបស់កម្ពុជាប្រជាធិប-តេយ្យ ។ តាមសៀវភៅកំណត់ហេតុរបស់ ប៊ុន បានបង្ហាញថា នយោបាយមួយដែលបានចាប់ផ្តើមដាក់ចេញនៅខែតុលាឆ្នាំ១៩៧៨ មិនមែនឲ្យវាយអ្នកទោសជនជាតិខ្មែរទេ ប៉ុន្តែជាការខឹងសម្បារបស់សន្តិបាលចំពោះ"ជនបរទេសដូចជាភ្នាក់ងារវៀតណាមនិងសេ.អ៊ី.អារបស់ចក្រពត្តិ" ។ តាមសម្តីរបស់ វ៉ាន់ ណាត យើងដឹងថា ចំនួនអ្នកជាប់គុកនៅមន្ទីរ ស-២១ បានធ្លាក់ចុះយ៉ាងច្រើននៅពេលនោះ ក្រោយពីការប្រារព្ធពិធីខួបបក្សកុម្មុយនិស្តកម្ពុជាលើកទី១៨ ។ ការចងចាំរបស់ វ៉ាន់ ណាត ត្រូវគ្នាទៅនឹងស្ថិតិអ្នកទោសបញ្ជូនចូលមន្ទីរ ស-២១ សម្រាប់ខែតុលានិងខែវិច្ឆិកា ។ បន្ទប់តូចសម្រាប់កម្មាភិបាលជាន់ខ្ពស់ត្រូវបានបោសសម្អាតនិងលាបថ្នាំថ្មី ហើយច្បាប់ទម្លាប់សម្រាប់អ្នកទោសធូរស្រាលទៀតផង ។ ប៊ុន បានបញ្ជាក់នៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួនថា ឥឡូវនេះមិនមានការវាយដំដើម្បីស្រង់យកចម្លើយសារភាពទៀតទេ ពោលគឺមានរហូតដល់ទៅ៨០ភាគរយនៃចំនួនអ្នកទោសទាំងអស់ឯណោះ ប៉ុន្តែបានបន្ថែមថា ប្រសិនបើធ្វើតាមទ្រឹស្តីនយោបាយ

ហើយមិនបានសម្រេចនោះ អ្នកសួរចម្លើយនៅតែប្រើវិធី «វាយដំ» តែដដែលហ្នឹង ។ ប៊ុន សរសេរនៅខែធ្នូថា «មិនមែនថាមិនវាយសោះទេ តែត្រូវវាយឲ្យតិចបំផុត» ។ នយោបាយថ្មីនេះបង្កើតឡើងមិនមែនមានន័យថានយោបាយមុនៗខុសទេ ហើយអ្នកដែលមើលការខុសត្រូវលើអំពើហិង្សាធ្ងន់ធ្ងរនៅឆ្នាំ១៩៧៧ នៅមន្ទីរស-២១នោះ ក៏នៅស្ថិតក្នុងមុខតំណែងដដែលដែរ ។ នៅក្នុងកំណត់ហេតុមួយភ្ជាប់ជាមួយចម្លើយសារភាពចុះខែធ្នូ ឆ្នាំ១៩៧៨ អ្នកសួរចម្លើយម្នាក់បាននិយាយដល់កំណែទម្រង់នេះថា «ចំពោះអ្នកទោស នៅពេលខ្ញុំប្រើនយោបាយទៅវាចង់និយាយ ប៉ុន្តែវាថាវាបានចូលសេ.អ៊ី.អាត្រឹមឆ្នាំ១៩៧៧ប៉ុណ្ណោះ ។ វានៅតែនិយាយរឿងវាដដែលៗ ។ វានិយាយហើយសរសេរចេញជាអក្សរអស់ហើយ រហូតមកដល់ឆ្នាំ១៩៧៨ ក៏វានៅតែដាក់ថាវាមិនបានក្បត់បក្សទេ ។ នៅត្រង់ចំណុចនេះខ្ញុំបានយកវាមកជិតខ្ញុំ ហើយពន្យល់ពីមាគ៌ាបក្សថ្មីថាចង់ជួយ (អ្នកទោស) ហើយសម្លុតវារួចនិយាយថាបើឯងមិននិយាយទេអញនឹងវាយមិនខាន ។ និយាយដល់ចំណុចនេះ វាក៏ព្រមបន្តនិយាយរឿងវាប្រាប់តទៅទៀត» ។

គ្មានឯកសារណាពន្យល់ពីមូលហេតុដែលនាំដល់កំណែទម្រង់បែបនេះទេ ហើយដោយសារតែគុកនេះត្រូវបិទទ្វារបន្តិចក្រោយមកនោះ វាពិបាកនិយាយណាស់ថាតើកំណែទម្រង់នេះកើតមានឡើងដោយទ្រង់ទ្រាយធំដែរឬក៏អត់ ដូចជា «ការកសាង» និងការដោះលែងអ្នកទោសមួយចំនួន ។ ប៉ុន្តែនៅពេលចុងក្រោយ បន្ទាប់ពីគុកត្រូវដល់ថ្ងៃបញ្ចប់ ការប្រហារជីវិតមនុស្សក៏នៅតែមានដដែល ហើយមុនពេលការចូលមកដល់របស់កងទ័ពវៀតណាម អ្នកទោសនៅមន្ទីរស-២១ត្រូវបានបាញ់សម្លាប់ចោលនៅនឹងកន្លែងតែម្តង ។ នៅចុងបញ្ចប់នៃសៀវភៅកំណត់ហេតុរបស់ខ្លួន ប៊ុន បានស្នើថា «តើចាំបាច់គួរបំបែកមនុស្សផ្សេងៗពីគ្នា តើគួរធ្វើទារុណកម្មពិសេស ប្រើអ្នកសួរចម្លើយពិសេស ឬប្រើវិធីផ្សេងទេ?» ។ ប្រាំខែមុននេះ អ្នកនៅពីលើ ប៊ុន បានចោទសួរសំណួរដូចគ្នានេះនៅក្នុងសៀវភៅរបស់ខ្លួនដោយឲ្យយោបល់ថា អ្នកសួរចម្លើយត្រូវតែ «មានបទពិសោធន៍» វាយដំត្រូវធ្វើឡើងទន្ទឹមនឹង«កិច្ចការ»ផ្សេងទៀត ហើយថា សុខភាពរបស់អ្នកទោសគួរតែគិតដែរ ។ ចាន់ បានបញ្ចប់កំណត់ហេតុរបស់ខ្លួនដោយស្នើថា «តើអ្នកសួរចម្លើយត្រូវវាយ (អ្នកទោស) នឹងដៃផ្ទាល់បានទេ?» ចម្លើយរបស់ ចាន់ គឺ «បើធ្វើអ៊ីចឹងមែន ធ្វើទៅតែតិចតួចបានហើយ» ។

ទោះបីជាការកែទម្រង់គំនិតនិងគំនិតរបៀបចិន-វៀតណាមទៅលើបញ្ហាយុត្តិធម៌ មានលក្ខណៈមិនដូចគ្នាទៅនឹងវប្បធម៌កម្ពុជាមុនសម័យបដិវត្តន៍ឬក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ប៉ុន្តែវាហាក់ដូចជាថា ការប្រព្រឹត្តគ្មានមេត្តាដែលធ្វើឡើងនៅមន្ទីរស-២១ បានចូលមកក្នុងប្រទេសតាមរយៈមន្ត្រីចិនម្នាក់ដែលធ្លាប់បានសង្កេតការណ៍ក្នុងតុលាការនៅទីក្រុងមូស្គូ ដែលធ្វើគ្រាន់តែល្អមើលនាទសវត្សរ៍ឆ្នាំ១៩៣០ ពោលគឺមិនមែនមកតាមរយៈវៀតណាមឬមកពីសូវៀតដោយផ្ទាល់នោះទេ ។

មន្ត្រីម្នាក់នេះមានឈ្មោះថា កាង សេង (១៨៩៨-១៩៧៥) ដែលជាអ្នករៀបចំនិងដឹកនាំដោយផ្ទាល់នូវយុទ្ធនាការអប់រំកសាងខ្លួននៅតំបន់ យ៉ានអាន ក្នុងឆ្នាំ១៩៤២និង១៩៤៣ និងការបោសសម្អាតទូទាំងប្រទេសនៅទសវត្សរ៍ឆ្នាំ១៩៥០ ។ កាង សេង គឺជាមេប៉ូលិសសម្ងាត់របស់ម៉ៅសេទុង ។ ក្រោយពីក្លាយជាមេសន្តិសុខនិងកិច្ចការស៊ើបអង្កេតរបស់បក្សកុម្មុយនិស្តចិន នៅក្នុងតំបន់គ្រប់គ្រងដោយបក្សកួកម៉េងតាំងនៅឆ្នាំ១៩៣១ កាង សេង បានទៅរស់នៅនៅប្រទេសសូវៀតរាប់ឆ្នាំ ។ នៅប្រទេសសូវៀត កាង សេង បានសិក្សាពីបញ្ហាសន្តិសុខនិងដំណើរការសួរចម្លើយរបស់សូវៀត ហើយព្រមទាំងបានឃើញការចាប់ផ្តើមវិសុទ្ធកម្មនៅទីនោះទៀតផង ។ ដោយប្រើនូវការទាក់ទងជាមួយសូវៀត កាង សេង ខ្លួនឯងបានបញ្ជាក់ថាសមាជិកមួយចំនួននៃបក្សកុម្មុយនិស្តចិនដែលត្រូវបង្ខំឲ្យចាកចោលស្រុក ត្រូវបានបោសសម្អាត ។ នៅពេលដែល កាង សេង វិលត្រឡប់មកស្រុកវិញនៅឆ្នាំ១៩៣៧ បទពិសោធន៍របស់ កាង សេង ធ្វើឲ្យប្រធានម៉ៅពេញចិត្តពេញថ្លើមយ៉ាងខ្លាំង ហើយប្រហែលក្លាយទៅជាអ្នកនាំចូលក្នុងប្រទេសចិននូវបច្ចេកទេសបោសសម្អាតតាមរបៀបសូវៀតទៀតផង ។ នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ កាង សេង ជាអ្នកកាន់កាប់ខាងសន្តិបាល ។ ពេលនោះ កាង សេង បានទទួលរហស្សនាមថា

“កាំភ្លើងខ្លីរបស់ ម៉ៅ” ហើយនៅក្នុងវិសុទ្ធកម្ម “ការកែតម្រង់” និង “ការជួយសង្គ្រោះ” នៅឆ្នាំ១៩៨២-១៩៨៣ដែល កាង សេង មើលការខុសត្រូវដោយផ្ទាល់ គឺមានលក្ខណៈឃោរឃៅ និងហ្មត់ចត់ណាស់ ។ ក្រោយពីយុទ្ធនាការទាំងនេះត្រូវបានបញ្ចប់សព្វគ្រប់ហើយ កាង សេង និយាយថា មនុស្សតិចជាង១០ ភាគរយដែល “បានឆ្លើយសារភាព” គឺពិតជាគិញនិងខ្មាំង ។ ស្ថិតក្នុងពាក់កណ្តាលវ័យចូលនិវត្តន៍ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ “កាង សេង ដែលគួរឲ្យគោរព” បានក្លាយជាមេមនោគមនៃបដិវត្តន៍វប្បធម៌ដែលមានសម្ព័ន្ធភាពជិតស្និទ្ធជាមួយនឹងក្រុមដែលគេហៅថា “បនបួននាក់” ហើយបានចូលប្រឡូកក្នុងយុទ្ធនាការវិសុទ្ធកម្មទូទាំងបក្សនៅឆ្នាំ១៩៦៧និង១៩៦៨ ។ នៅពេល កាង សេង ទទួលមរណភាពនាឆ្នាំ១៩៧៥ មានការធ្វើបុណ្យយ៉ាងអធិកអធមជាផ្លូវរដ្ឋជូនដល់វិញ្ញាណក្ខន្ធរបស់គាត់ ។ ប្រាំឆ្នាំក្រោយមក នៅពេលដែលបនបួននាក់ដួលរលំទៅ កាង សេង ត្រូវបានបណ្តេញចេញពីបក្សកុម្មុយនិស្តទាំងក្នុងព្រលឹងជាខ្មោច ។

អតីតមន្ត្រីចិនម្នាក់ដែលមានការពាក់ព័ន្ធក្នុងកិច្ចការកម្ពុជាចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៦០ បាននិយាយថា កាង សេង បានជួយយកអាសា ប៉ុល ពត នៅពេល ប៉ុល ពត ធ្វើទស្សនកិច្ចនៅទីក្រុងប៉េកាំងក្នុងឆ្នាំ១៩៦៦ ។ កាលនោះ កាង សេង ទទួលបន្ទុកខាងទំនាក់ទំនងជាមួយបក្សកុម្មុយនិស្តបរទេស ហើយឥឡូវនេះត្រូវគេស្គាល់ថាជាអ្នកគាំទ្រ អ្នកដែលយល់ស្របចំពោះការវាយប្រហាររបស់ចិនទៅលើ“លទ្ធិសេរីនិយម” របស់សូវៀត ។ នៅក្នុងអំឡុងពេលទស្សនកិច្ចរបស់ សាឡុត ស កាង សេង គឺជាសមាជិកដ៏សំខាន់របស់គណៈកម្មាធិការត្រួតពិនិត្យករណីយុត្តិសាស្ត្រ ដែលក្រោយមកដូរឈ្មោះមកជា “ក្រុមមជ្ឈិមត្រួតពិនិត្យករណីយុត្តិសាស្ត្រ” ដែលជាអង្គភាពសម្ងាត់មួយបង្កើតឡើងនៅខែឧសភាឆ្នាំ១៩៦៦ ដើម្បី“គ្រប់គ្រងវិសុទ្ធកម្មទៅលើអ្នកសេរីប្រឆាំងនឹងបដិវត្តន៍” ។ ដូច្នេះទោះជាយើងមិនដឹងថាតើកាលនោះឬក្រោយមក សាឡុត ស បានដឹងអំពីប្រព័ន្ធអង្គភាពនេះដែរឬយ៉ាងណាក៏ដោយ ប៉ុន្តែការណ៍នេះបានផ្តល់ជាគំរូដល់ស្ថាប័នមួយនៅមន្ទីរស-២១ ។

កាង សេង និង សាឡុត ស ប្រហែលជាពន្យល់គ្នាឲ្យដឹងទៅវិញទៅមកនៅក្នុងដំណើរទស្សនកិច្ចជាបន្តបន្ទាប់របស់កម្ពុជាទៅកាន់ប្រទេសចិនក្នុងឆ្នាំ១៩៧០និង១៩៧១ ។ នៅពេល កាង សេង ទទួលមរណភាពនៅឆ្នាំ១៩៧៥ មន្ត្រីចិនរូបនោះបាននិយាយថា ប៉ុល ពត បានមកធ្វើទស្សនកិច្ចនៅស្ថានទូតចិនប្រចាំនៅទីក្រុងភ្នំពេញ ដើម្បីសម្តែងនូវការរំលែកទុក្ខផ្ទាល់ខ្លួន ។ ប្រសិនបើទំនាក់ទំនងរវាង ប៉ុល ពត និង កាង សេង ពិតជាមែនមាននោះអាចជាហេតុផលគួរឲ្យជឿបានថា មន្ទីរស-២១ មានដើមកំណើតមកពីដំណើរការសន្តិសុខនិងមនោគមវិជ្ជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ និងវិសុទ្ធកម្មតាមរបៀបសូវៀត-ចិន ដែលធ្វើឡើងក្រោយមកទៀតនោះ ។

## ទារុណកម្មនៅមន្ទីរស-២១

ដោយចាំទុកក្នុងចិត្តនូវអ្វីៗដែលកើតឡើងពីមុន និងឈុតឆាកពិស្តារទាំងប៉ុន្មានខាងដើមនេះ យើងអាចវិលត្រឡប់មកពិនិត្យមើលការអនុវត្តទារុណកម្មជាក់ស្តែងនៅមន្ទីរស-២១ និងហេតុផលរបស់អ្នកធ្វើការនៅទីនោះក្នុងការធ្វើទារុណកម្ម ។ សព្វថ្ងៃនេះគ្មាននៅសល់ឯកសារណាមួយដែលនិយាយលម្អិតអំពីការធ្វើទារុណកម្មនៅក្នុងគុកនេះឡើយ ។ ដើម្បីសិក្សាអំពីបាតុភូតនេះ យើងត្រូវផ្អែកទៅលើកំណត់ហេតុរំពុកដែលនៅសល់រតាត់រតាយរបស់អ្នកសួរចម្លើយនិងថ្នាក់លើរបស់ខ្លួនបានសរសេរឆ្លងឆ្លើយគ្នា ។ កំណត់ហេតុនេះត្រូវបានបន្ថែមដោយចម្លើយសារភាពរបស់អ្នកសួរចម្លើយផ្ទាល់ ចំណារនៅតាមជាយទំព័រចម្លើយសារភាព អត្ថបទសិក្សាចំនួនបីច្បាប់ដែលសរសេរឡើងដោយកម្មាភិបាលធ្វើការនៅមន្ទីរស-២១ និងសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយដែលចងក្រងឡើងនៅឆ្នាំ១៩៧៦ ។

ឯកសារទាំងនេះមិនបានបង្ហាញពីទារុណកម្មគ្រប់បែបគ្រប់យ៉ាងដែលធ្វើឡើងនៅមន្ទីរ ស-២១ ទេ ។ ឯកសារនេះក៏មិនបានបញ្ជាក់ឲ្យបានច្បាស់ថាទារុណកម្មត្រូវធ្វើឡើងញឹកញាប់ដល់កម្រិតណា ការបង្កើតនយោបាយប៉ះពាល់ដល់ការធ្វើទារុណកម្មយ៉ាងដូចម្តេច ហើយរយៈពេលនិងទារុណកម្មដែលត្រូវធ្វើឡើងនោះក៏មិនបញ្ជាក់ច្បាស់ដែរ ។ ប៉ុន្តែវាហាក់ដូចជាថា ការ

គ្រប់គ្រងការធ្វើទារុណកម្មមិនខុសពីរឿងផ្សេងទៀតនៅក្នុងគុកទេ គឺបានក្លាយទៅជារឿងធម្មតាទៅហើយ នៅពេលដែល "ប្រព័ន្ធ"នេះចេះតែវិវត្តទៅមុខ នៅពេលអ្នកសួរចម្លើយលែងមានការស្ទាក់ស្ទើរ និងនៅពេលដែលវិធីធ្វើទារុណកម្មក្លាយទៅជាចំណង់ចំណូលចិត្តរបស់អ្នកធ្វើការនៅទីនោះ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ដូចយើងបានឃើញស្រាប់ហើយ មន្ទីរស-២១មានដំណើរការទៅយ៉ាងរលូន ។ ដោយមានបទពិសោធន៍សាកល្បងមួយឆ្នាំមកហើយ អ្នកសួរចម្លើយកាន់តែស៊ាំទាំងការ "ធ្វើនយោបាយ" និងធ្វើទារុណកម្ម ។ អ្នកទាំងអស់នេះមានគំនិតកាន់តែច្បាស់ថែមទៀតថា ការធ្វើឯកសារប្រភេទណាដែលធ្វើឲ្យថ្នាក់លើរបស់ខ្លួនពេញចិត្ត តើទារុណកម្មបែបណា "ដំណើរការល្អ" ហើយថា តើអ្នកទោសនិងចម្លើយសារភាពរបស់ខ្លួនត្រូវ"ដាក់ឲ្យដំណើរការយ៉ាងដូចម្តេចឲ្យបានលឿន ។ ពេលវេលាចេះតែរំកិលទៅមុខ ការសួរចម្លើយកាន់តែធ្វើលឿន ហើយចម្លើយសារភាពក៏កាន់តែខ្លី ។ ចម្លើយសារភាពច្រើនតែត្រូវបានថតជាខ្សែអាត់ បន្ទាប់មក យកមកវាយអង្គុលីលេខ ។ សង្ខេបលម្អិតរួចហើយយកមកភ្ជាប់ជាមួយចម្លើយសារភាពអង្គភាព យោធា តំបន់ភូមិសាស្ត្រ និង"ខ្សែក្បត់" ។ ប៉ុន្តែមិនអាចនិយាយថាតើការិយាធិបតេយ្យនៃដំណើរការទាំងមូលនៅមន្ទីរស-២១ ប៉ះពាល់ដល់កម្រិតនិងចំនួនទារុណកម្មយ៉ាងដូចម្តេចទេ ទោះបីជាយើងដឹងថាទារុណកម្មនិងការវាយដំចេះតែបន្តទៅយ៉ាងលឿននៅឆ្នាំ១៩៧៧ក៏ដោយ ។ អ្នកថតរូបម្នាក់ឈ្មោះ ញ៉ែម អេន នៅចាំបានថា ធ្លាប់ឮ "សម្រែកដង្ហោយហៅជាច្រើនលើក ជាពិសេសនៅពេលយប់ ជាពេលដែលទីក្រុងភ្នំពេញស្ងាត់ជ្រងំ គ្មានឮសម្លេងអ្វីសោះ ។ សម្រែកនេះឮខ្លាំងណាស់ សូម្បីតែនៅចម្ងាយប្រហែលមួយគីឡូម៉ែត្រក៏ឮដល់ដែរ" ។ ស្រដៀងគ្នានេះដែរ អតីតឆ្មាំគុកឈ្មោះ ខៀវ ល បាននិយាយទៅកាន់ អាឡិចសាន់ដ័រ ហ៊ីនតុន ថា "ខ្ញុំឮតែសម្រែក មិនឮនិយាយអ្វីទេ ជួនកាលទៅស្ងាត់ឈឹងតែម្តង" ។ ក្នុងកិច្ចសម្ភាសន៍ជាមួយលោក ឌូក្លាស់ នីវិន, គក ស្រស់ បាននិយាយថា "រាល់ពេលចេញទៅធ្វើការ" ខ្លួនបានឮមនុស្សស្រែកក្រោមការសួរចម្លើយ និង "ពេលណាដែលអ្នកទោសមិនធ្វើតាមឆ្មាំ" ។


ទារុណកម្មនៅមន្ទីរ ស-២១
វិចិត្រករៈ វ៉ាន់ ណាត អតីតអ្នកទោសនៅមន្ទីរ ស-២១

សម្រែកមនុស្សដែលកំពុងទទួលរងទារុណកម្មគឺបន្លឺឡើងនៅពេលមានបញ្ហាខាងរដ្ឋបាលដែលមានការសម្ងាត់ក្នុងការប្រតិបត្តិការក្នុងគុក ។ "បញ្ហារអប់រំនយោបាយ" ទុយ បានសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួន ។ "ជួនកាល

សម្លេងអ្នកទោសដែលកំពុងតែត្រូវវាយដំអាចលេចព្ធដល់ខាងក្រៅ(គុក) ទៀតផង» ។

ភាពតឹងតែងរបស់អ្នកសួរចម្លើយភាគច្រើនមិនសម្រេចបានអ្វីឡើយ ។ ក្នុងករណីជាច្រើន ទាំងអ្នកគុកនិងអ្នកសួរចម្លើយ គឺមិនបានដឹងថាតើមានការប្រព្រឹត្តអ្វីខុស ឬការឆ្លើយសារភាពមិនច្បាស់និងពិបាកយល់មានន័យយ៉ាងដូចម្តេចទេ ។ លក្ខណៈពិសេសនៃការសួរចម្លើយភាគច្រើនគឺសួរកំបុតកំបុយអំពីមូលហេតុត្រូវចាប់ខ្លួនមក និងវាយដំអ្នកដែលឆ្លើយថាមិនដឹងមូលហេតុ ។ ដោយខ្វះពត៏មានខ្លួនឯងផ្ទាល់ អ្នកសួរចម្លើយបានងាកមករកការធ្វើទារុណកម្ម ហើយដូចដែលលោក អារីស្តូតថល បានកត់សម្គាល់ដែរថា កាលពីជាងពីរពាន់ឆ្នាំមុន ចម្លើយសារភាពដែលចេញមកពីការធ្វើទារុណកម្មមានការពិតតិចណាស់ ។

អ្នកសួចម្លើយតែងតែបាត់បង់នូវការគ្រប់គ្រងខ្លួនឯង ។ ចំណង់ច្បាស់ជាមានលើសលប់នៅពេលក្មេងៗបីនាក់ប្រដាប់ដោយដំបងធំៗ ខ្សែតី ខ្សែភ្លើងសម្រាប់ឆក់ និងប្រភេទសម្ភារផ្សេងៗទៀត ត្រូវបានចាក់សោដាក់ក្នុងបន្ទប់មួយដែលមានអ្នកទោសក្បត់ជាប់ខ្នោះដៃ និងគ្មានអ្នកណាជួយ ។ ដូចលោក វ៉ូលហ្វែង សហ្វស្គី បានលើកឡើងដូច្នេះដែរថា «ប្រសិនបើអំពើឃោរឃៅត្រូវបានចាត់ទុកថាជារឿងធម្មតានៅក្នុងសហករណ៍នោះវានឹងក្លាយទៅជាកាតព្វកិច្ចទៅហើយ» ។ ម៉ា ម៉េងឃាង (ហៅរិន) អតីតអ្នកសួរចម្លើយ បានសារភាពថា អំពើឃោរឃៅគឺជារឿងចុងក្រោយបំផុតនិងមានការលើកទឹកចិត្តផង ។ រិន និយាយនៅក្នុងកិច្ចសន្ទនាធម្មតាជាមួយអ្នកធ្វើការជាមួយខ្លួនថា÷

«ពីរសប្តាហ៍ក្រោយមក...ម្នាក់ឈ្មោះ ឡឿន ម្នាក់ឈ្មោះ ស្រេង និងម្នាក់ទៀតខ្ញុំផ្ទាល់ កំពុងតែឈប់សម្រាកនិយាយគ្នាលេងនៅកន្លែងដាំបាយជាន់លើបង្អស់ (នៅមន្ទីរស-២១) ។ នៅពេលនោះ ឡឿន និយាយថា «នៅក្នុងក្រុម(សួរចម្លើយ)ទី១ ឮតែពីវ៉ៃ ទៅកន្លែងណាក៏ឮដែរ ហើយសួរ (អ្នកទោស) ថាតើឯងជាសេ (សេ.អ៊ី.អា) មែនទេ...សួរសំណួរបែបនេះតើមានអ្នកណាឆ្លើយរួច បើគេមិនស្គាល់សូម្បីតែ «សេ» ហ្នឹងតំណាងអ្វីផងនោះ ។ មិនដែលឮក្រុម១នេះ«ធ្វើនយោបាយ»ម្តងណាសោះ អ្វីដែលគេគិតនោះគឺគិតតែពីវ៉ៃ ហើយនៅពេលវ៉ៃខ្លាំងវាចេះតែឆ្លើយប៉ាតណាប៉ាតណី ចោទអ្នកនេះ ចោទអ្នកនោះ ។ នេះជាចំណុចខ្សោយរបស់ក្រុម១» ។ អាម្នាក់ឈ្មោះ សែង និយាយថានៅជិតវាក៏ឮអ៊ីចឹងដែរ ឮតែ ឡើកៗ ដាំងៗ ខ្ទប់ៗ ហើយអូយ សេឬមិនមែនសេ? នៅពេលវាមិនស្គាល់មួយណាជា«សេ»មាន់ និងមួយណាជា«សេ»ទាផងនោះ» ។

ដូចយើងឃើញស្រាប់ហើយតាមរយៈអ្វីដែលលើកមកនិយាយនេះ តុល្យភាពរវាងទារុណកម្មនិងនយោបាយភាគច្រើនមិនអាចសម្រេចទៅបានទេ ជាពិសេសពេលដែលអ្នកសួរចម្លើយមានការហ៊ឹកហាត់បានតិចពេកទាំងផ្នែកនយោបាយនិងការសួរចម្លើយ ធ្វើតាមរដ្ឋបាលពេក មានកំហឹងក្រេវក្រោលពេក និងមានបទពិសោធន៍ប្រយុទ្ធច្រើនពេក ។ រំឭកម្តងទៀតដល់សម្តីរបស់លោក ក្លសវិត ដែលថា «ធ្វើនយោបាយ»នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានន័យថាធ្វើសង្រ្គាមតាមគ្រប់មធ្យោបាយ ។ ដូចគ្នានឹងឆ្នាំក្រហមនៅប្រទេសចិនគ្រប់គ្រងដោយប្រធាន ម៉ៅ អ៊ីចឹងដែរ អ្នកសួរចម្លើយនៅមន្ទីរស-២១ត្រូវបានបង្ហាត់បង្រៀនថា «ខ្លាំង» របស់បក្សត្រូវតែ «វាយសម្រុក» «កម្ទេចចោល» ។ មិនតែប៉ុណ្ណោះនៅបានបង្រៀនថា ពួកគេជា «ដង្ហើម» របស់របបនេះទៀតផង ។ ក្រោយពីមានការហ៊ឹកហាត់ដ៏ឆ្អិនឆ្អៅស្តីអំពីពិភពសម្ងាត់ និងប្រហែលជាអំពីហេតុផលនៃមន្ទីរស-១៧រួចមក អ្នកធ្វើការនៅមន្ទីរស-២១ក៏ចាប់ផ្តើម «បោសសម្អាតខ្មាំង»ដោយដៃទទេនិងអាវុធផ្សេងៗគ្មានញញើតដៃ ។

អ្នកទោសកម្រនិយាយអំពីទារុណកម្មណាស់ ហើយសម្តីរបស់អ្នកទោសក៏មិនសូវជាមានការស្វាគមន៍ប៉ុន្មានដែរ ។ ឧទាហរណ៍ជាក់ស្តែងមួយ នៅពេល ណៃ សារ៉ន សរសេរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា «ចម្លើយរបស់ខ្ញុំនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ៧៦ ត្រូវបានផ្តល់ក្រោយពីគេធ្វើទារុណកម្មមកលើខ្ញុំយ៉ាងខ្លាំង» ឃ្លានេះត្រូវបាន ឌុច គូសខ្វែងចោល ហើយ ឌុចក៏បានផ្ញើឯកសារមួយមកវិញដែលមានសរសេរថា «ឯងគ្មានសិទ្ធិវាយការណ៍រឿងនេះមកអង្គការទេ» ។

**(នៅមានត)**

# រូបថតឯកសារ




**(តពីលេខមុន)**

**រូបទី១៥**

◆ ទឹម ហេង អាយុ១៩ឆ្នាំ (ឆ្នាំ១៩៧៧) យុទ្ធជនក្នុងកងការពារនៅមន្ទីរ ស-២១ ។ ទីកន្លែងកំណើតនៅភូមិទួលកន្ទួត ឃុំកោះធំ ស្រុក១៨ (កោះធំ) តំបន់២៥ ។ ឪពុកឈ្មោះ ទឹម ម្ដាយឈ្មោះ ដុង យុន ។ មានបងប្អូន ៧នាក់ៈ ប្រុស៤នាក់ ស្រី៣នាក់ ។ ចូលបដិវត្តន៍ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៧៤ ។ ចូលបំពេញការងារនៅមន្ទីរ ស-២១ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ។ បច្ចុប្បន្នរស់នៅខេត្តកណ្ដាល ។




**រូបទី១៦**

◆ ប៉េវ អ្នកយាមនិងចាំទទួលអ្នកទោសបញ្ជូនចូលមន្ទីរ ស-២១ ។ មកពីកងពល៧០៣ ។ ស្រុកកំណើតនៅឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។




**រូបទី១៧**

◆ យឿ ម៉ាត់ ឈ្មោះបដិវត្តន៍ ឆន អាយុ២៣ឆ្នាំ (ឆ្នាំ១៩៧៧) ជនជាតិខ្មែរឥស្លាម អនុប្រធានកងវរយការពារមន្ទីរ ស-២១ ។ ស្រុកកំណើតនៅភូមិកំពត ឃុំកំពត ស្រុកកំពត ខេត្តកំពត តំបន់៣៥ ។ ឪពុកឈ្មោះ យឿ សឹម ម្ដាយឈ្មោះ ឡេ ប៊ីល ហៅ អត ។ ចូលជួរកងទ័ពបដិវត្តនៅខែមិថុនា ឆ្នាំ១៩៧១ ។ ចូលបំពេញការងារនៅមន្ទីរ ស-២១ នៅចុងឆ្នាំ១៩៧៦ ហើយនៅខែកុម្ភៈ ឆ្នាំ១៩៧៧ ត្រូវចាប់ឃុំឃាំងនៅមន្ទីរ ស-២១ វិញ ។ (បច្ចុប្បន្នមិនដឹងស្លាប់ឬរស់) ។




**រូបទី១៨**

◆ ស៊ឹម ម៉េល ឈ្មោះបដិវត្ត ម៉ាន អាយុ២២ឆ្នាំ (ឆ្នាំ១៩៧៧) ជាជនជាតិខ្មែរឥស្លាម កើតនៅភូមិបារ៉ែន ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ។ ចូលបម្រើក្នុងជួរកងទ័ពបដិវត្តនៅខែមេសា ឆ្នាំ១៩៧១ ។ នៅខែសីហា ឆ្នាំ១៩៧៥ ចូលធ្វើការនៅមន្ទីរ ស-២១ ក្នុងកងចិញ្ចឹមសត្វនៅបឹងទំពុន ។ ខែកក្កដា ឆ្នាំ១៩៧៦ ផ្លាស់មកធ្វើការក្នុងកងសួរចម្លើយនៃមន្ទីរ ស-២១ ។ ខែសីហា ឆ្នាំ១៩៧៧ ផ្លាស់ទៅខាងកសិកម្មនៅព្រៃស (ស-២១ឃ) ។ ឪពុកឈ្មោះ សាស កើ ម្តាយឈ្មោះ គះ ។ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៧ និងត្រូវកម្ទេចនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ ។




**រូបទី១៩**

◆ គក ស្រស់ ឈ្មោះបដិវត្ត ស្រស់ កើតថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ១៩៥០ យុទ្ធជននៅក្នុងកងការពារមន្ទីរ ស-២១ ។ ស្រុកកំណើតនៅ ភូមិព្រៃកតាទៀង ឃុំជ្រោយតាកែវ ស្រុក១៨ (កោះធំ) តំបន់២៥ ។ ឪពុកឈ្មោះ ចក់ គក ម្តាយឈ្មោះ ហ៊ុន ឡូ ។ មានបងប្អូន១០នាក់ៈ ប្រុស៦នាក់ ស្រី៤នាក់ ។ ចូលបដិវត្តន៍ថ្ងៃទី ១៥ ខែមីនា ឆ្នាំ១៩៧៤ ។ ចូលបំពេញការងារនៅមន្ទីរ ស-២១ នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៧៥ ។ កម្រិតវប្បធម៌ៈ ថ្នាក់ទី៧ចាស់ ។ បច្ចុប្បន្នរស់នៅខេត្តកណ្តាល ។

**រូបទី២០**

◆ ស្រ៊ី ជាងថតរូបនៅមន្ទីរស-២១ ។ ត្រូវចាប់ខ្លួនឃុំនៅមន្ទីរ ស-២១ វិញនៅឆ្នាំ១៩៧៧ ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។




**រូបទី២១**

◆ លិញ កងការពារមន្ទីរស-២១ ។ ពីមុននៅកងពល៧០៣ ។ ត្រូវចាប់ខ្លួនដាក់នៅមន្ទីរស-២១ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ។ បច្ចុប្បន្នមិនដឹងស្លាប់ឬរស់ ។

**សាន់ កល្យាណ**



# តុលាការនៅទីម័រខាងកើត:

## ក្រុមប្រឹក្សាអ្នកច្បាប់ពិសេសខាងព្រហ្មទណ្ឌកម្រិតធ្ងន់

(តពីលេខមុន)

រូបមន្តសម្រាប់តុលាការកាត់ទោសខ្មែរក្រហមគឺថា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់មិនអាចជួយថ្នាក់លើឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះឡើយ ប្រសិនបើៈ ក) ថ្នាក់លើមានបញ្ជានិងមានការគ្រប់គ្រងជាធរមាន ឬមានអំណាចនិងការត្រួតពិនិត្យលើអ្នកនៅពីក្រោមបង្គាប់ ខ) ថ្នាក់លើបានដឹងនិងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ហៀបនឹងប្រព្រឹត្តឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ និង គ) ថ្នាក់លើមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះ ឬមិនបានដាក់ទណ្ឌកម្មទៅលើចារី ។ គួរឲ្យកត់សម្គាល់ថា ចំណុចនេះមានតម្រូវការសំខាន់ដែលថាថ្នាក់លើត្រូវតែ“មានបញ្ជានិងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព មានអំណាចនិងការត្រួតពិនិត្យ” ទៅលើអ្នកនៅពីក្រោមបង្គាប់ដែលចម្លងចេញពីលក្ខន្តិកៈច្បាប់របស់តុលាការអន្តរជាតិ ។ នេះមានន័យថាមេបញ្ជាការត្រូវតែមានអំណាចទៅលើអ្នកនៅក្រោមបង្គាប់ និងមានលទ្ធភាពបង្ការកុំឲ្យមានឧក្រិដ្ឋកម្មឬដាក់ទណ្ឌកម្មទៅលើអ្នកនៅក្រោមបង្គាប់ ។

### បញ្ជារបស់ថ្នាក់លើ

នៅក្នុងច្បាប់អន្តរជាតិមានមុខងារពីរកើតឡើងនៅក្នុងទំនាក់ទំនងទៅនឹងបញ្ហាបញ្ជាថ្នាក់លើ (ពោលគឺបទបញ្ជាចេញពីមេដឹកនាំយោធា មេដឹកនាំស៊ីវិល ឬចេញពីរដ្ឋាភិបាល) ។

១) បទបញ្ជាថ្នាក់លើមិនអាចការការពារខ្លួនបានទេ ប៉ុន្តែអាចត្រូវបានគិតពិចារណាថាជាកត្តាសម្រាលទោស ។ កត្តានេះកើតឡើងចេញពីច្បាប់តុលាការយោធាអន្តរជាតិនៅនូរិមបឹក ហើយត្រូវបានប្រើនៅក្នុងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ។

២) បទបញ្ជាថ្នាក់លើនៅក្នុងកាលៈទេសៈណាមួយ អាចបង្កើតបានជាការការពារខ្លួនបាន ។ ចំណុចនេះកើតចេញពីយុត្តិសាស្ត្រនៃសង្គ្រាមលោកលើកទី២មួយចំនួនដែលស្ថិតនៅក្រោមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដែលមានលក្ខណៈឃ្លាតឆ្ងាយពីចំណុចសំខាន់របស់ធម្មនុញ្ញតុលាការយោធាអន្តរជាតិនៅក្នុងចំណាត់ការជាមួយបុគ្គលស្ថិតក្នុងថ្នាក់ក្រោមបង្គាប់(ជនជាប់ចោទនៅតុលាការយោធាអន្តរជាតិសុទ្ធតែស្ថិតនៅក្នុងឋានៈជាថ្នាក់ដឹកនាំ) ហើយខុសពីកម្រងសៀវភៅយោធាមួយចំនួនដូចជាកម្រងសៀវភៅចុះសមរភូមិរបស់កងទ័ពអាមេរិកាំងសៀវភៅកម្រងច្បាប់កងទ័ពចក្រភពអង់គ្លេសជាដើម ។ ច្បាប់តុលាការអន្តរជាតិប្រកាន់យកជំហរបែបនេះ ។

ដូចនេះឃើញថា មានវិវាទទៅលើធាតុផ្សំនានានៃគោលការណ៍នៃបទបញ្ជាពីថ្នាក់លើនៅក្នុងច្បាប់ទម្លាប់អន្តរជាតិ ។ អ្នកធ្វើសេចក្តីព្រាងច្បាប់នៅទីម័រនិងកម្ពុជាបានជ្រើសរើសយកជម្រើសទី១ ។ ចំណុចនេះតែងតែទទួលនូវការរិះគន់ថាមានលក្ខណៈមិនប្រាកដនិយមនៅក្នុងការរៀបចំអង្គការចាត់តាំងយោធា និងសារសំខាន់ដែលវិន័យយោធាតម្រូវជាចាំបាច់ថាកូនចៅនៅក្រោមបង្គាប់ត្រូវតែស្តាប់បញ្ជាថ្នាក់លើ ។ ស្ថានការណ៍មានលក្ខណៈធ្ងន់ធ្ងរនៅពេលដែលអ្នកនៅក្រោមបង្គាប់ស្ថិតក្រោមការគាបសង្កត់យ៉ាងខ្លាំង (ដូចជានៅក្នុងការប្រយុទ្ធក្តៅគគុកជាដើម) ដែលជាស្ថានការណ៍មួយមិនអាចនាំទៅដល់ការឲ្យហេតុផលផ្អែកគំនិតក្នុងខណៈដែលខ្លួនទទួលបាននូវនីត្យានុកូលភាពនៃបញ្ជាដែលធ្លាក់មកលើខ្លួនហើយ ។ ប៉ុន្តែវាមិនមែនមិនទាក់ទងទៅនឹងច្បាប់របស់កម្ពុជាទេ ។ ច្បាប់កម្ពុជាមានគោល

បំណងកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ហេតុដូចនេះ តុលាការកម្ពុជាស្ថិតក្នុងជំហរដូចជាតុលាការយោធាអន្តរជាតិនៅនូរិមប៊ឺកដែរ ដែលនៅក្នុងតុលាការនោះ ការការពារខ្លួនរបស់ជនជាប់ចោទដោយសំអាងថាជាបញ្ជាពីថ្នាក់លើត្រូវបានបដិសេធដោយចេតនា ។ ជនជាប់ចោទទាំងអស់សុទ្ធតែស្ថិតនៅក្នុងតួនាទីជាអ្នកមានអំណាចចេញបញ្ជា ។

ទាំងនៅទីម័រខាងកើតនិងនៅប្រទេសកម្ពុជា បញ្ហាគឺកើតឡើងពីការប្រើច្បាប់ក្នុងស្រុកទាំងដុលនៅក្នុងតុលាការអន្តរជាតិដែលបំប្លែងជាតុលាការក្នុងស្រុក ។ នៅក្នុងទឹកដីទីម័រដែលស្ថិតនៅក្រោមការកាន់កាប់របស់ប្រទេសឥណ្ឌូនេស៊ី បុគ្គលម្នាក់មិនអាចត្រូវបានរកឃើញកំហុសដោយផ្អែកតាមច្បាប់របស់ប្រទេសឥណ្ឌូនេស៊ីបានឡើយ ប្រសិនបើបុគ្គលនោះធ្វើតាមបញ្ជាថ្នាក់លើនៅក្នុងកាលៈទេសៈពិសេសដូចដែលមានសម្តែងនៅក្នុងមាត្រា៥១នៃក្រមព្រហ្មទណ្ឌឥណ្ឌូនេស៊ី ។ នៅក្នុងប្រទេសកម្ពុជាក៏យ៉ាងដូច្នេះដែរ ។

ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦(មាត្រា៩៩-១០១)ចែងថាបញ្ជាពីថ្នាក់លើអាចជាសំអាងសម្រាប់ការពារខ្លួននៅក្នុងស្ថានការណ៍ជាក់លាក់មួយចំនួន ។ ដូច្នេះឃើញថាការប្រព្រឹត្តតាមបទបញ្ជាថ្នាក់លើមិនមានទោសឧក្រិដ្ឋទេទាំងនៅទីម័រខាងកើតនិងនៅប្រទេសកម្ពុជា ។ ប៉ុន្តែអ្នកធ្វើសេចក្តីព្រាងច្បាប់លេខ ២០០០/១៥ និងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមបានដកចំណុចការពារខ្លួនចោល ទោះបីជាក្នុងបទឧក្រិដ្ឋដែលត្រូវកាត់ទោសក្រោមច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធក៏ដោយ ។ មានការកត់សម្គាល់រួចមកហើយថា ច្បាប់អន្តរជាតិមិនទាន់បានដោះស្រាយឲ្យបានច្បាស់លាស់ទៅលើបញ្ហាថាបទបញ្ជាពីថ្នាក់លើជាការការពារខ្លួន សូម្បីតែទាក់ទងនឹងឧក្រិដ្ឋកម្មក្នុងដែនសមត្ថកិច្ចសកលក៏យ៉ាងដូច្នេះដែរ ។ នេះបង្កឲ្យមានបញ្ហាផ្នែកនីត្យានុកូលភាព ពីព្រោះគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ផ្នែកព្រហ្មទណ្ឌនិងសិទ្ធិមនុស្ស (សូមមើលមាត្រា១៥នៃកតិកាសញ្ញាស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ) ដែលចែងថា បុគ្គលម្នាក់មិនអាចទទួលការកាត់ទោសដោយសារអំពើដែលមិនមែនជាបទឧក្រិដ្ឋនៅពេលដែលអំពើនេះត្រូវបានប្រព្រឹត្តឡើងបានទេ ។ ជាការច្បាស់ហើយថា បុគ្គលម្នាក់អាចទាញហេតុផលថារាល់បទល្មើសសុទ្ធតែមានទោសបើគ្មានការការពារដែលអាចទទួលយកបាន ។ ប៉ុន្តែតើវាជាការត្រឹមត្រូវនិងយុត្តិធម៌ដែរឬទេដែលបុគ្គលម្នាក់ត្រូវបានបដិសេធមិនឲ្យមានការការពារខ្លួនដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់នៅពេលបទល្មើសកើតឡើង និងមិនស្របគ្នាទៅនឹងច្បាប់អន្តរជាតិ? ទោះបីជាត្រឹមត្រូវឬមិនត្រូវតាមច្បាប់យ៉ាងដូចម្តេចក៏ដោយ ប៉ុន្តែវាជាករណីជាក់ស្តែងនៅទីម័រខាងកើត ដែលនៅទីនោះជនជាប់ចោទភាគច្រើនដែលគ្មានបុគ្គលណាម្នាក់ស្ថិតក្នុងតួនាទីជាថ្នាក់ដឹកនាំ បានសារភាពថាខ្លួនពិតជាបានប្រព្រឹត្តបទល្មើសទៅលើក្រមព្រហ្មទណ្ឌឥណ្ឌូនេស៊ី ប៉ុន្តែអះអាងផ្សេងៗគ្នាថាខ្លួនធ្វើឡើងក្រោមការបង្ខិតបង្ខំ ឬនៅក្រោមបញ្ជាពីថ្នាក់លើ ។ មកដល់ពេលនេះមិនទាន់មានសាលក្រមសម្រេចឲ្យរួចខ្លួននៅឡើយទេ ។

ជនទាំងឡាយដែលជាប់ចោទពីបទឧក្រិដ្ឋកម្រិតធ្ងន់នៅទីម័រខាងកើត មានសិទ្ធិលើកឡើងនូវការការពារខ្លួនដូចបុគ្គលទាំងឡាយដែលឡើងតុលាការអន្តរជាតិដែរ ។ ប្រសិនបើមានសំអាងត្រឹមត្រូវ ការការពារខ្លួនខាងក្រោមនេះនឹងនាំទៅដល់ការរួចផុតពីការចោទប្រកាន់÷ ១)កង្វះសមត្ថភាពផ្នែកសតិ ។ ២)ការបង្ខិតបង្ខំ (អំពើនេះត្រូវបានប្រព្រឹត្តឡើងដោយសារការគំរាមកំហែងដល់អាយុជីវិត ឬការប៉ះពាល់ដល់រាងកាយជាប្រចាំ ឬដែលពិតជានឹងកើតឡើងមកលើបុគ្គលនោះឬបុគ្គលផ្សេងទៀត ហើយអំពើរបស់បុគ្គលខាងលើនេះគឺធ្វើឡើងក្នុងលក្ខណៈចាំបាច់និងសមស្រប ដើម្បីជៀសវាងការគំរាមកំហែងនេះដោយសារតែបុគ្គលនេះមិនមានចេតនាបង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរអំពើរបស់បុគ្គលដែលរិះរកធ្វើយ៉ាងណាឲ្យបានរួចខ្លួន ។ ការគំរាមកំហែងបែបនេះអាច ក)ធ្វើឡើងដោយបុគ្គលផ្សេងទៀត ឬ ខ) កើតឡើងដោយកាលៈទេសៈដែលបុគ្គលនោះមិនអាចគ្រប់គ្រងបាន) ។ ៣)ការស្រវឹងឬពុលស្រា វៀរលែងតែបុគ្គលនោះស្រវឹងឬពុលស្រាដោយចិត្តឯងនៅក្នុងស្ថានភាពដែលបុគ្គលនោះដឹងឬមិនអើពើនឹងគ្រោះថ្នាក់ដែលជាលទ្ធផលចេញពីការស្រវឹងឬពុលស្រា នោះនឹងមានន័យថា បុគ្គលម្នាក់នេះហាក់ដូចជាក្លាយជាអ្នកប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរហើយ ។ ៤)អំពើធ្វើ

ឡើងដើម្បីការពារខ្លួនមានហេតុផលសមរម្យ ដែលរួមមានការការពារអ្នកដទៃ ឬភាពចាំបាច់ផ្នែកយោធា និងសេចក្តីសំអាងពិត (សម្រាប់តែខក្រិដ្ឋសង្គ្រាមប៉ុណ្ណោះ) ។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានចែងបញ្ញត្តិនានាទាក់ទងនឹងការការពារខ្លួនទេ គឺមានតែ “១” មួយប៉ុណ្ណោះដែលហាមប្រាមមិនឲ្យប្រើការបញ្ជាពីថ្នាក់លើដើម្បីសម្រាលការទទួលខុសត្រូវជាបុគ្គល ។ ច្បាប់នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាបច្ចុប្បន្នដែលនឹងយកមកអនុវត្តនៅក្នុងតុលាការកាត់ទោសខ្មែរក្រហមមិនមានចែងអំពីការការពារខ្លួនឡើយ ទោះបីជាសេចក្តីសម្រេចចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ ដែលចេញដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ស្តីអំពីៈ “បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការៈច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល” បានចែងច្បាស់អំពីកត្តាមួយចំនួនដែលអាចសម្រាលទោសក៏ដោយ ។ ហេតុដូចនេះវាមិនមែនជាការមិនសមហេតុផលទេក្នុងការពិនិត្យទៅលើច្បាប់ដែលត្រូវបានអនុវត្តនៅពេលនោះ ពោលគឺក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦តែម្តង ។ ក្រមព្រហ្មទណ្ឌនេះបានចែងអំពីការការពារខ្លួនស្របច្បាប់ដូចតទៅនេះ÷ ១)ចរិតវិកល ឬសតិបញ្ញាមិនប្រក្រតី (មាត្រា៩០) ។ ២)អនីតិជន (អាយុតិចជាង១៨ឆ្នាំ តុលាការត្រូវសម្រេចទៅលើការយល់ដឹងខុសដឹងត្រូវរបស់បុគ្គលនោះ) (មាត្រា៩១) ។ ៣)កម្លាំងដែលមកបង្ខំ ។ គ្រោះថ្នាក់យ៉ាងធំបំផុតត្រូវធ្លាក់មកលើអ្នកណាម្នាក់ក្នុងពេលជាបន្ទាន់ក្រៃពេក មិនអាចនឹងចៀសបានដោយងាយ ហើយអ្នកមានគ្រោះនោះនឹងដោះខ្លួនឲ្យរួចពីគ្រោះនេះបានក៏លុះតែបានប្រព្រឹត្តបទល្មើសណាមួយទើបរួចខ្លួន (មាត្រា៩៧) ។ ៤)ការធ្វើតាមបង្គាប់របស់ច្បាប់ ហើយអ្នកបញ្ជាឲ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូប ។ សេចក្តីបង្គាប់ជាអនីត្យានុកូល ហើយអ្នកបញ្ជាជាអាជ្ញាធរធម្មានុរូប (មាត្រា៩៩,១០០) ។ អនុសាសន៍និងយោបល់ផ្សេងៗដែលនឹងជម្រាបជូនខាងក្រោមនេះត្រូវបានធ្វើឡើងក្នុងក្តីសង្ឃឹមថានឹងមានឆន្ទៈពិតប្រាកដក្នុងការបង្កើតយន្តការស្វែងរកយុត្តិធម៌មួយសម្រាប់អំពើឈឺចាប់ដែលគួរឲ្យព្រឺព្រួចប្រហាក់ប្រហែលនឹងអ្វីដែលប្រជាជនកម្ពុជាបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ សម្រាប់ប្រទេសកម្ពុជាវិញ ដែលមានច្បាប់កាត់ទោសខ្មែរក្រហមចូលជាធរមានហើយ ប៉ុន្តែមិនទាន់អនុវត្ត នៅតែមិនមានពេលក្នុងការអង្កេតឲ្យកាន់តែច្បាស់ទៅលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់នៅទីម័រខាងកើត ។ មេរៀននេះបើយកមកអនុវត្តបាន នឹងមានផលប្រយោជន៍ចំពោះគម្រោងការកាត់ទោសមេដឹកនាំខ្មែរក្រហមនា

**គណៈប្រតិភូទីម័រខាងកើតមកទស្សនកិច្ចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ**



កម្មាភិបាលខ្មែរក្រហម (អ្នកបកប្រែ)

ពេលខាងមុខ ។ នៅក្នុងការធ្វើសេចក្តីអង្កេតខាងក្រោមនេះ អ្នកនិពន្ធមិនបានប្រកាន់យកជំហរថាតើអង្គការសហប្រជាជាតិគួរតែចូលទៅក្នុងអនុស្សារណៈនៃការយោគយល់គ្នាឬយ៉ាងណានោះទេ ។ ក៏ប៉ុន្តែក៏គ្មានការជឿងឆ្ងល់ដែរថា ជំនួយអន្តរជាតិដ៏សន្ធឹកសន្ធាប់ មិនថាតែជំនួយមកពីសហប្រជាជាតិ ប្រទេសអ្នកផ្តល់ជំនួយ ឬអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវការជាចាំបាច់ប្រសិនបើមានឱកាស ក្នុងការធានាឲ្យប្រាកដថាការដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ពិតជាធ្វើបានទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ មានការកត់សម្គាល់ថា ការលែងឲ្យមានការបញ្ជាពីថ្នាក់លើជាលក្ខណៈការពារខ្លួនជនដែលត្រូវបានចោទប្រកាន់នៅក្នុងតុលាការខ្មែរក្រហម នឹងមានបញ្ហាមួយចំនួនទាក់ទងនឹងយុត្តិធម៌និងនីត្យានុកូលភាព ។ ពីព្រោះនៅពេលប្រព្រឹត្តបទល្មើសនេះជាការការពារខ្លួនមានសុពលភាព ។ ៥) ការការពារខ្លួនឬការពារអ្នកដទៃដូចដែលមានសម្តែងនៅក្នុងមាត្រា១០១ដល់១០៣ ។

នៅទីម័រខាងកើត ចារីប្រព្រឹត្តអំពើឃោរឃៅជាច្រើនស្ថិតក្នុងយុវវ័យ ប៉ុន្តែមិនមែនជាបញ្ហាឧក្រិដ្ឋកម្មបង្កឡើងដោយអនីតិជនដូចជាករណីនៅប្រទេសសេរ៉ាឡេអូននិងប្រទេសកម្ពុជាទេ ។ ប្រទេសសេរ៉ាឡេអូន មានបញ្ហាដោះស្រាយទៅលើអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយយុទ្ធជនដែលស្ថិតក្នុងវ័យកុមារ ហើយតុលាការពិសេសប្រទេសសេរ៉ាឡេអូនមានដែនសមត្ថកិច្ចទៅលើកុមារក្នុងចន្លោះអាយុពី១៦ដល់១៨ឆ្នាំ ។ ច្បាប់របស់តុលាការពិសេសនេះក៏បានកំណត់ច្បាស់ថា ការជ្រើសរើសកុមារឲ្យបម្រើកងទ័ព និងការប្រើយុទ្ធជនវ័យកុមារគឺជាឧក្រិដ្ឋកម្មសង្គ្រាម ។ បញ្ញត្តិនេះដកស្រង់ចេញពីច្បាប់របស់តុលាការអន្តរជាតិ ។ ទោះបីជាយ៉ាងនេះក្តី ក៏អាចមានការប្រមើលឃើញថា ក្រៅពីករណីលើកលែងទាំងនេះ ជនល្មើសភាគច្រើនដែលស្ថិតក្នុងវ័យកុមារ នឹងត្រូវដាក់នៅក្នុងដំណើរការស្វែងរកការពិតនិងការបង្រួបបង្រួមដែលដើរទន្ទឹមគ្នា ជាជាងដាក់ឲ្យតុលាការកាត់សេចក្តី ។

ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មិនបានចែងអំពីបញ្ហាអាយុទេ ។ ប្រហែលមកពីថា ចារីក្នុងវ័យកុមារទាំងអស់ដែលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ ឥឡូវនេះក្លាយជានីតិជនទៅហើយ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កុមារម្នាក់មិនអាចជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំខ្មែរក្រហម ឬអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមដែរ ។ នៅក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅពេលដែលជនជាប់ចោទម្នាក់មានអាយុក្រោម១៨ឆ្នាំ តុលាការមានសិទ្ធិពិនិត្យទៅលើសមត្ថភាពនៃការយល់ដឹង ហើយទណ្ឌកម្មនឹងមានលក្ខណៈខុសគ្នាទៅតាមកម្រិតនៃការយល់ដឹងរបស់ជនជាប់ចោទនោះ ។ នៅក្រោមច្បាប់កម្ពុជាបច្ចុប្បន្នគ្មានការកំណត់អំពីអាយុតិចបំផុតដែលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ ប៉ុន្តែជារឿយៗតែងតែមានទឡ្ហីករណ៍ថា រដ្ឋធម្មនុញ្ញកម្ពុជាមានលក្ខណៈស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិស្តីអំពីយុត្តិធម៌សម្រាប់អនីតិជន ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារថា កុមារគឺជាបុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ ។

### ឃ) នីតិវិធី

រឿងក្តីអំពើឃោរឃៅនៅទីម័រខាងកើតត្រូវបានអនុវត្តទៅតាមនីតិវិធីព្រហ្មទណ្ឌក្រោមវិធាននៃរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត ។ វិធានទាំងនេះគ្រប់គ្រងលើការអនុវត្តនីតិវិធីព្រហ្មទណ្ឌទាំងអស់ ទោះបីករណីបទល្មើសធ្ងន់ធ្ងរឬមិនធ្ងន់ធ្ងរក៏ដោយ ។ នីតិវិធីនេះយកលំនាំមួយភាគធំពីគន្លងក្រមរដ្ឋប្បវេណីដែលមានឥទ្ធិពលពីសមត្ថកិច្ចរបស់ច្បាប់កុំម៉ុនឡ និងបញ្ញត្តិមួយចំនួននៅដែលប្រើប្រាស់ក្នុងការកាត់ក្តីជាអន្តរជាតិមួយចំនួននិងតុលាការយុត្តិធម៌អន្តរជាតិ ។ ចៅក្រមស៊ើបអង្កេតដែលត្រូវបានតែងតាំងជាពិសេសទៅក្នុងក្រុមប្រឹក្សាតុលាការពិសេស ត្រូវធានាថា សិទ្ធិរបស់ជនសង្ស័យត្រូវបានការពារ និងចេញឯកសារផ្សេងៗដូចជាដីកាចាប់ខ្លួននិងដីកាធ្វើកោសល្យវិច័យលើសាកសព ។ ចៅក្រមស៊ើបអង្កេតមានអំណាចចេញបញ្ជាឲ្យមានការឃុំខ្លួនហូតដល់៦ខែ (ដោយមានរបាយការណ៍ប្រចាំខែផង) ។ ប៉ុន្តែក្រោយពីការឃុំខ្លួនដីកានេះត្រូវតែស្ថិតនៅក្រោមការពិនិត្យឡើងវិញរបស់ក្រុម

ប្រឹក្សារអគ្គចៅក្រម ។ ដីកាចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរត្រូវធ្វើឡើងនៅតុលាការស្រុកឌីលី ហើយរឿងក្តីទាំងនេះត្រូវយកមកជំនុំជម្រះនៅក្រុមប្រឹក្សាតុលាការពិសេស ។ ដូចដែលបានកត់សម្គាល់ខាងលើមកហើយថា បណ្តឹងឧទ្ធរណ៍ត្រូវដាក់ជូនសាលាឧទ្ធរណ៍ ។ វិធាននៃភ័ស្តុតាងមានលក្ខណៈធូរស្រាល÷ អ្វីដែលទាក់ទងនិងមានលក្ខណៈបង្ហាញផ្លូវគឺជាជាភ័ស្តុតាងប្រវេសនីយ (គួរឲ្យទទួល) វៀរលែងតែមានករណីលើកលែងមួយចំនួនដូចជា បទល្មើសខាងផ្លូវភេទ និងចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម ។

នីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលមិនសូវទទួលបានការពេញចិត្តនោះនឹងយកមកអនុវត្តនៅក្នុងនីតិវិធីក្រោមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ច្បាប់ដែលនឹងយកមកអនុវត្តរួមមាន រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់អ៊ុនតាក់ និងច្បាប់រដ្ឋកម្ពុជាឆ្នាំ១៩៩៣ ស្តីអំពីនីតិវិធីព្រហ្មទណ្ឌ ។ ដើម្បីពង្រឹងការការពារសិទ្ធិមនុស្សសម្រាប់ជនជាប់ចោទ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ (មាត្រា៣៥) មានគោលបំណងពង្រឹងនីតិវិធីត្រឹមត្រូវតាមច្បាប់សម្រាប់ជនជាប់ចោទ ។ មាត្រានេះមានលក្ខណៈដូចគ្នាទៅនឹងមាត្រា ១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ ។ ច្បាប់នេះក៏បានចែងទៀតថា តុលាការអាចស្វែងរកសេចក្តីណែនាំអំពីវិធាននីតិវិធីដែលបង្កើតឡើងជាកម្រិតអន្តរជាតិ ។

ដោយគ្មានសញ្ញាណបញ្ជាក់ថាមានទារុណកម្មឬការគាបសង្កត់មិនត្រឹមត្រូវពីសំណាក់អាជ្ញាធរស៊ើបអង្កេត ជនជាតិទីម័រជាច្រើនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌក្នុងអំឡុងពេលមានអំពើហិង្សានៅឆ្នាំ១៩៩៩ បានចូលខ្លួនមកសារភាពកំហុសចំពោះក្រុមប្រឹក្សាតុលាការពិសេស ។ ផ្នែក ២៩A.១ នៃច្បាប់លេខ ២០០០/១៥ របស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត ដែលជាច្បាប់ដកស្រង់ចេញពីមាត្រា៦៥នៃលក្ខន្តិកៈតុលាការអន្តរជាតិ តម្រូវឲ្យក្រុមប្រឹក្សាតុលាការពិសេសមុននឹងយកចម្លើយនេះជាការបាន លុះត្រាតែកំណត់ឲ្យបានច្បាស់ថា÷

ក) ជនជាប់ចោទយល់ជ្រួតជ្រាបច្បាស់លាស់អំពីសារជាតិនិងវិបាកនៃការចូលខ្លួនមកសារភាពទោសកំហុស ។

ខ) ការចូលខ្លួនមកសារភាពគឺត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីសំណាក់ជនត្រូវចោទប្រកាន់ ក្រោយពីមានការពិភាក្សាល្មមគ្រប់គ្រាន់ជាមួយស្នាក្តីរបស់ខ្លួន ។

គ) ការចូលខ្លួនមកសារភាពពីទោសកំហុសគឺផ្អែកលើអង្គហេតុនៃបណ្តឹងដែលមាននៅក្នុង÷ ១) ការចោទប្រកាន់ដែលជាការចោទប្រកាន់ដោយគ្មានភ័ស្តុតាងរបស់ដីកាចោទប្រកាន់និងដែលទទួលស្គាល់ដោយជនជាប់ចោទ ២) វត្ថុតាងទាំងឡាយដាក់ជូនរដ្ឋអាជ្ញាពិនិត្យ ។ វត្ថុតាងទាំងនេះជួយបញ្ជាក់ទៅលើដីកាចោទប្រកាន់ ហើយដែលជនជាប់ចោទទទួលស្គាល់ដែរ ។ ៣) ភ័ស្តុតាងផ្សេងៗទៀតដូចជាសក្ខីកម្មរបស់សាក្សីដែលដាក់ជូនរដ្ឋអាជ្ញាឬជនជាប់ចោទ ។

ផ្ទុយមកវិញ នៅប្រទេសកម្ពុជាគ្មាននីតិវិធីបែបនេះក្នុងការដោះស្រាយបញ្ហាចម្លើយការឆ្លើយទទួលកំហុសនេះទេ ។ អ្វីដែលមានគឺទំនោរយ៉ាងច្បាស់ តែថាចម្លើយជនជាប់ចោទគឺត្រូវតែបានមកពីដំណាក់កាលអង្កេតស៊ើបសួរ ជាពិសេសនៅពេលនគរបាលឃុំខ្លួន ។ ចម្លើយជនជាប់ចោទមាននៅក្នុងឯកសាររបស់នគរបាលយុត្តិធម៌ ដែលតាមផ្លូវច្បាប់ត្រូវបានចាត់ទុកថាមានតម្លៃត្រឹមត្រូវតាមច្បាប់ក្នុងករណីគ្មានភ័ស្តុតាងចុងចោទមកជំទាស់ទេនោះ ។ ជនជាប់ចោទដែលចង់ដកចម្លើយរបស់ខ្លួនមកវិញនៅពេលដំណើរការជំនុំជម្រះក្តី ពិតជាពិបាកនឹងធ្វើឲ្យតុលាការលែងយកចម្លើយនោះជាការបានណាស់ ។ របាយការណ៍ដែលបោះពុម្ពផ្សាយជាច្រើនស្តីពីប្រព័ន្ធតុលាការកម្ពុជា គឺផ្តោតសំខាន់ទៅលើការប្រើទារុណកម្មដើម្បីស្រង់យកចម្លើយសារភាព ភាពអាចទទួលយកបាននៃចម្លើយដែលធ្វើឡើងសម្រាប់នគរបាលយុត្តិធម៌ជាភ័ស្តុតាងបញ្ជាក់ពីភាពមានទោស និងសុឆន្ទៈរបស់ចៅក្រមក្នុងការទទួលយកចម្លើយទាំងនោះជាភ័ស្តុតាងសំខាន់បញ្ជាក់ពីទោសកំហុស (ករណីនេះមានតែម្តងម្កាលប៉ុណ្ណោះ) ។

## V. *រៀនសូត្រពីបទពិសោធន៍នៅទីម័រខាងកើត*

ទោះបីជាមានបញ្ហាមួយចំនួននៅក្នុងដំណើរការផ្សារដែលលើកមកបង្ហាញជូនខាងលើរួចមកហើយយ៉ាងណាក៏ដោយក៏នៅមានសក្តានុពលភាពយ៉ាងច្រើនសម្រាប់ការផ្សារសិក្សាអំពីបទព្រហ្មទណ្ឌកម្រិតធ្ងន់ដើម្បីឈានទៅសម្រេចឲ្យបាននូវយុត្តិធម៌និងការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។ តុលាការអន្តរជាតិពិសេសធ្លាប់បាននិងបន្តទទួលបាននូវការពេញចិត្តពីសំណាក់សាធារណជនទូទៅ ។ មានអ្នកខ្លះទាញហេតុផលថា តុលាការក្នុងស្រុកបំប្លែងជាតុលាការអន្តរជាតិប្រហែលជាល្អបំផុត ដែលអាចទទួលជោគជ័យដោយមានការសម្រេចចិត្តរបស់សហគមន៍អន្តរជាតិក្នុងការរកយុត្តិធម៌ដល់ប្រទេសឥណ្ឌូនេស៊ីជាប្រទេសមួយដែលបានកាន់កាប់និងប្រព្រឹត្តអំពើឃោរឃៅមកលើទឹកដីទីម័រខាងកើតអស់រយៈកាល២៤ឆ្នាំមកហើយ ។ មកទល់នឹងពេលនេះ មានដីកាចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់ចំនួន៣០ ត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលចំនួន៥០រូប ។ មានចេញសាលក្រមចំនួន១២ ដែលក្នុងនោះមានតែសាលក្រមមួយប៉ុណ្ណោះដែលចូលក្នុងករណីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ គ្មានសាលក្រមសម្រេចឲ្យរួចខ្លួននិងការលើកបណ្តឹងចោទមានពីរករណី ដោយសំអាងទៅលើបញ្ហាខាងសមត្ថកិច្ចនិងនីតិវិធី ។ មានបណ្តឹងឧទ្ធរណ៍ពីរលើកចុងក្រោយដែលចេញដោយសាលាឧទ្ធរណ៍ ។ ដីកាចាប់ខ្លួនជនជាប់ចោទមួយចំនួនទៀតត្រូវបានបញ្ជូនទៅប្រទេសឥណ្ឌូនេស៊ី ប៉ុន្តែមិនទាន់មានជនជាប់ចោទណាម្នាក់ត្រូវបានប្រគល់ខ្លួនដើម្បីជំនុំជម្រះទោសនៅតុលាការទីម័រខាងកើតនៅឡើយទេ ។

គួរលេខនេះមិនបានបញ្ជាក់ដំណើរការទាំងមូលទេ ហើយទទួលបានជោគជ័យទោះបីជាមានបញ្ហាធំៗគួរឲ្យកត់សម្គាល់យ៉ាងណាក៏ដោយ ។ ការផ្សារសិក្សាអំពីបទព្រហ្មទណ្ឌកម្រិតធ្ងន់មានបណ្ណសារមួយដែលមានបញ្ហា ។ បញ្ហាធំៗមួយចំនួនធ្វើឲ្យរារាំងដល់ការធ្វើតាមពាក្យសន្យា ហើយដែលមានទឡ្ហីករណ៍ថាវាបានធ្វើឲ្យមានអយុត្តិធម៌ចំពោះប្រជាជននៅទីម័រខាងកើត ។ រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតបានជ្រើសរើសយកទីម័រខាងកើតជាកន្លែងពិសោធន៍ក្នុងការស្វែងរកយុត្តិធម៌មានលក្ខណៈជាអន្តរជាតិ ។ ដោយមិនបានគិតពិចារណា ឬពិចារណាមិនបានដិតដល់ទៅលើធនធាននានាដែលនឹងត្រូវការជាចាំបាច់សម្រាប់ការអនុវត្តជាក់ស្តែង រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតបានបង្កើតក្តីប្រាថ្នាដ៏លើសលប់មួយ ចង់បាននូវយុត្តិធម៌តាមរយៈក្រុមប្រឹក្សាតុលាការចម្រុះរវាងចៅក្រមមូលដ្ឋាននិងចៅក្រមក្នុងស្រុកដោយចោទប្រកាន់លើរឿងក្តីដែលកសាងដោយអយ្យការអន្តរជាតិជាលើកដំបូងនៅក្នុងតុលាការស្រុកឌីលីដែលទើបតែបង្កើតថ្មីៗនេះ ដែលស្ថិតក្នុងចំណោមប្រទេសក្រីក្រជាងគេនៅលើពិភពលោក ។ សមត្ថកិច្ចលើកម្មវត្ថុដែលជាប់វិវាទនិងច្បាប់សារធាតុជាក់ស្តែងត្រូវបានដកចេញពីច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត បានបង្កើតក្រុមជំនាញស៊ើបអង្កេតមួយក្រោមការគ្រប់គ្រងរបស់អគ្គរដ្ឋអាជ្ញារងទទួលបន្ទុកព្រហ្មទណ្ឌកម្រិតធ្ងន់ដែលធ្វើការដោយឯករាជ្យដាច់ដោយឡែកពីការស៊ើបអង្កេតលើបទព្រហ្មទណ្ឌនានា ។


អ្នកទោសនៅមន្ទីរ ស-២១


អ្នកសួរចម្លើយនៅមន្ទីរ ស-២១

ចាប់តាំងពីចុងឆ្នាំ២០០០មក អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនិងក្នុងស្រុក សាធារណជន ប្រព័ន្ធឃោសនា និងគណៈកម្មការរបស់អង្គការសហប្រជាជាតិ (ជាអាទិ៍ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ និងអគ្គស្នងការជាន់ខ្ពស់

ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស) បានលើកឡើងម្តងហើយម្តងទៀតនូវការព្រួយបារម្ភរបស់ខ្លួនចំពោះការខ្វះការគាំទ្រឲ្យបានមាំទាំងចំពោះការស៊ើបអង្កេតនិងការចោទប្រកាន់ទៅលើបទព្រហ្មទណ្ឌកម្រិតធ្ងន់ ដែលជាចំណុចខ្សោយមិនមានប្រសិទ្ធភាព និងកិច្ចការផ្សេងៗទៀតដែលត្រូវបានធ្វើឡើងទៅតាមគន្លងចាស់ដែលប្រតិបត្តិកន្លងមក ។ «ការងារចុះស្រាវជ្រាវពីបទព្រហ្មទណ្ឌកម្រិតធ្ងន់» ត្រូវបានចាត់ទុកជាទូទៅថាបានខកខានមិនបាននាំមកនូវយុត្តិធម៌សម្រាប់ប្រជាជននៅទីម័រខាងកើត ហើយ «ការងាររបស់គម្រោង» នេះត្រូវបានលើកឡើងជាសំអាងសម្រាប់ឲ្យមានការបង្កើតឡើងនូវតុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសមួយ ។ រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត បានប្រគល់អំណាចឲ្យមានការស៊ើបអង្កេតផ្ទៃក្នុង ប៉ុន្តែត្រូវទទួលបរាជ័យដែលមិនអាចពន្យល់បានក្នុងការប្រតិបត្តិតាមអនុសាសន៍ដែលត្រូវបានធ្វើឡើងនិងបណ្តោយឲ្យសភាពការណ៍បែបនេះបន្តកើតឡើងទៅមុខទៀត ។ ការណ៍នេះនាំឲ្យមានបុគ្គលជាច្រើនទាញសេចក្តីសន្និដ្ឋានថា យុត្តិធម៌និងនីតិរដ្ឋសម្រាប់ទឹកដីទីម័រខាងកើតមិនមែនជាអាទិភាពរបស់បេសកកម្មរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតទេ ។

ក៏ប៉ុន្តែឥឡូវនេះ រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតបានចាប់ផ្តើមដោះស្រាយបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាដែលនាំឲ្យមានកម្សោយនៃការងារព្រហ្មទណ្ឌកម្រិតធ្ងន់នេះ ។ អនុប្រធានថ្មីនៃតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (អេស.អ.អេស.ជី) បានចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាដែលកើតឡើងទាំងអស់នេះ ។ ឥឡូវនេះ ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ត្រូវបានដាក់ឲ្យនៅក្រៅពីការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ហើយកំពុងតែស្ថិតនៅក្រោមការគ្រប់គ្រងចាត់ចែងរបស់ អេស.អ.អេស.ជី ។ ចុងបញ្ចប់មានប្រភពគ្រប់គ្រាន់និងមាំទាំ ហើយមានការបើកការិយាល័យនៅតាមស្រុកនានានៅតាមទីជនបទនៃទឹកដីទីម័រ ។ ឥឡូវនេះ រដ្ឋអាជ្ញាមានសិទ្ធិគ្រប់គ្រងចាត់ចែងការស៊ើបអង្កេតដោយផ្ទាល់ ។ មានសមាសភាពថ្នាក់ដឹកនាំថ្មីនៅក្រសួងយុត្តិធម៌និងអយ្យការ ដែលរួមមានការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ផង ។

ចំណុចទាំងនេះគឺជាការផ្លាស់ប្តូរដែលមើលទៅអាចនាំមកនូវលទ្ធផលវិជ្ជមាន ប៉ុន្តែមិនទាន់អាចនិយាយបានទេ គឺចាំមើលសិន តើលទ្ធផលអ្វីខ្លះដែលចេញពីការផ្លាស់ប្តូរនេះនៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនៃអាណត្តិរបស់គម្រោងការងារនេះ (អាណត្តិរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតមានរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែការងារព្រហ្មទណ្ឌកម្រិតធ្ងន់នឹងនៅត្រូវបន្តគ្រប់គ្រងដោយអ្នកស្នងបេសកកម្មរហូតដល់ពាក់កណ្តាលឆ្នាំ២០០៣) ។

អនុសាសន៍និងយោបល់ផ្សេងៗដែលនឹងជម្រាបជូនខាងក្រោមនេះ ត្រូវបានធ្វើឡើងក្នុងក្តីសង្ឃឹមថានឹងមានឆន្ទៈពិតប្រាកដ ក្នុងការបង្កើតយន្តការស្វែងរកយុត្តិធម៌មួយសម្រាប់អំពើឈឺចាប់ដែលគួរឲ្យព្រឺព្រួចប្រហាក់ប្រហែលនឹងអ្វីដែលប្រជាជនកម្ពុជាបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ សម្រាប់ប្រទេសកម្ពុជាវិញដែលមានច្បាប់កាត់ទោសខ្មែរក្រហមចូលជាធរមានហើយ ប៉ុន្តែមិនទាន់អនុវត្ត នៅតែមិនមានពេលក្នុងការអង្កេតឲ្យកាន់តែច្បាស់ទៅលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់នៅទីម័រខាងកើត ។ មេរៀននេះបើយកមកអនុវត្តបាន នឹងមានផលប្រយោជន៍ចំពោះគម្រោងការកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលខាងមុខ ។

នៅក្នុងការធ្វើសេចក្តីអង្កេតខាងក្រោមនេះ អ្នកនិពន្ធមិនបានប្រកាន់យកជំហរថាតើអង្គការសហប្រជាជាតិគួរតែចូលទៅក្នុងអនុស្សរណៈនៃការយោគយល់គ្នាឬយ៉ាងណានោះទេ ។ ក៏ប៉ុន្តែក៏គ្មានការងឿងឆ្ងល់ដែរថា ជំនួយអន្តរជាតិដ៏សន្ធឹកសន្ធាប់ មិនថាតែជំនួយមកពីសហប្រជាជាតិ ប្រទេសអ្នកផ្តល់ជំនួយ ឬអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវការជាចាំបាច់ប្រសិនបើមានឱកាសក្នុងការធានាឲ្យប្រាកដថាការដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមពិតជាធ្វើបានទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។

**(នៅមានត)**

**ស៊ុហ្សាណា លីនតុន**

# ការវិភាគទៅលើសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ ដែលឈប់ចរចាជាមួយរដ្ឋាភិបាលកម្ពុជា អំពីដំណើរការបង្កើតតុលាការចម្រុះកាត់ទោសមេដឹកនាំខ្មែរក្រហម

អង្គការសហប្រជាជាតិបានធ្វើការសម្រេចចិត្តដ៏ឈ្លាសវៃក្នុងការដកថយពីការចរចាជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើតអ្វីដែលហៅថា «តុលាការចម្រុះ» ក្នុងគោលបំណងកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ហេតុផលមួយដែលធ្វើឲ្យរដ្ឋាភិបាលកម្ពុជាសុំការជួយជ្រោមជ្រែងពីសំណាក់អង្គការសហប្រជាជាតិ ដើម្បីនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស គឺគ្រាន់តែជាមធ្យោបាយមួយនៅក្នុងការដើរក្រឡាអុកចុងក្រោយជាមួយទាហានខ្មែរក្រហមដែលនៅសេសសល់តែប៉ុណ្ណោះ ។ នៅពេលដែលខ្លួនដោះស្រាយជាមួយមេដឹកនាំខ្មែរក្រហមភាគច្រើន និងចាប់បាន តាម៉ុក ហើយនោះ រដ្ឋាភិបាលកម្ពុជាចាប់ផ្តើមដកថយចេញពីអ្វីដែលខ្លួនបានសន្យាថានឹងស្វែងរកយុត្តិធម៌ ។ ក្រោយហេតុការណ៍ទាំងនេះកើតឡើងរួចមក រដ្ឋាភិបាលកម្ពុជាយល់ឃើញថាខ្លួនឯងមានបញ្ហាជាមួយគំនិតបង្កើតតុលាការ ហើយនៅពេលដែលអង្គការសហប្រជាជាតិបន្តធ្វើការជាមួយក្នុងឆន្ទៈល្អដើម្បីរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជា រដ្ឋាភិបាលកម្ពុជាក៏ចាប់ផ្តើមចរចាយ៉ាងគំហុក ដើម្បីបញ្ចៀសកុំឲ្យមានតុលាការដែលអាចកើតមានឡើងនៅពេលខាងមុខ ដែលខ្លួនលែងត្រូវការប្រើប្រាស់ និងដែលខ្លួនមិនអាចគ្រប់គ្រងបាន ។

បន្ទាប់មកចូលដល់រឿងប្រព័ន្ធតុលាការ«ចម្រុះ»ដែលមានការចូលរួមពីសំណាក់ចៅក្រមខ្មែរដែលជាចំណាប់ខ្មាំងនយោបាយ និងចៅក្រមបរទេសដែលតែងតាំងដោយអង្គការសហប្រជាជាតិ ។ (បើខ្ញុំមិនច្រឡំទេគឺថា តុលាការកម្ពុជាសព្វថ្ងៃនឹងធ្វើអ្វីៗតាមតែគេបង្គាប់ ពោលគឺបញ្ហាពាក់ព័ន្ធនឹងអ្នកមានអំណាច ។ ប្រសិនបើមិនធ្វើដូច្នេះទេ ចៅក្រមទាំងនេះនឹងត្រូវដកចេញពីការងារជាមិនខាន ។ រឿងមានតែប៉ុណ្ណឹង ។ កាលពីមុនខ្ញុំមានការភ័ន្តច្រឡំថា រឿងសំខាន់(កាត់ក្តីមេដឹកនាំនៃរបបខ្មែរក្រហម) ដល់ថ្នាក់នេះហើយ ចៅក្រមកម្ពុជាពិតជានឹងធ្វើទៅតាមមនសិការរបស់ខ្លួនមិនខាន ។ ប៉ុន្តែបទពិសោធន៍របស់ខ្ញុំធ្វើកិច្ចការជាមួយតុលាការកម្ពុជា និងបុគ្គលមួយចំនួនដែលយល់ច្បាស់ពីបញ្ហានេះបានពន្យល់ប្រាប់ខ្ញុំ ធ្វើឲ្យខ្ញុំលែងមានការយល់ច្រឡំតទៅទៀត) ។ ដើម្បីធានាឲ្យច្បាស់ថា គ្មានការផ្តន្ទាទោសណាដែលរដ្ឋាភិបាលកម្ពុជាមិនយល់ព្រមនោះ ចៅក្រមខ្មែរនឹងមានចំនួនច្រើនជាងចៅក្រមបរទេសនៅសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ ក្រៅពីនេះមានគេប្រាប់ខ្ញុំថា រាល់ការសម្រេចផ្សេងៗត្រូវតែធ្វើតាម «២» ដែលមានចែង គឺ«មតិភាគច្រើនលើសលប់» ដែលអាចឲ្យចៅក្រមបរទេសអាចប្រើសិទ្ធិជំទាស់ ដោយតម្រូវថាយ៉ាងហោចណាស់ត្រូវមានសម្លេងគាំទ្រមួយជាមួយមតិភាគច្រើន ទើបសេចក្តីសម្រេចរួមមួយមានសុពលភាពបាន ។ (អ្វីដែលអ្នកគាំទ្រ «២» ចែងពីមតិភាគច្រើនលើសលប់មិនបានលើកឡើងនោះគឺថា «សំឡេងស្មើគ្នា» រវាងចៅក្រមខ្មែរនិងចៅក្រមបរទេសនៅគ្រប់តុលាការទាំងបីកម្រិតអាចនាំឲ្យមានសាលក្រមសម្រេចឲ្យរួចខ្លួនបាន) ។

ត្រូវតែមានតុលាការអន្តរជាតិដើម្បីកាត់ទោសជនដៃដល់ដែលបានរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដរាបណាឆន្ទៈនយោបាយដែលនឹងនាំឲ្យមានយុត្តិធម៌នោះមិនទាន់មានគ្រប់គ្រាន់នៅក្នុងចំណោមរដ្ឋដែលមានការពាក់ព័ន្ធ ។ ឧទាហរណ៍ដ៏ល្អមួយគឺអតីតប្រទេសយូហ្គោស្លាវីនាពេលថ្មីៗនេះ ។ ក៏ប៉ុន្តែនៅពេលដែលមានឆន្ទៈនយោបាយរកយុត្តិធម៌ពិតជាមានមែន ហើយជនដៃដល់ចូលមកបង្ហាញខ្លួនចំពោះមុខតុលាការក្នុងស្រុករបស់រដ្ឋដែល

ពាក់ព័ន្ធ គឺមិនចាំបាច់បង្កើតតុលាការអន្តរជាតិដើម្បីធានាយុត្តិធម៌នោះទេ ។ ចំណុចដែលត្រូវកត់សម្គាល់គឺថា តើមានឆន្ទៈនយោបាយដែរឬទេ ។

មានមន្ទិលសង្ស័យបន្តិចបន្តួចថា ឆន្ទៈនយោបាយដែលជាការចាំបាច់ក្នុងការនាំយកឧក្រិដ្ឋជនមកកាត់ទោស គឺបាននិងកំពុងតែមានលក្ខណៈមិនគ្រប់គ្រាន់នៅក្នុងខ្លួនរដ្ឋាភិបាលសព្វថ្ងៃដែលមានការខ្វាយខ្វល់តែអំពីរឿងរក្សាអំណាចក្នុងស្រុក និងការបង្កើតធម្មានុរូបអន្តរជាតិ ។ ការរៀបចំកាត់ទោសមេដឹកនាំខ្មែរក្រហមក្រោមច្បាប់គ្រប់គ្រងសព្វថ្ងៃ គឺរដ្ឋាភិបាលមានបំណងគាំទ្រការបង្កើតធម្មានុរូបអន្តរជាតិអូសបន្លាយពេលវេលា ។ ធ្វើយ៉ាងដូច្នេះគឺដើម្បីរក្សាការគ្រប់គ្រងទៅលើលទ្ធផលចេញពីតុលាការនោះ ។ និយាយឲ្យខ្លីមានន័យថា រដ្ឋាភិបាលកម្ពុជាចង់បានតុលាការបែបផែននយោបាយមួយដែលធ្វើឡើងគ្រាន់តែឲ្យល្អមើលប៉ុណ្ណោះ ពោលគឺធ្វើឲ្យដំណើរការកាត់ក្តីមានលក្ខណៈអឹកធឹកតែសំបកក្រៅ ហើយយកការគាំទ្ររបស់អង្គការសហប្រជាជាតិធ្វើជាតែមបិទពីក្រៅ ។ អង្គការសហប្រជាជាតិបដិសេធមិនចូលរួមជាមួយដំណើរការខាងលើនេះជាការត្រឹមត្រូវឥតខ្ចោះ ។ ប្រសិនបើរដ្ឋាភិបាលកម្ពុជាចង់រៀបចំតុលាការកាត់ទោសខ្មែរក្រហមដែលអំណាចគ្រប់គ្រងទាំងអស់ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ខ្លួន ទាំងកាត់ឲ្យជាប់ទោសនិងការដោះលែងតាមតែខ្លួនយល់ឃើញថាសមស្របចំពោះខ្លួននោះ រដ្ឋាភិបាលកម្ពុជាគួរធ្វើតែម្នាក់ឯង ។ ផ្ទុយមកវិញ ប្រសិនបើរដ្ឋាភិបាលកម្ពុជាមានបំណងចង់រៀបចំតុលាការដែលគ្មានសម្ពាធនយោបាយរដ្ឋាភិបាលមានសេរីភាពដូចគ្នា ហើយគួរតែមានកិច្ចសហ-ប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ ។

ចំពោះអ្នកដែលយល់ថាតុលាការដែលគ្មានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិនឹងគ្មានធម្មានុរូបនោះ ចម្លើយគឺ "មិនបាច់ក៏បាន" ។ បញ្ហានៃការចូលរួមរបស់អង្គការសហប្រជាជាតិ គឺមិនមែនដើម្បីផ្តល់នូវភាពស្របច្បាប់ចំពោះដំណើរការកាត់ក្តីដែលមិនមានលក្ខណៈស្របច្បាប់នោះទេ ប៉ុន្តែដើម្បីធានាថាដំណើរការនោះធ្វើឡើងប្រកបដោយភាពស្របច្បាប់ ។ នេះជាចំណុចសំខាន់ដែលអ្នកសម្តែងការមិនយល់ព្រមចំពោះការសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ លាងដៃលែងចូលរួមជាមួយរឿងស្មុគស្មាញនេះ ហាក់ដូចជាភ្លេចគិតដល់ ។ (យ៉ាងហោចណាស់មានបុគ្គលម្នាក់សង្ឃឹមថាពិតជាដូច្នេះមែន ហើយថាគំនិតគ្រប់គ្រងរបស់មន្ត្រីទាំងនេះមិនមែនដូច្នេះទេ ពីព្រោះមេដឹកនាំខ្មែរក្រហមធ្វើយ៉ាងដូចម្តេចក៏នៅតែមានកំហុសដែរ តើមានអ្វីខុសគ្នាទៅប្រសិនបើមេដឹកនាំខ្មែរក្រហមទាំងនោះត្រូវកាត់ឲ្យជាប់ទោសទៅតាមច្បាប់ឬក្រឹត្យរបស់រដ្ឋាភិបាលនោះ) ។ ការជំនុំជម្រះក្តីមានលក្ខណៈស្របច្បាប់នឹងមិនអាចធ្វើទៅរួចទេ ទោះជាក្រោមទម្រង់ការបែបណាក៏ដោយ ដែលមានតុលាការកម្ពុជាមានតួនាទីជាអ្នកគ្រប់គ្រងនោះ ។ ការរៀបចំបង្កើតតុលាការដែលគួរឲ្យអាម៉ាស់ក្រោមច្បាប់កាត់ទោសខ្មែរក្រហមសព្វថ្ងៃនេះ វាមិនខុសអ្វីជាងការធ្វើឲ្យកាន់តែខូចប្រយោជន៍របស់អ្នកដែលរងការឈឺចាប់និងស្លាប់បាត់បង់ជីវិតយ៉ាងវេទនានោះទេ ។ សុខចិត្តគ្មានតុលាការវាប្រសើរជាងមានតុលាការដែលមានបែបផែនរបៀបនេះ ។

ខ្ញុំធ្លាប់ធ្វើការជាមួយប្រជាជនកម្ពុជា ខ្ញុំដឹងថាប្រជាជនទាំងនេះជាអ្នករួចផុតពីសេចក្តីស្លាប់ជំនាន់ខ្មែរក្រហម ។ ជនរងគ្រោះទាំងនេះមានការភ័ន្តច្រឡំទៅលើការព្រួយបារម្ភរបស់ថ្នាក់ដឹកនាំរបស់ខ្លួន ដែលតាំងពីមុនក៏ដូចជាឥឡូវគឺមិនមែនបញ្ហាយុត្តិធម៌ទេ ប៉ុន្តែគឺជាការរក្សាឯកសិទ្ធិនិងអំណាចឲ្យនៅថិតថេរ ។ មូលហេតុនេះហើយបានជាប្រជាជនកម្ពុជាបាននិងកំពុងទន្ទឹងរង់ចាំតុលាការអន្តរជាតិពិតប្រាកដមួយដើម្បីវិនិច្ឆ័យទោសឧក្រិដ្ឋជនខ្មែរក្រហម ។ រដ្ឋាភិបាលកម្ពុជាបាននិងកំពុងរៀបចំដើងព្រួលយ៉ាងមាំទាំដើម្បីឲ្យបានតែមស្របច្បាប់បិទពីលើដំណើរការតុលាការដែលមិនស្របច្បាប់ ។ អង្គការសហប្រជាជាតិនិងប្រទេសដែលគោរពនីតិរដ្ឋ មិនគួរបន្តជួយជ្រោមជ្រែងការរៀបចំក្រឡាអុកនេះទៀតឡើយ ។ ប្រសិនបើអ្នកដឹកនាំនយោបាយកម្ពុជាចង់ធ្វើការដោយសុទ្ធចិត្ត ដើម្បីបង្កើតតុលាការមួយដែលមានឯករាជ្យពិតប្រាកដដើម្បីស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា អង្គការសហប្រជាជាតិគួរតែបើកទ្វារចំហរជានិច្ច ។

**រ៉ោម៉ិន ចូហាន់សាន់**

## ចរិតអង្គការសហប្រជាជាតិៈ

# តើការលើកលែងទោសជាតម្លៃនៃសន្តិភាពនៅកម្ពុជា?

នៅក្នុងខណៈដែលការជំនុំជម្រះក្តី មីឡូសីវិច បានចាប់ផ្តើម នោះ មានអ្នកខ្លះនិយាយថានេះគឺជាការចាប់ផ្តើម“សករាជថ្មីនៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់អន្តរជាតិ” ។ នៅថ្ងៃទី៨ ខែកុម្ភៈ ក្រោយពីមានការចរចាអស់រយៈពេល៤ឆ្នាំកន្លះ អង្គការសហប្រជាជាតិបានប្រកាសថាខ្លួនឈប់ចូលរួមនៅក្នុងដំណើរការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមនៅកម្ពុជាទៀតហើយ ។ វាជាការងាយពេកហើយដែលត្រូវទម្លាក់កំហុសទៅលើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នោះ ។ បញ្ហាដែលធ្វើឲ្យការពិភាក្សាផ្លូវច្បាប់ទាល់ច្រកគឺការទាមទារទៅវិញទៅមករវាងអធិបតេយ្យភាពជាតិនិងសិទ្ធិមនុស្សជាសាកល ។ ប្រសិនបើយើងបានចូលដល់សករាជថ្មីនៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់អន្តរជាតិ វាមើលទៅមានលក្ខណៈដូចគ្នាគួរឲ្យកត់សម្គាល់ទៅនឹងទ្រឹស្តីដែលថាច្បាប់អនុវត្តបានតែចំពោះបុគ្គលមួយចំនួនប៉ុណ្ណោះ ។

ក្នុងចន្លោះឆ្នាំ១៩៧៥និង១៩៧៩ យ៉ាងហោចណាស់មានប្រជាជនពីរលាននាក់បានស្លាប់ដោយសារការដកពិសោធន៍របស់ខ្មែរក្រហមតាមបែបកុម្មុយនិស្តចាស់គំរិល ។ ក្រោយពីវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ តើអង្គការសហប្រជាជាតិ ឬរដ្ឋការលោក ជីមី ខាតធ័រ បានគាំទ្ររាល់កិច្ចខិតខំប្រឹងប្រែងនាំយកខ្មែរក្រហមមកកាត់ទោសដែរឬទេ? ចម្លើយគឺទេ ។ សហរដ្ឋអាមេរិកបានបោះឆ្នោតគាំទ្រម្តងហើយម្តងទៀត ដើម្បីឲ្យរបបប្រល័យពូជសាសន៍រក្សាអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ។ ទោះបី អៀង សារី ត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខនៅឆ្នាំ១៩៧៩ក៏ពិតមែន ប៉ុន្តែ អៀង សារី នៅតែធ្វើជាតំណាងរបស់កម្ពុជានៅអង្គការសហប្រជាជាតិដដែល ។ ការពិភាក្សាយកជាសាច់ការស៊ីជម្រៅអំពីការកាត់ទោស ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមដទៃទៀតទើបតែចេញរូបរាងនៅឆ្នាំ១៩៩០-៩១ នៅពេលដែលមេដឹកនាំអាស៊ានចង់ចរចាអំពីបញ្ហាអនុសញ្ញាមួយដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ។ សម្តេច ហ៊ុន សែន ធ្វើជាតំណាងខាងភាគីកម្ពុជាក្នុងកិច្ចចរចានេះ ។ សម្តេចមានប្រសាសន៍ថា “ខ្ញុំនៅតែចងចាំទាំងការឈឺចាប់ថា នៅឆ្នាំ១៩៩០-៩១... ខ្ញុំតែម្នាក់ឯងគត់ដែលនិយាយហើយនិយាយទៀតអំពីពាក្យថា “ប្រល័យពូជសាសន៍” ប៉ុន្តែខ្ញុំត្រូវបានវាយប្រហារនិងចោទថាជាមនុស្សដែលគ្មានសុឆន្ទៈក្នុងការបញ្ចប់សង្គ្រាម” ។ ពេលសន្ធិសញ្ញាទីក្រុងប៉ារីសត្រូវបានចុះហត្ថលេខានៅឆ្នាំ១៩៩១ គ្មានការលើកឡើងពីអំពើប្រល័យពូជសាសន៍ឡើយ ។ ជាការច្បាស់ណាស់ អង្គការសហប្រជាជាតិ ឬ “សមត្ថកិច្ចសាកល” ធ្វើអ្វីខ្មែរក្រហមមិនបានឡើយ មានតែចំណាត់ការផ្នែកនយោបាយដាច់អហង្ការរបស់សម្តេច ហ៊ុន សែន ក្នុងឆ្នាំ១៩៩៦និង១៩៩៧ តែប៉ុណ្ណោះ ដែលធ្វើឲ្យខ្មែរក្រហមបរាជ័យ ។ សម្តេចបានផ្តល់ការលើកលែងទោសដល់មេដឹកនាំខ្មែរក្រហមនិងអ្នកចុះចូលមួយចំនួនទៀតក្នុងឆ្នាំ១៩៩៦និង១៩៩៧ ដោយមានការជំទាស់ពីសំណាក់រដ្ឋាភិបាល និងក្រុមអ្នកសិទ្ធិមនុស្សលោកខាងលិច ។ ការចុះចូលទាំងនេះ និងមរណភាពរបស់ ប៉ុល ពត បានរុញច្រានបញ្ហាឧក្រិដ្ឋកម្មសង្គ្រាមឲ្យលេចធ្លោនៅឆ្នាំ១៩៩៨ ។ នៅឆ្នាំ១៩៩៩ ពេលដែលអង្គការសហប្រជាជាតិស្នើចង់ឲ្យមានការជំនុំជម្រះក្តីនៅប្រទេសទីបី និងរៀបចំដំណើរការទាំងមូលក្រោម

ការចាត់ចែងជ្រោមជ្រែងរបស់អង្គការសហប្រជាជាតិ សម្តេច ហ៊ុន សែន បានបដិសេធយ៉ាងដាច់អហង្ការ ដោយមានប្រសាសន៍ថា «ខ្ញុំគិតថានេះជាសម្តីរបស់អ្នកច្បាប់ ។ អ្នកច្បាប់គឺអ្នកច្បាប់ ។ ខ្ញុំគោរពទឡ្ហីករណ៍ដែលអ្នកច្បាប់លើកឡើង ។ អ្នកច្បាប់មិនមែនជាអ្នកនយោបាយ» ។ សំខាន់ជាងនេះទៅទៀត សម្តេចនាយករដ្ឋមន្ត្រី បានបដិសេធការទាញសន្និដ្ឋានថា នេះគឺជាបញ្ហាច្បាប់ ។ «ដូច្នេះប្រសិនបើអ្នកច្បាប់បានផ្លាស់ប្តូរទាំងផ្នែកសីលធម៌និងនយោបាយ ខ្ញុំគិតថាគេគួរតែឈប់ធ្វើជាអ្នកច្បាប់ ហើយចូលមកធ្វើការខាងនយោបាយវិញ» ។ បញ្ហាសំខាន់ដែលមិនទាន់ដោះស្រាយបានរវាងអង្គការសហប្រជាជាតិនិងកម្ពុជា គឺជាបញ្ហាមួយក្នុងចំណោមបញ្ហានយោបាយអន្តរជាតិៈ តើ«សមត្ថកិច្ចសកល»យកឈ្នះលើអធិបតេយ្យភាពជាតិបានដែរឬទេ? អតីតឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា តូនី ខេវិន បានចោទអង្គការសហប្រជាជាតិថាបានប៉ុនប៉ងទាំងបង្ខំមកលើកម្ពុជា ។ លោកមានប្រសាសន៍ថា «ការប្រព្រឹត្តដោយការមើលងាយបែបនេះ ចំពោះការអះអាងស្របច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា គឺអង្គការសហប្រជាជាតិកំពុងតែសម្របខ្លួនតាមការយល់ឃើញជាអន្តរជាតិដែលកំពុងតែមានឥទ្ធិពលជាពិសេសនៅអឺរ៉ុបនិងអាមេរិកខាងជើង ដែលថាសិទ្ធិមនុស្សជាលក្ខណៈបុគ្គល វាមានសារសំខាន់ជាងអធិបតេយ្យជាតិរបស់រដ្ឋនានានៅក្នុងតតិយលោកទៅទៀត» ។

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិដែលបានទទួលការគាំទ្រពីសំណាក់មជ្ឈដ្ឋានសិទ្ធិមនុស្ស បានជំរុញឲ្យមានសណ្តាប់ធ្នាប់ថ្មីមួយដោយផ្អែកលើវិធានសម្រាប់ដឹកនាំប្រទេសដែលប្រឆាំងជាមួយនឹងភាពមិនអាចរំលោភបាននៃអធិបតេយ្យជាតិ ។ ការមិនគួរឲ្យកើតឡើងនោះគឺថា ក្នុងខណៈដែលក្រុមធ្វើការខាងសិទ្ធិមនុស្សនិងអ្នកច្បាប់ស៊ីវិលកំណត់និងពង្រីកក្រុមថ្មីនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មេដឹកនាំលោកខាងលិចមិនអាចប្រមូលផ្តុំសេចក្តីសម្រេចដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ឡើយ ។ ក្នុងពេលដែលវិធាននានាសរសេរនៅក្នុងសៀវភៅទាំងនោះមានលក្ខណៈទូលំទូលាយជាងពេលណាៗទាំងអស់នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិនោះ ភាពខុសគ្នាដ៏សំខាន់ទាំងច្បាប់ចេញពីទំនៀមទម្លាប់និងក្រមច្បាប់សង្គ្រាមដែលបញ្ជាក់ពីការខុសគ្នារវាងទាហាននិងជនស៊ីវិល ស្ទើរតែជិតបាត់ស្រមោលទៅហើយនៅតាមកន្លែងមួយចំនួនដូចជានៅអតីតយូហ្គោស្លាវី រ៉្វាន់ដា ទីម័រខាងកើត និងសេរ៉ាឡេអូន នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ។

បទដ្ឋានត្រួតត្រានៃច្បាប់អន្តរជាតិបច្ចុប្បន្នគឺមានដាក់ស្តែងនៅប្រទេសសេរ៉ាឡេអូន ដែលនៅទីនោះ អង្គការសហប្រជាជាតិសន្យាថានឹងបង្កើតតុលាការ«ចម្រុះ»ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មសង្គ្រាមដោយផ្អែកតាម«គំរូរបស់ប្រទេសកម្ពុជា» ។ សូម្បីតែចុងចោទដ៏សំខាន់បំផុតឈ្មោះ ហ្វូឌី សានកូស ដែលកំពុងតែនៅក្នុងការឃុំឃាំង ក៏ការជំនុំជម្រះក្តីមិនទាន់ចាប់ផ្តើមដែរ ហើយថវិកាត្រូវបានកាត់បន្ថយទៀតផង ។ ចំណែកឯនៅតុលាការពិសេសពីររបស់អង្គការសហប្រជាជាតិនៅទីក្រុងឡាអេនិងអារូសាវិញ អង្គការសហប្រជាជាតិបានចំណាយថវិការហូតទៅជិតដល់មួយកោដិដុល្លារដើម្បីកាត់ក្តីបុគ្គលមិនដល់៥០នាក់ផង ។ នៅក្នុងស្រមោលដ៏វែងអន្លាយនៃព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ដែលមានឈ្លើយសឹកអាមេរិកកាំងកំពុងប្រឈមមុខនឹងតុលាការយោធាបែបប្រពៃណីនោះ (ចាស់គំរឹលជាង) ការអះអាងអំពីសមត្ថកិច្ចសកលគឺជាការអះអាងមួយដែលមិនសុចរិត (ប្រហោងក្នុង ឬ នៅខាងក្នុង) ។ ប្រសិនបើការធ្វើបត្យាប័ននិងជំនុំជម្រះក្តី ស្លូបូដាន មីឡូសឺវិច ជាការចាប់ផ្តើម«ទំព័រសករាជថ្មីនៃការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ជាអន្តរជាតិ»មែននោះ វាគ្មានអ្វីឲ្យប្លែកណាស់ណាពីសករាជមុនឡើយ ដោយហេតុថា បណ្តុំនៃវិធាននិងបទដ្ឋានគតិយុត្តិមួយចំនួនមានលក្ខណៈដូចគ្នាដដែល ។ សព្វថ្ងៃនេះ មេដឹកនាំខ្មែរក្រហមដូចជា អៀង សារី នួន ជា ខៀវ សំផន និងមេដឹកនាំមួយចំនួនទៀត កំពុងតែរស់នៅដោយមានសេរីភាព ។ ប្រហែលជាការលើកលែងទោសជាតម្លៃសន្តិភាពនៅកម្ពុជាហើយមើលទៅ ។ **ភីតធ័រ ម៉ារឃ្សៀរ**

# ការជំនុំជម្រះក្តីមីឡូសីវិច

សព្វថ្ងៃនេះហាក់មានទំនោរទៅលើសាកលភាវូបនីយកម្មយុត្តិធម៌ ។ ការកាត់ទោស មីឡូសីវិច គឺជាគំរូដ៏ល្អមួយ ។ ស្លូបូដាន មីឡូសីវិច បានរៀបចំការធ្វើមនុស្សឃាតលើមនុស្សរាប់ពាន់នាក់ នៅក្នុងយុទ្ធនាការ“ដ៏សាហាវឃោរឃៅ”មួយ ក្នុងគោលបំណងបំពេញនូវតម្រូវការស្រេកឃ្លានអំណាចរបស់ខ្លួន ។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២នេះ តុលាការព្រហ្មទណ្ឌអន្តរជាតិនៅទីក្រុងឡាអេប្រទេសហុល្លង់ បានបើកសវនាការជំនុំជម្រះក្តី មីឡូសីវិច ដែលជាប្រមុខរដ្ឋទីមួយត្រូវប្រឈមមុខនឹងតុលាការអន្តរជាតិ ពោលគឺមានរយៈពេល៤ថ្ងៃក្រោយពីអង្គការសហប្រជាជាតិសម្រេចបញ្ឈប់ការចរចាជាមួយរដ្ឋាភិបាលកម្ពុជាស្តីអំពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ការជំនុំជម្រះក្តីនេះគឺជាករណីឧក្រិដ្ឋកម្មសង្គ្រាមធំជាងគេបង្អស់ហើយចាប់តាំងពីពួកហ៊ីត្លែរត្រូវនាំមកកាត់ទោសចំពោះមុខតុលាការយោធាមួយក្រោយពីសង្គ្រាមលោកលើកទី២ ។ មីឡូសីវិច ដែលមានអាយុ៦០ឆ្នាំ ប្រឈមមុខនឹងការចោទប្រកាន់ចំនួន៦៦ករណីទាក់ទងនឹងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មសង្គ្រាមនៅប្រទេសក្រូអាស៊ី បូស្នៀ និងកូសូវ៉ូ ដែលសម្លាប់មនុស្សអស់រាប់ពាន់នាក់ និងជម្លៀសមនុស្សជាង១លាននាក់ផ្សេងទៀត ។ ប្រការចោទប្រកាន់នីមួយៗមានកម្រិតទណ្ឌកម្មដាក់គុកអស់មួយជីវិត ។

មនុស្សរាប់លាននាក់នៅទូទាំងតំបន់បាល់កង់បាននាំគ្នាមើលទូរទស្សន៍ផ្សាយបន្តផ្ទាល់ស្តីអំពីការជំនុំជម្រះជាលើកដំបូងនេះ ។ ទម្រាំតែកសាងរឿងក្តីមួយនេះបានចប់ចុងចប់ដើម វាស៊ីពេលអស់រាប់ឆ្នាំ ។

មីឡូសីវិច ជាប្រធានាធិបតីនៃសាធារណរដ្ឋស៊ែបពីឆ្នាំ១៩៨៩ ដល់១៩៩៧ ។ នៅឆ្នាំ១៩៩៧ មីឡូសីវិច បានក្លាយជាប្រធានាធិបតីនៃសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ ឪពុករបស់ មីឡូសីវិច គឺជាគ្រូបង្រៀន ។ គាត់បានចាកចេញពីផ្ទះតាំងពី មីឡូសីវិច រៀននៅសាលាបឋមសិក្សាម៉្លេះ ។ ឪពុករបស់ មីឡូសីវិច បានធ្វើអត្តឃាតនៅឆ្នាំ១៩៦២ ចំណែកម្តាយធ្វើអត្តឃាតនៅឆ្នាំ១៩៧៣ ។ មីឡូសីវិច បានរៀបការជាមួយសិស្សរួមថ្នាក់ឈ្មោះ ម៉ារីចាណា ម៉ាកូវិច ដែលជាសកម្មជនកុម្មុយនិស្តមកពីត្រកូលអ្នកកាន់លទ្ធិកុម្មុយនិស្តជនជាតិស៊ែប៊ី ។ នៅឆ្នាំ១៩៥៩ មីឡូសីវិច បានចូលក្នុងបក្សកុម្មុយនិស្ត ។ នៅឆ្នាំ១៩៦៤ មីឡូសីវិច ទទួលសញ្ញាប័ត្រច្បាប់ពីសាកលវិទ្យាល័យប៊ែលក្រាដ ។

ចំណែកអ្នកកាន់អំណាចផ្តាច់ការយោធានៃប្រទេសឈីលី ពីណូដេ ត្រូវបានថ្កោលទោសដោយគណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សក្នុងឆ្នាំ១៩៧៧ ពីបទធ្វើទារុណកម្មទៅលើជនជាប់ឃុំឃាំង ។ ក្រោយពីមានការប៉ុនប៉ងធ្វើឃាតនៅឆ្នាំ១៩៨៦ ពីណូដេ បានចាត់វិធានការកាន់តែក្តៅទៅលើអ្នកប្រឆាំងនឹងខ្លួន ។

រដ្ឋធម្មនុញ្ញរបស់ប្រទេសឈីលីការពារឲ្យ ពីណូដេ រួចពីការចោទប្រកាន់នៅក្នុងទឹកដីរបស់ខ្លួន ។ ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញនេះមិនអាចការពារឲ្យរួចពីការចោទប្រកាន់ពីប្រទេសផ្សេងទៀតឡើយ ។ ក្នុងខណៈដែល ពីណូដេ កំពុងតែព្យាបាលជំងឺនៅប្រទេសអង់គ្លេសនៅខែតុលា ឆ្នាំ១៩៩៨ ចៅក្រមជនជាតិអេស្ប៉ាញបានស្នើសុំឲ្យមានការធ្វើបត្យាប័នបញ្ជូនខ្លួន ពីណូដេ ទៅប្រទេសអេស្ប៉ាញ ក្រោមការចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្សក្នុងរយៈពេលដែលគាត់កំពុងកាន់អំណាច ។

នៅដើមឆ្នាំ១៩៩៩ តុលាការកំពូលប្រទេសអង់គ្លេសបានសម្រេចសេចក្តីថា លោក ពីណូដេ អាចត្រូវធ្វើបត្យាប័នដើម្បីឲ្យប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅក្រោយខែកញ្ញាឆ្នាំ១៩៨៨ ជាពេលដែលប្រទេសអង់គ្លេសបានចុះហត្ថលេខាលើកិច្ចព្រម

ព្រៀងស្តីពីសិទ្ធិមនុស្សអន្តរជាតិ ។ កិច្ចព្រមព្រៀងនេះអនុញ្ញាតឲ្យប្រទេសហត្ថលេខីចោទប្រកាន់បុគ្គលទាំងឡាយ រួមទាំងអតីតប្រមុខរដ្ឋដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម អំពើប្រល័យពូជសាសន៍ និងអំពើរំលោភសិទ្ធិមនុស្សផ្សេងៗទៀត ។

ក្នុងចំណោមបរិបទទាំងបីគឺ ការកាត់ទោស មីឡូសីវិច ពីណូជេ និងមេដឹកនាំខ្មែរក្រហមដែលនៅមានជីវិត គ្មានបរិបទណាមួយមានលក្ខណៈធ្ងន់ធ្ងររហូតដោះស្រាយមិនចេញនោះទេ ។ បញ្ហាគឺស្ថិតនៅត្រង់ឆន្ទៈនយោបាយនិងពេលវេលា ។ ជាក់ស្តែងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានចំណាយពេលធ្វើការជាមួយគ្នាអស់រហូតដល់៤ឆ្នាំកន្លះទៅលើបញ្ហាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែនៅតែមិនអាចសម្រេចបានលទ្ធផលជាដុំកំភួននៅឡើយ ក្នុងខណៈដែលមេដឹកនាំខ្មែរក្រហមខិតដល់វ័យកាន់តែទ្រុឌទ្រោម ហើយប្រជាជនកម្ពុជាកាន់តែអន្ទះសាចង់ឃើញអង្គការសហប្រជាជាតិជួយផ្តល់យុត្តិធម៌ដល់រូបខ្លួនក៏ដូចជាឪពុកម្តាយបងប្អូនសាច់សាលោហិតដែលស្លាប់បាត់បង់ជីវិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែងនៅថ្ងៃទី១៥ខែកុម្ភៈកន្លងទៅនេះ កែ ពក អតីតលេខាភូមិភាគឧត្តរ (ក្រោយមកហៅថាភូមិភាគកណ្តាល) បានស្លាប់ដោយគ្មានការកាត់ទោស ក្នុងខណៈដែល កាំងហ្កិច អៀវ ហៅឌុច កំពុងតែជាប់ឃុំនិងជិតដល់ថ្ងៃដោះលែងឲ្យនៅក្រៅឃុំតាមច្បាប់កំណត់ ។ នេះជាប្រផ្នូលមួយដ៏អាក្រក់សម្រាប់ជនរងគ្រោះក្រោមរបបខ្មែរក្រហម ។ អតីតមេដឹកនាំខ្មែរក្រហមទាំងអស់នឹងស្លាប់ម្តងមួយៗ ដោយបន្សល់ទុកនូវមន្ទិលសង្ស័យរាប់លានករណីសម្រាប់អ្នករងគ្រោះក្រោមរបបនេះផ្ទាល់ ដរាបណាគ្មានសញ្ញាណបញ្ជាក់ថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងត្រូវបង្កើតឡើងឆាប់ៗនេះទេនោះ ។ **ស្ទួ ប៊ុនស៊ុ**



វិចិត្រករអាយុ១២ឆ្នាំ

# សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្លើយតបនឹងសេចក្តីប្រកាសដកខ្លួនរបស់អង្គការសហប្រជាជាតិ ពីការចរចាអំពីដំណើរការកាត់ទោសខ្មែរក្រហម

## ថ្លែងដោយឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការបរទេស និងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

## ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២

ខ្ញុំបានទទួលលិខិតមួយច្បាប់ចុះថ្ងៃទី៨ កុម្ភៈ ពីឯកឧត្តម ហេន ខូរេល ដែលក្នុងនោះឯកឧត្តមបានថ្លែងថា អង្គការសហប្រជាជាតិនឹងឈប់បន្តការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា ឆ្ពោះទៅបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ខ្ញុំសូមសម្តែងនូវការស្រងាកចិត្តយ៉ាងខ្លាំងចំពោះការប្រកាសដែលមិនរំពឹងទុកទាំងស្រុងបែបនេះ ។

នេះជាការភ្ញាក់ផ្អើលដោយបានដឹងថាលេខាធិការដ្ឋានអង្គការសហប្រជាជាតិគិតថា វាហាក់បីដូចជាយើងមិនអាចដោះស្រាយបញ្ហាតាមការចរចាបន្ថែមទៀតបាន ទោះបីជាភាគីទាំងពីរបានឈានដល់ការឯកភាពគ្នាយ៉ាងច្រើនតាមរយៈដំណើរការនៃការចរចាចាប់តាំងពីសេចក្តីព្រាងពីរខុសគ្នាមួយនៃច្បាប់តែមួយត្រូវបានដាក់លើតុចរចាអស់រយៈពេល២ឆ្នាំកន្លះកន្លងមក ។ ការចរចានេះជាកិច្ចការដ៏លំបាកដូចជាការបើកទូកក្តោងតាមផ្លូវទឹកថ្មីដែលគ្មានផែនទី ប៉ុន្តែយើងបានឈានដល់ការរៀបចំតុលាការជាតិមួយ ដោយមានការចូលរួមជាអន្តរជាតិដែលមិនបានព្រាងទុកជាមុន ។ ការសម្របសម្រួលត្រូវបានធ្វើឡើងរវាងភាគីទាំងសងខាងក្នុងដំណើរការនេះ ប៉ុន្តែខ្ញុំជឿថា គំរូដែលយើងបានរៀបចំ និងដែលត្រូវបានអនុម័តទៅជាច្បាប់កម្ពុជានាថ្ងៃទី១០ សីហា ឆ្នាំ២០០១ បានបង្កើតមូលដ្ឋានដ៏រឹងមាំសម្រាប់ការកាត់ទោសនេះ ។ ខ្ញុំមានជំនឿថា ច្បាប់ដែលបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយមានការចូលរួមជាអន្តរជាតិ និងឆ្លើយតបនឹងស្តង់ដារអន្តរជាតិដែលអាចទទួលយកបាននេះ អាចធ្វើឲ្យចេញជារូបរាងនូវគោលការណ៍ជាមូលដ្ឋានទាំងអស់ដែលបានឯកភាពគ្នារវាងភាគីទាំងពីរក្នុងអំឡុងពេលចរចា ។

បីសប្តាហ៍មុន ខ្ញុំបានសរសេរលិខិតផ្ញើជូនឯកឧត្តម ហេន ខូរេល តាមខ្លឹមសារទាំងនេះ និងបានឆ្លើយតបយ៉ាងលម្អិតចំពោះចំណុចទាំង១១ដែលឯកឧត្តមលើកឡើងពាក់ព័ន្ធនឹងច្បាប់ ដោយបំភ្លឺច្បាស់លាស់នូវជំហររបស់យើង និងសំណូមពរលើចំណុចពាក់ព័ន្ធមួយចំនួនអាចត្រូវបានដាក់បញ្ចូលក្នុងអត្ថបទសហប្រតិបត្តិការ *Articles of Cooperation* ដែលបានស្នើដើម្បីចុះហត្ថលេខាដោយភាគីទាំងពីរ ហើយឯកសារដែលធ្លាប់តែពោលនេះនឹងគ្រប់គ្រងការចូលរួមជាអន្តរជាតិក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

ដើម្បីផ្តល់នូវសាវតារបន្ថែម ចំពោះសេចក្តីថ្លែងការណ៍របស់ខ្ញុំនាថ្ងៃនេះ ខ្ញុំនឹងបញ្ចេញនូវលិខិតរបស់ខ្ញុំដែលបានផ្ញើជូនឯកឧត្តម ហេន ខូរេល កាលពីថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០០១ និងថ្ងៃទី២២ មករា ឆ្នាំ២០០២ ក៏ដូចជាឯកសារផ្សេងៗទៀត រួមទាំងការបកប្រែជាភាសាអង់គ្លេសនៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ ។ រហូតដល់ពេលនេះ យើងសូមកោតសរសើរចំពោះឯកឧត្តម ហេន ខូរេល ដែលបានឯកភាពរក្សាការពិភាក្សាផ្ទាស់ប្តូរមតិយោបល់រវាងភាគីទាំងពីរដោយសម្ងាត់ ប៉ុន្តែដោយយោលលើសកម្មភាព

ឯកតោភាគីបច្ចុប្បន្នពីអង្គការសហប្រជាជាតិក្នុងការបញ្ឈប់ពិភាក្សា និងដោយយោលលើការបកស្រាយខុសយ៉ាងពិតប្រាកដចំពោះជំហររបស់កម្ពុជា ដែលបានលេចចេញពីបទអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិនាថ្ងៃទី៨ កុម្ភៈ នោះ វាហាក់បីដូចជាមានបំណងផ្សព្វផ្សាយឯកសារនេះជាសាធារណៈក្នុងពេលនេះ ។

ឥឡូវនេះ ខ្ញុំសូមធ្វើការឆ្លើយតបដោយត្រង់ៗ ទៅនឹងចំណុចសំខាន់ពីរ នៅក្នុងសេចក្តីថ្លែងការដ៏វែងនិងស្មុគស្មាញដែលបានធ្វើឡើងដោយឯកឧត្តម ហេន ខូរេល កាលពីថ្ងៃសុក្រទី៨ កុម្ភៈ ដូចតទៅ៖

**ទី១** ការអះអាងទូទៅត្រូវបានធ្វើឡើងថា អង្គជំនុំជម្រះវិសាមញ្ញដូចដែលបានគ្រោងទុកបច្ចុប្បន្ន នឹងមិនអាចធានាបាននូវឯករាជ្យភាព ភាពមិនលម្អៀង និងគោលដៅបានទេ ហើយជាឯកសារយោងអរូបីចំពោះស្តង់ដារយុត្តិធម៌អន្តរជាតិ ប៉ុន្តែឯកឧត្តម ហេន ខូរេល ពុំបានផ្តល់នូវការបកស្រាយណាមួយដែលថា ច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញនឹងស្តង់ដារនេះឡើយ ។

**ទី២** ចំណុចសំខាន់ទីពីរពាក់ព័ន្ធនឹងទំនាក់ទំនងរវាងច្បាប់កម្ពុជាដែលបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងអត្ថបទសហប្រតិបត្តិការដែលបានស្នើដើម្បីចុះហត្ថលេខារវាងភាគីទាំងពីរ ។ នៅក្នុងលិខិតរបស់ខ្ញុំចុះថ្ងៃទី២៣ វិច្ឆិកា ខ្ញុំបានរៀបរាប់ថា តាមទស្សនៈរបស់យើង "ច្បាប់ដែលត្រូវបានអនុម័តដោយអង្គការនីតិបញ្ញត្តិកម្ពុជាក្រោមរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់នូវយុត្តាធិការនិងសមត្ថកិច្ចនៃអង្គជំនុំជម្រះ ក៏ដូចជាសមាសភាពរចនាសម្ព័ន្ធគ្រប់គ្រងនិងនីតិវិធីនៃការធ្វើសេចក្តីសម្រេច ផ្ទុយទៅវិញអត្ថបទសហប្រតិបត្តិការកំណត់ទម្រង់ការនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ក្នុងការអនុវត្តមាត្រាទាំងឡាយនៃច្បាប់ដែលពាក់ព័ន្ធនឹងការជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ។

យើងឃើញការដាច់ពីគ្នាកាន់តែច្បាស់ រវាងភាពដើមនិងគោលបំណងនៃច្បាប់ និងអត្ថបទសហប្រតិបត្តិការ ។ យើងពុំមានបំណងណាមួយ ដើម្បីបន្ថយខ្លឹមសារនៃអត្ថបទសហប្រតិបត្តិការដល់ឋានៈជាឯកសារបច្ចេកទេសនិងរដ្ឋបាលដែលចំណុះច្បាប់ទេ (ដោយប្រើពាក្យរបស់ឯកឧត្តម ហេន ខូរេល) ។ មិនមែនជាការត្រឹមត្រូវទេ ដូចដែលតាមសម្តីនៃអ្នកនាំពាក្យរបស់អគ្គលេខាធិការ) ថារដ្ឋាភិបាលកម្ពុជាបានបដិសេធនូវសំណើរបស់អង្គការសហប្រជាជាតិ ដែលជំនួយឧបត្ថមរបស់អង្គការសហប្រជាជាតិនឹងត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ។ តាមការពិត នេះជាតួនាទីដែលយើងបានគ្រោងរៀបចំសម្រាប់អត្ថបទសហប្រតិបត្តិការ ដូចមូលដ្ឋានធម្មតានៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរដ្ឋជាសមាជិកមួយជាមួយអង្គការសហប្រជាជាតិដែរ ។

រដ្ឋជាសមាជិកមួយចំនួនរបស់អង្គការសហប្រជាជាតិដែលជាអ្នកគាំទ្រដ៏ខ្លាំងក្លានៃការចរចាឆ្ពោះទៅបង្កើតតុលាការកាត់សេចក្តីខ្មែរក្រហម បានសម្តែងនូវគោលបំណងរបស់ខ្លួនក្នុងការបន្តដំណើរការនេះ (ការដកស្រង់ពីសេចក្តីថ្លែងការណ៍ទាំងនេះនឹងត្រូវបានចែកជូនបន្ទាប់ពីសន្និសីទនេះ) ។ អនុញ្ញាតឲ្យខ្ញុំថ្លែងយ៉ាងច្បាស់ថា ពីភាគីកម្ពុជា ទ្វារនៅតែបើកចំហចំពោះការចរចាជាមួយអង្គការសហប្រជាជាតិ ។ មាត្រាទី៤៦នៃច្បាប់របស់យើងបានបញ្ជាក់យ៉ាងច្បាស់ថា ជាបឋមត្រូវផ្តល់ឲ្យមានការចូលរួមរបស់អង្គការសហប្រជាជាតិក្នុងដំណើរការនេះ ។ វាមានសារសំខាន់ដើម្បីយល់ថា ច្បាប់ដែលបានអនុម័តដោយអង្គការនីតិបញ្ញត្តិរបស់យើងគឺជាលទ្ធផលនៃការចរចាទាំងស្រុងរវាងកម្ពុជានិងអង្គការសហប្រជាជាតិ ហើយក្នុងច្បាប់នោះមានចំណុចសម្របសម្រួលជាច្រើនពីភាគីរបស់យើងក៏ដូចជាពីភាគីអង្គការសហប្រជាជាតិដែរ ។

ខ្ញុំសូមធ្វើការសន្និដ្ឋានថា រាជរដ្ឋាភិបាលកម្ពុជានៅតែប្តេជ្ញាក្នុងការស្វែងរកយុត្តិធម៌ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយខ្មែរក្រហម ក្នុងនាមប្រជាពលរដ្ឋកម្ពុជានិងមនុស្សជាតិទាំងមូល ។ យើងជឿជាក់ថា ច្បាប់ដែលបានអនុម័តកាលពីថ្ងៃទី១០ សីហា ឆ្នាំ២០០១ ផ្តល់នូវមូលដ្ឋានគ្រឹះដល់ដំណើរការស្វែងរកយុត្តិធម៌ក្នុងតុលាការកម្ពុជា ដោយមានការចូលរួមជាអន្តរជាតិ ហើយឆ្លើយតបនឹងស្តង់ដារអន្តរជាតិដែលអាចទទួលយកបាន ព្រមទាំងសង្ឃឹមថាអង្គការសហប្រជាជាតិនឹងជាផ្នែកមួយនៃដំណើរការនេះ ។

# សុន សេន និង ប៉ុល ពត



សុន សេន ប៉ុល ពត

# ស្លាប់ព្រោះស្រឡាញ់ស្រុកកំណើត


អ៊ុយ ផាត
បងបង្កើតរបស់ អ៊ុយ សារ៉ុម

កាលនៅពីក្មេង ខ្ញុំធ្លាប់បានចូលទៅក្នុងវិមានរដ្ឋចម្ការមន ជាមួយម្តាយរបស់ខ្ញុំ ដោយសារប្អូនស្រីបង្កើតរបស់គាត់ឈ្មោះ អ៊ុយ សារ៉ុម ត្រូវជាកូនចិញ្ចឹមរបស់លោកសេនាប្រមុខ លន់ ណុល និងលោកជំទាវ ខេង ។ លោកតារបស់ខ្ញុំឈ្មោះ ម៉ា ហ៊ិត ហៅ ម៉ា ហួត និងប្រពន្ធរបស់គាត់ឈ្មោះ យាយលៀន ក៏រស់នៅទីនោះដែរ ។ លោកតា ហួត មានស្រុកកំណើតនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ លោកយាយ លៀន មានស្រុកកំណើតនៅខេត្តកំពត ។ ម្តាយរបស់ខ្ញុំបាននិយាយថា លោកតាខ្ញុំចូលធ្វើទាហានតាំងពីជំនាន់សង្គមរាស្ត្រនិយមមកម៉្លេះ ហើយមានតួនាទីជាអ្នកការពារលោកសេនាប្រមុខ លន់ ណុល ដែលនៅពេលនោះលោកសេនាប្រមុខមានតំណែងជាចៅហ្វាយខេត្តបាត់ដំបង ។ លោកតាខ្ញុំគ្មានជាប់សាច់ញាតិអ្វីជាមួយលោកសេនាប្រមុខទេ ប៉ុន្តែគាត់មានភក្តីភាពចំពោះលោកសេនាប្រមុខណាស់ ។ នៅពេលផ្លាស់ពីខេត្តបាត់ដំបងមករស់នៅភ្នំពេញ លោកតាខ្ញុំមានតួនាទីជាទាហានផង និងជាអ្នកមើលការខុសត្រូវផ្នែកចុងភៅផង ។ ចំណែកឯលោកយាយរបស់ខ្ញុំមានតួនាទីជាអ្នកថែទាំប្រុសពេជ្រ និង ប្រុសគុជ ដែលជាបុត្ររបស់លោកសេនាប្រមុខ ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ លោកតាត្រូវផ្លាស់មកនៅវិមានរដ្ឋចម្ការមនជាមួយលោកសេនាប្រមុខនិងគ្រួសារ ។ នៅពេលដែលសភាពការណ៍ស្រុកខ្មែរគ្មានស្ថិរភាព កូនបង្កើតនិងកូនចិញ្ចឹមរបស់លោកសេនាប្រមុខបានចាកចេញទៅសហរដ្ឋអាមេរិក ។ នៅរវាងឆ្នាំ១៩៧៣-៧៤ លោកសេនាប្រមុខបានប្រាប់លោកតានិងលោកយាយខ្ញុំឲ្យរត់ចេញទៅបរទេសដែរ ប៉ុន្តែគាត់មិនព្រមទៅ ។ លោកសេនាប្រមុខបានប្រាប់ទៀតថា «បើយើងមិនចេញពីស្រុកខ្មែរទេ យើងពិតជាស្លាប់» ។ លោកតាខ្ញុំមិនជឿ ព្រោះគាត់យល់ថា មានមន្ត្រីរាជការនិងទាហានមានបណ្តាស័ក្តិធំៗគេមិនរត់ផង ចំណែកគាត់គ្រាន់តែជាចុងភៅ គ្មាននរណានឹងសម្លាប់គាត់ទេ ។ នៅដើមឆ្នាំ១៩៧៥ លោកសេនាប្រមុខបានចាកចេញពីប្រទេសកម្ពុជាក្រោមរូបភាពថាចេញទៅព្យាបាលជំងឺ ដោយគ្មានមន្ត្រីរាជការណាម្នាក់ចាប់អារម្មណ៍ឡើយ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយចូលទីក្រុងភ្នំពេញ ។ លោកតាខ្ញុំភ្ញាក់ខ្លួន ព្រោះឃើញភាពសាហាវយង់ឃ្នងរបស់ខ្មែរក្រហមដែលបាញ់សម្លាប់ភ្លាមៗចំពោះប្រជាជនណាដែលប្រឆាំងជំទាស់មិនព្រមចេញពីក្រុង ។ ខ្មែរក្រហមបង្ខំឲ្យប្រជាជនចេញក្នុងរយៈពេលតែ៣ថ្ងៃប៉ុណ្ណោះ ។ មុនដំបូងលោកតាខ្ញុំបម្រុងធ្វើដំណើរតាមផ្លូវជាតិលេខ៥ទៅទិសខាងលិច ឆ្ពោះទៅខេត្តកំពង់ឆ្នាំងដែលជាស្រុកកំណើតរបស់គាត់ ប៉ុន្តែដោយសារមនុស្សកកស្ទះច្រើនពេក គាត់ក៏ត្រឡប់មកស្រុកកំណើតបងថ្លៃរបស់គាត់នៅភូមិយកបាត្រ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ នៅទីនោះអង្គការខ្មែរក្រហមបានចែកអង្ករពោតសំឡឹឲ្យហូប ។ ការហូបចុកប៉ុណ្ណឹងមិនអាចគ្រប់គ្រាន់ទេ លោកតាក៏នាំបងប្អូនកូនក្មួយដីកយកគល់ចេកគល់ល្ហុងមកលាយដើម្បីហូបឲ្យបានឆ្អែត ។ ទោះជាអាហារទាំងនេះធ្វើឲ្យគាត់បានឆ្អែតក៏ពិតមែន ប៉ុន្តែអាហារទាំងអស់នេះគ្មានជីវជាតិគ្រប់គ្រាន់សម្រាប់បំប៉នរាងកាយរបស់លោកតាទេ បណ្តាលឲ្យគាត់កើតជំងឺហើម ។ លោកតាប្រឹងដើរត្រុកៗ (ដើរឈប់ៗ) រហូតដល់ភូមិកោះប្រាក់ដែលមានចម្ងាយប្រហែល៧គីឡូម៉ែត្រ ទើបដល់ផ្ទះម្តាយខ្ញុំដែលត្រូវជាក្មួយស្រីរបស់គាត់ ។ ម្តាយខ្ញុំក្រឡេកឃើញក៏ស្ទុះទៅទទួលលោកតាដោយក្តីអាណិត ។ ម្តាយខ្ញុំសួរគាត់ថា ម៉េចបានជាពួងហើមដៃហើមជើងអីចឹង? លោកតាប្រាប់ថា «ហូបមិនគ្រប់គ្រាន់

ហូបតែពោតសំឡី ។ កាលជំនាន់មុន ពោតសំឡីគ្មាននរណាគេស៊ីទេ ឯងយកមកស៊ីហើយស៊ីមិនឆ្អែតទៀត» ។ ម្តាយខ្ញុំសួរទៀតថា ចុះពូឈើអីចឹងខំដើរមកធ្វើអី ។ គាត់ថា មកពីពូឃ្លានពេក ពូថាក្រែងភូមិហ្នឹងធូរជាង ។ ម្តាយខ្ញុំក៏យកអង្ករដែលខ្មែរក្រហមចែកឲ្យតាមគ្រួសារ មកដាំបាយឲ្យលោកតាពីសា ។ លោកតាពីសាបាយបណ្តើរលាន់មាត់បណ្តើរថា ឆ្ងាញ់ណាស់ មិនបាច់មានម្ហូបអីទេ យកតែអំបិលបានហើយ ។ ពីសាបាយឆ្អែត លោកតានិយាយប្រាប់ម្តាយខ្ញុំថា លោកសេនាប្រមុខឲ្យគាត់ចេញទៅប្រទេសអាមេរិក ប៉ុន្តែគាត់មិនទៅ ពេលនេះជ្រុលអស់ហើយ ។ លោកតាសម្រាកនៅផ្ទះម្តាយរបស់ខ្ញុំបានបីថ្ងៃ ក៏ត្រឡប់ទៅវិញ ព្រោះខ្លាចប្រពន្ធគាត់ចាំមើលផ្លូវ ។ ចាប់ពីពេលនោះមក ខ្ញុំមិនដែលឃើញលោកតាមកផ្ទះខ្ញុំទៀតទេ ម្តាយខ្ញុំខំស៊ើបសួរក៏បានដឹងថាអង្គការជម្លៀសគ្រួសាររបស់លោកតាទៅខេត្តពោធិសាត់ តាំងពីពេលនោះមកក៏បាត់ដំណឹងលោកតាឈឹង ។ លុះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានប្រជាជនខ្លះវិលត្រឡប់មកស្រុកកំណើតវិញ ពេលនោះទើបមានដំណឹងថា ក្រុមគ្រួសារលោកតាត្រូវស្លាប់អស់គ្មានសល់ម្នាក់ឡើយ ។ ចំណែកម្តាយខ្ញុំឈ្មោះ អ៊ុយ ផាត បានរស់រានមានជីវិតមកដល់សព្វថ្ងៃនៅភូមិកោះប្រាក់ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដោយសារគាត់មិនត្រូវខ្មែរក្រហមជម្លៀសទៅខេត្តពោធិ៍សាត់ ។

**សុខ ខណ្ណៈ**

សូមសរសេរលិខិត ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក

**ទស្សនាវដ្តី "ស្វែងរកការពិត"**

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ឬតាមទូរសាលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

ឬ Email: dccam@bigpond.com.kh

# លិខិតថ្លែងអំណរគុណ

ពីខ្ញុំ នាយខុទ្ទកាល័យសាលាខេត្តព្រះវិហារ ផ្ញើជូនលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។

ជារៀងរាល់លេខនៃទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលផ្ញើតាមរយៈរថយន្តឈ្នួលមកសាលាខេត្តព្រះវិហារ ខុទ្ទកាល័យបានធ្វើការបែងចែកឯកសារដ៏មានតម្លៃជាប្រវត្តិសាស្ត្រនេះជូនដល់ថ្នាក់ដឹកនាំខេត្ត (អភិបាលខេត្តទាំង៤) និងមន្ត្រីក្រោមឱវាទចំណុះឲ្យសាលាខេត្ត រហូតដល់សាលាស្រុកទាំង៧នៃខេត្តព្រះវិហារយើងខ្ញុំ ។ ជួសមុខឲ្យមន្ត្រីរាជការក្នុងខេត្តព្រះវិហារ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកនាយកនិងសហការីក្រោមឱវាទទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានយកចិត្តទុកដាក់ផ្ញើឯកសារដ៏មានតម្លៃនេះសម្រាប់យើងខ្ញុំទាំងអស់គ្នាបានអាននិងស្រាវជ្រាវអំពីវិនាសកម្មស៊ើរគ្រប់វិស័យក្នុងសង្គមខ្មែរទាំងមូល ដែលកូនខ្មែរគ្រប់រូប គ្រប់ជំនាន់ ត្រូវតែចងចាំជានិច្ចថា ការដឹកនាំ អ្នកដែលជាប្រមុខគេត្រូវត្រិះរិះពិចារណាឲ្យបានច្បាស់លាស់បំផុតមុននឹងសម្រេចកិច្ចការអ្វីមួយ ទើបនាំសង្គមឲ្យរីកចម្រើនបាន ។ ផ្ទុយទៅវិញ អ្នកដែលជាប្រមុខគេ ប្រសិនបើធ្វេសប្រហែសវានឹងនាំឲ្យសង្គមហិនហោចឈឺចាប់ខ្លោចផ្សាបំផុត ដូចកាលពីរបបខ្មែរក្រហមដឹកនាំសង្គមក្រោយថ្ងៃ ១៧-០៤-១៩៧៥ ជាឧទាហរណ៍ស្រាប់ ។

ត្បែងមានជ័យ ថ្ងៃទី៥ ខែ២ ឆ្នាំ២០០២

**នាយខុទ្ទកាល័យ**

**សុខ ប៊ុនលាង**

## *ប្រលោមលោកបដិវត្តន៍ខ្មែរក្រហម*

# ពលិកម្មរម៉ៀះយើង

**(*តពីលេខមុន*)**

*ខ្ញុំឃើញតែមេឃុំស្មៀកខោស្នាប់ភ្លៅចេញមកសំពះអង្វរបាតុករ ថាវាអត់ដឹងរឿងអីទេ វានៅក្រោមបង្គាប់គេទេ ។ អានេះភ័យខ្លាំងពេក ភ្លេចទាំងស្លៀកខោឲ្យស្រួលបួល ។ បងប្អូនយើងដោយខឹងរកអាយមបាលទាំងពីរនាក់មិនឃើញ ក៏កាប់គុទូកៅអីសាលាស្រុក ហែកសំបុត្រស្នាមពួកវាចោលពេញដី ។ បងប្អូនយើងរៀបឡើងឡានទៅកម្ទេចផ្ទះមីកន្ទំប្រពន្ធអាសក្តិ៤ទៀត ដែលស្ថិតនៅខាងកើតសាលាស្រុក តែឃើញផ្ទះវាចាក់សោឥតមនុស្សនៅ ។ បងប្អូនក៏ថយមកសរសេរពាក្យស្លោកប្រឆាំងថ្កោលទោសនៅតាមជញ្ជាំងសាលាស្រុកជាច្រើន ហើយក៏លើកគ្នាត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ ។*

*តាំងពីពេលនោះមក អ្នកភូមិយើងបង្កើតបានជាចម្រៀងច្រៀងតៗគ្នាមកថាៈ*

*«អ្នកភូមិសំឡូតយើងឈឺចាប់ក្រៃ*
*អាវុធនៅដៃក្រោកឡើងតវ៉ា*
*មីកន្ទំវាភ័យវារត់ឆ្វេឆ្វា*
*អាមេឃុំនោះណារត់មកតែខោស្នាប់*
*អាឈួនភ័យខ្លាំងខ្លាចគេសម្លាប់*
*វាក៏ប្រញាប់ឡើងឡានអាផុនទៅបរ» ។*

*ចម្រៀងនេះក្លាយទៅជាចម្រៀងប្រជាប្រិយប្រចាំស្រុក ដែលលើកទឹកចិត្តបំផុសនិងជំរុញចលនាតស៊ូរបស់ប្រជាជនយើងនៅសំឡូតជាបន្តបន្ទាប់ទៀត ។*

*រំលងមួយអាទិត្យមក ពេលប្រហែលជាម៉ោង៤ទៀបភ្លឺ ខ្ញុំកំពុងតែមូរកន្ទេល ស្រាប់តែឃើញម៉ែរត់ត្រហេបត្រហបឡើងមកលើផ្ទះស្រែកថា «ពុកវា ទាហានព័ទ្ធភូមិអស់ហើយ!» ។ ស្រែកបានតែប៉ុណ្ណោះ ស្រាប់តែឃើញទាហានអាវុធគ្រប់ដៃផុសឡើងនៅគ្រប់ច្រកភូមិ ។ អាទាហានខ្លះសំរុកឡើងលើផ្ទះបងប្អូនយើងខ្លះទៅហើយ ។ ខ្ញុំរត់ចុះមកដីឃើញ អាឈួននិងអាជក់ខ្សៀ បញ្ជាទៅកូនទាហានវាថាៈ «អាណាតដៃបាញ់ចោលទាំងអស់!» «ពួកហ្អែងឆែកឆេររើកកាយមើលឲ្យខ្ទេចខ្ទីក្រែងលោពួកវាលាក់កាំភ្លើង!» «ចាប់អាមេៗឲ្យបានទាំងរស់មកឲ្យអញ!» ។ ភ្លាមៗនោះឃើញអាពួកហ្វាស៊ីសទាំងនោះធាក់តាយុត អ៊ំណាម ធ្លាក់រមៀលតាមកាំជណ្តើរពីលើផ្ទះ ។ ដៃគាត់ទាំងពីរជាប់ចំណងយ៉ាងតឹង ។ ព្រមជាមួយគ្នានោះដែរ ខ្ញុំឃើញគេបណ្តើរ អ៊ំត្រា អ៊ំព្រីង ពូខឿន ពីខាងលិចភូមិមក ។ អាទាហានមួយពួកទៀតឡើងស្រចូលឆែកឆេរផ្ទះខ្ញុំ ។ ម៉ែឈរនៅក្រោមផ្ទះកាន់ដៃខ្ញុំម្ខាងបងម្ខាង ។ ពុកបាត់មិនដឹងទៅណា ។ វារើដផ្ទះមួយសន្ទុះធំអត់បានការអីទាំងអស់ ។ អាកាប៉ូរ៉ាលគេស្រែកមកដីថាៈ «អត់ឃើញអីទេតេជគុណអើយ!» ។ អាឈួនក៏ស្រែកទៅវិញថាៈ «ប៉ុណ្ណឹងបានហើយ! ចាប់បានអាស្វាប៉ុន្មាននាក់នេះក៏ល្មមដែរហើយ!» «មក ទៅបន្ទាយវិញ!» ។ ពួកអាទាហានក៏ចាប់អ៊ំៗនិងពូៗយើងគ្រវែងគ្រវាត់ឡើងលើឡានបើកចេញពីភូមិទៅបាត់ ។ ខ្ញុំខំតាមសម្លឹងអ៊ំៗពូៗយ៉ាងស្រងូតស្រងាត់ក្នុងចិត្ត ។ អ៊ំៗពូៗក៏សម្លឹងមកខ្ញុំវិញដែរ ។*

*គ្រួសារអ្នករងគ្រោះទាំងអស់លក់បញ្ចាំកេរមរតកទ្រព្យសម្បត្តិដែលមានអម្បាលម៉ាន ដើម្បីតាមដានរឿងប្តីរបស់ខ្លួន ។ តែឥតអំពើសោះ ។ លុយក៏អស់ ដំណឹងពីប្តីក៏អត់បាន ។ ចំណេញតែពួកអាទាហាននិងពួកអាសាលាស្រុកបោកយកលុយចាយផ្ញើព្រងើយ ។ វាភរថាចាំថ្ងៃនេះថ្ងៃនោះវាឲ្យដំណឹង ។ តែដល់ថ្ងៃសន្យាវាលើកទៅស្អែក រួចហើយស្អែកមួយទៀតពុំចេះចប់ ។ អស់ពីរឿងសន្យា វាទារលុយបន្ថែមថាយកទៅសូកលោកនេះលោកនោះ វាត្រូវការប៉ុណ្ណេះម៉ឺនប៉ុណ្ណោះម៉ឺន ។ បានស្តីផ្ញើម៉ឺន បើបងប្អូនយើងរកតែច្រកក្រពះមិនទាំងគ្រប់ផង ។ បងប្អូនយើងខាតសព្វខាតគ្រប់ គឺខាតលុយ ខាតពេលវេលា ខាតការងារ ថែមទាំងចាញ់បោកវា យកលុយទៅឲ្យពួកវាស៊ីទទេៗទៀត ។ ព្រៃផ្សៃជាងនេះទៅទៀត ដល់ឃើញនៅតែ*

ស្រីៗបេះតែឡើងចុះសួរនាំពីរឿងប្ដីសី ពួកវាហ៊ានទាំងបែចង់ហើយរហូតចាប់ប្រពន្ធកូនអ្នករងគ្រោះរំលោភលេងសើចតាមទំនើងចិត្តពាលយង់ឃ្នងរបស់វាផង ។

កន្លះខែក្រោយមក ពួកបន្ទាយទាហាននិងពួកសាលាស្រុកផ្សាយថា តាយុត អ៊ំណាម អ៊ំព្រីង អ៊ំត្រា ពូមឿន ចងកសម្លាប់ខ្លួនក្នុងគុកទៅហើយ ។ ឯសពជនរងគ្រោះទាំង៥នាក់ក៏បូជារួចស្រេចបាច់ហើយដែរ ។ គ្រួសារសពទៅសុំធាតុ ពួកវាអត់ឲ្យ ថែមទាំងគំរាមថាប្រយ័ត្នចាប់ទាំងប្រពន្ធដាក់គុកទៀត ។ គ្រួសារអ្នករងគ្រោះអស់សង្ឃឹមក៏វិលមកផ្ទះវិញទាំងក្រៀមក្រំ ។

ចំណែកឯពុកខ្ញុំ ពុកលែងបានចូលស្រុកភូមិទៀតហើយ ។ ពុកលួចមកផ្ទះពេលយប់ៗម្ដងៗ ខ្ញុំសួរពុកថាៈ ពុកទៅឯណា? ពុកឆ្លើយថា ទៅនៅជាមួយលោកតាឯភ្នំឯណោះ ។ ដឹងដំណឹងនេះភ្លាម ពុកអត់ជឿពាក្យវាផ្សាយបន្តិចបន្តួចសោះឡើយ គាត់ចោទយ៉ាងច្បាស់ថា គឺពួកវាសម្លាប់ពូៗអ៊ំៗទាំងនោះ ពុំមែនចងកសម្លាប់ខ្លួនឯងទេ ។ ពុកបានប្ដេជ្ញាសងឈាមអ៊ំៗពូៗទាំងនោះឲ្យបានជាដាច់ខាត ។ ពុកចងអាឃាតនឹង អាឈួន និង អាផុន យ៉ាងក្ដៅក្ដួលក្នុងចិត្ត ហើយប្ដេជ្ញាថានឹងកម្ទេចវាឲ្យបានថ្ងៃណាមួយ ។

◆◆◆

ចូលមកដល់ដើមខែប្រូត ស្រាប់តែអ្នកបររទេះផ្សាយប្រាប់អ្នកភូមិថា អាជក់ខ្សៀត្រូវ“ខ្មែរក្រហម”សម្លាប់នៅត្រង់អូររង់ខេន ។ ខ្លួនត្រូវគ្រាប់សុសពេញខ្លួន ចំណែកមាត់វាសុទ្ធតែភក់ពេញ ។ ខ្ញុំនឹកក្នុងចិត្តថា ពួកហ្វែងប្លន់ដីគេ ត្រូវតែស៊ីដីដូច្នេះហើយ ។ តែអ្នកបររទេះក៏បានប្រាប់យើងដែរថា ពួកប៉ូលិសក៏ចាប់បានខ្មែរក្រហម៣នាក់វិញដែរ ហើយពួកវានឹងយកទៅបាញ់ចោលជាសាធារណៈនៅថ្ងៃស្អែកនេះ ។

ស្អែកឡើង យើងទៅមើលគេប្រហារជីវិត“ខ្មែរក្រហម” ៣នាក់នៅខាងកើតភ្នំព្រះ ព្រោះ អាឈួន វាឲ្យកេណ្ឌអ្នកស្រុកទៅមើលទាំងអស់ ។ វាកេណ្ឌអ្នកស្រុកទៅនេះក្នុងគោលបំណងសម្លុតស្មារតីប្រជាជនកុំឲ្យយកតម្រាប់តាមជនទាំង៣នាក់នេះ ហើយឲ្យបាក់បបខ្ទបខ្ទាចពួកវាជារៀងរហូត ។

ពេលគេបណ្ដើរអ្នកទោសយកទៅចងនឹងបង្គោលប្រហារជីវិត ទើបយើងស្គាល់ថា ក្នុងចំណោម“ខ្មែរក្រហម”៣នាក់នេះម្នាក់ជាឪពុកខ្ញុំតែម្ដង ។ ខ្ញុំស្លុតក្នុងចិត្តពន់ពេក ។ ខ្ញុំមើលមុខម៉ែម៉ែភ្នែករលីងរលោង ។ ពុកបែបឥតដឹងថាកូនពុកឈរមើលគេសម្លាប់ពុកទេមើលទៅ? យើងឈរឆ្ងាយពីគ្នាតែប្រហែល ៥០ ជ្វាយម៉ែត្រប៉ុណ្ណោះ តែហាក់ដូចជាមានមហាសមុទ្រខណ្ឌយើងទាំងពីរមិនឲ្យស្គាល់មិនឲ្យហៅគ្នាឮឡើយ ។ លុះដល់ម៉ោងពួកវាហើយ ពួកវាចងពុកផ្អិបនឹងសសរ ។ ពុកមានតែខោខ្លីមួយប៉ុណ្ណោះ ។ សាច់ពុកបែកហើម ហើយដាំទាំងដុំៗ ។ ពុកឈានដើរដោយលំបាក ភ្នែកហើមលឹប ។ ចិញ្ចើមមានស្នាមរយះមាត់បែកឈាមហូរសស្រាក់ ។ នៅនាទីចុងក្រោយនេះ តើពុកមាននឹកដល់ខ្ញុំ បង និងម៉ែ ទេ? ពុកអត់ដឹងថាកូនប្រុសកូនស្រីពុកនៅក្នុងចំណោមប្រជាជនដែលឈរមើលនេះទេមើលទៅ? ខ្ញុំឃើញពុកងាកទៅមើលមិត្តគាត់២នាក់ទៀតនៅជិតនោះ ។ ពូពីរនាក់ទៀតសោតក៏ញញឹមយ៉ាងកក់ក្ដៅទៅរកពុកខ្ញុំរួចស្រាប់តែគេឮសូរសម្រែកដែលគេមិនបានស្មានទុកជាមុនសោះថាៈ “ជយោបដិវត្តកម្ពុជា! ជយោបដិវត្តកម្ពុជា! ជយោបដិវត្តកម្ពុជា!” ។ សម្រែកនេះលាន់ឡើងខ្ទរដើងព្រៃ ហើយមកអង្រួនបេះដូងខ្ញុំឲ្យញាប់ញ័រនិងពុះកញ្ជ្រោលឡើងមួយរំពេច ។ សម្រែកជយឃោសន៍ “ជយោបដិវត្តកម្ពុជា!” និងសម្រែកបដិសេធពួកអានាម៉ិននិងនាយទាហានប្រតិកិរិយា ក៏លាន់ឡើងកងរំពងខ្ទរខ្ទារពេញព្រៃ ។ ភ្លាមនោះ ប្រជាជនយើងក៏សម្រុកចូលវាយប្រតាយប្រតប់ជាមួយពួកអាទាហានដែលឈរយាមរាំងមិនឲ្យយើងចូល ។ ឃើញសភាពការណ៍ជ្រួលច្របល់យ៉ាងនេះ ខ្មាំងភិតភ័យតក្កមា ហើយប្រញាប់បាញ់រះសម្លាប់អ្នកជាប់ចោទទាំង៣នាក់នោះភ្លាម ។ ទាហាន១២នាក់ៈ ៦នាក់លុតជង្គង់ ៦នាក់ទៀតឈរ តម្រង់កាំភ្លើងទៅរកពុកខ្ញុំមុនគេ ។ អាម្នាក់ទៀតកាន់កាំភ្លើងខ្លីបញ្ជា ។ ខ្ញុំលែងហ៊ានមើលទិដ្ឋភាពនេះតទៅទៀតហើយ ។ ស្នូរកាំភ្លើងផ្ទុះឡើងលាន់សូរដូចរន្ទះ ។ ទ្រូងខ្ញុំក្ដុកក្ដួលអួលណែនឡើងដល់ដើមក ។ ខ្ញុំចង់រត់ទៅឱបពុកខ្ញុំដូចកាលពុកលួចមកលេងផ្ទះនៅពេលយប់ម្ដងៗដូច្នោះដែរ ។ ខ្ញុំចង់ស្រែកទ្រហោយំឲ្យអស់ចិត្ត ។

**(នៅមានត)**

ចម្រៀងខ្មែរក្រហម

# កុមារក្រុមសាមគ្គីរៀនផងធ្វើការផងយ៉ាងរីករាយ

យើងខ្ញុំកុមារាកុមារី ក្នុងក្រុមសាមគ្គីមានរស្មីភ្លឺថ្លា រួមផ្សំពុកម៉ែមីងមាយាយតា
ជំរុញចលនាកសាងកម្ពុជាថ្មី រុងរឿងប្រាកដ ។

ពេលព្រឹកយើងរៀនលេខអក្សរ យើងរៀនវប្បធម៌និងរៀនប្រវត្តិ នៃការតស៊ូប្រឆាំងចក្រពត្តិ
ខ្លាំងក្លាមោះមុតគ្មានអ្វីប្រៀបបាន នៃប្រជាជនកម្ពុជាយើង ។

ពេលរសៀលយើងនាំគ្នាធ្វើព្រូ ជាមួយបងគ្រូញាប់ដៃញាប់ជើង ខ្លះចេញឃ្វាលគោខ្លះរែកចំបើង
ទៅមកចុះឡើងខ្លះស្រោចបន្លែ ខ្លះជញ្ជូនដី ។

យើងសាងប្រទេសឡើងវិញ លុបបំបាត់ចេញកំអែលចក្រពត្តិ ស្ទួយប្រទេសយើងទាំងក្រុងជនបទ
ចំរើនវិវឌ្ឍន៍សំបូរសប្បាយ ទូលាយគ្រប់ផ្នែក ។

យើងរស់នៅក្នុងកម្ពុជាថ្មី យើងសែនរីករាយចូលរួមចំណែក សាងកម្ពុជាយើងឲ្យបានល្អឯក
ថ្ងៃថ្លាអនេកសុភមង្គល ជូនប្រជាជនយើង ។

រៀនផងហើយយើងធ្វើការផង ជាមួយបង១ពុកម៉ែមាមីង នៅក្រោមរស្មីបដិវត្តន៍ចាំងចែង
ភ្លឺផ្លេកក្រៃលែងអង្គការបដិវត្តន៍ មហិមាបំផុត ។

អនាគតភ្លឺច្បាស់នៅមុខយើង ដល់ពេលធំឡើងយើងរត់ត្រសង ជ្រោងគ្រវីទង់បន្តវេនបង១
ធានារ៉ាប់រងជ្រោងទង់បដិវត្តន៍ រៀងរហូតអើយ ។

រៀងរៀងចងក្រងជាឯកសារ

កញ្ញា សើ សាយ្យាណា

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១ ០ ០ ០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់នៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០ ០ ០ រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.